ISSN 1560-7615

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី៦ លេខ១ | មករា - មីនា ឆ្នាំ២០០២ | តម្លៃ ១.៥០០៛

# ចំណោទស្តីពីព្រៃសម្បទានមានចីរភាពនៅកម្ពុជា

**លោក Bruce McKenney បានពិនិត្យពីជំនួយទ្រទ្រង់របស់ពួកទាយកដល់ការគ្រប់គ្រងព្រៃឈើឱ្យមានចីរភាព វិភាគពីចំណុចបង្អាក់ទឹកចិត្តខាងហិរញ្ញវត្ថុរបស់ពួកសម្បទានិកក្នុងការទទួលអនុវត្តន៍កំណែទំរង់ និងវាយតំលៃពីប្រសិទ្ធិភាពនៃប្រព័ន្ធព្រៃសម្បទានកម្ពុជា ក្នុងលក្ខណៈជាមធ្យោបាយដើម្បីទទួលឱ្យបានគោលដៅខាងអភិវឌ្ឍន៍ ។***

ចាប់ពីឆ្នាំ១៩៩៤ ដល់ ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតឱ្យមានជាង ៣០ ព្រៃសម្បទានសំរាប់ពាណិជ្ជកម្មដែលមានផ្ទៃដីសរុប ប្រហែល ៦,៥ លានហិកតា គឺស្មើនឹងមួយភាគបីនៃផ្ទៃប្រទេស ឬជាងពាក់កណ្តាលនៃព្រៃឈើនៅកម្ពុជា ។ តាមការអនុវត្តន៍ប្រព័ន្ធព្រៃសម្បទាន រដ្ឋាភិបាលបានស្វែងរកវិធីផ្ទេរការទទួលខុសត្រូវក្នុងការគ្រប់គ្រងព្រៃឈើទៅឱ្យក្រុមហ៊ុនឯកជន, និងប្រមូលចំណូលដែលកំពុងត្រូវការយ៉ាងខ្លាំងសំរាប់ការអភិវឌ្ឍន៍ជាតិ ។ ទោះបីតាំងពីពេលនោះមក រដ្ឋាភិបាលបានលុបចោលក្រុមហ៊ុនព្រៃសម្បទានមកត្រឹមតែ ២០ (ប្រហែល ៤.២លានហិកតា) ក៏ដោយ ក៏ប្រព័ន្ធសម្បទាន នៅតែជាមធ្យោបាយចំបងដដែល សំរាប់ការគ្រប់គ្រងព្រៃឈើនៅកម្ពុជា ។



ក្រោមការគ្រប់គ្រងព្រៃឈើមានចីរភាព គេតំរូវឱ្យសម្បទានិកកាប់ឈើតែ ១-៣ដើម ក្នុងមួយហិកតាប៉ុណ្ណោះ ។
រូបភាពនេះបង្ហាញពីនាយកដ្ឋានរុក្ខាប្រមាញ់ និងសត្វព្រៃ ធ្វើអធិការកិច្ចលើការកាប់ឈើក្នុងក្រុមហ៊ុនសម្បទានមួយនៅឆ្នាំ២០០១ ។

ដោយមានបញ្ហាជាច្រើនខាងការប្រមូលផលឈើគ្មានចីរភាព និងការកាប់ឈើខុសច្បាប់នៅក្នុងតំបន់ព្រៃសម្បទាន រដ្ឋាភិបាល និងអ្នកផ្តល់ជំនួយក៏មានគោលនយោបាយទប់ទល់ដ៏ចំបងមួយគឺ ការប្រកាសឱ្យមានការគ្រប់គ្រងព្រៃសម្បទានមានចីរភាព (sustainable forest management: SFM) ។ SFM មាននិយមន័យច្រើនណាស់ ប៉ុន្តែជាទូទៅវាជាការធានាឱ្យធនធានព្រៃឈើអាចផ្តល់ឈើបានរហូត ដោយរក្សាបាននូវគុណភាពព្រៃធម្មជាតិ, ជីវចំរុះ, តួនាទីល្អនៃប្រព័ន្ធ អេកូឡូស៊ី, និងសេវាព្រៃឈើផ្សេងៗទៀតដូចជាការការពារគុណភាពដី និងតំបន់ទីជំរាល, ការរក្សាសិទ្ធិប្រើប្រាស់ធនធានព្រៃឈើរបស់សហគមន៍មូលដ្ឋាន, និងការគាំពារតំលៃផ្សេងៗខាងវប្បធម៌ ។

ក្នុងគោលដៅសំរេចឱ្យបាននូវ SFM នៅក្នុងប្រព័ន្ធសម្បទាន រដ្ឋាភិបាល និងទាយកបានវិនិយោគធនធានច្រើនណាស់ក្នុងប៉ុន្មានឆ្នាំកន្លងទៅនេះ។ គំរោងធំៗមានជាអាទិ៍ គំរោងកែទំរង់គោលនយោបាយព្រៃឈើ (១៩៩៧-១៩៩៨) ផ្តល់មូលនិធិដោយធនាគារពិភពលោក, គំរោងគ្រប់គ្រងព្រៃឈើមានចីរភាព (១៩៩៩-២០០០) ផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ី, និងគំរោងគ្រប់គ្រងព្រៃសម្បទាននិងគំរោងសាកល្បងត្រួតពិនិត្យ (២០០១-២០០៣) ដែលកំពុងអនុវត្តបន្តដោយទទួលមូលនិធីធនាគារពិភពលោក ។ នៅក្នុងការខំប្រឹងប្រែងកែទំរង់ប្រព័ន្ធព្រៃសម្បទានទាំងនេះ វាមានការសន្មតពីរយ៉ាង:

១. SFM ជារបបគ្រប់គ្រងអាចរស់រានជីវិតបានខាងផ្លូវសេដ្ឋកិច្ច ដែលសំរាប់ឱ្យសម្បទានិកទទួលយក និងអនុវត្តនៅក្នុងប្រទេសកម្ពុជា ។
២. ប្រព័ន្ធសម្បទានគឺជាឧបករណ៍គ្រប់គ្រងដ៏សក្តិសិទ្ធិបំផុត សំរាប់ទាញយកអត្ថ

* លោក Bruce McKenney ជាប្រធានកម្មវិធីបរិដ្ឋាន និងធនធានធម្មជាតិនៅ វបសអ ។ កម្មវិធីនេះចាប់ផ្តើម នៅខែតុលា ២០០១ ក្នុងគោលបំណងដើម្បីកែលំអការយល់ដឹងឱ្យកាន់តែប្រសើរឡើងលើបញ្ហាដែលពាក់ពន្ធ័នឹងធនធានធម្មជាតិ និង-

## មាតិកា

ចំណោទស្តីពីព្រៃឈើសម្បទានមានចីរភាពនៅកម្ពុជា ........ ១
ការអភិវឌ្ឍន៍ឧត្តមសិក្សា ........ ៨
ពលកម្មចំណាកស្រុកនៅក្នុងសេដ្ឋកិច្ចអន្តរកាល ........ ១២
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ........ ១៦
— ស្ថានភាពក្នុងប្រទេស ........ ១៨
— សន្ទស្សន៍សេដ្ឋកិច្ច ........ ២១
សន្ធានុក្រម ........ ២៣
ព័ត៌មានថ្មីៗពី វបសអ ........ ២៤

ប្រយោជន៍ពីធនធានព្រៃឈើកម្ពុជាឱ្យអស់លទ្ធភាពដើម្បីបំរើការអភិវឌ្ឍន៍ ។

ដើម្បីវាយតំលៃលើការសន្មតទាំងពីរ អត្ថបទនេះពិនិត្យពីការគាំទ្ររបស់ពួកទាយកសំរាប់ការគ្រប់គ្រងព្រៃសម្បទានមានចីរភាព, ការវិភាគពីចំណុចបង្អាក់ទឹកចិត្តផ្សេងៗផ្នែកហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ចំពោះសម្បទានិកក្នុងការទទួលអនុវត្ត SFM និងការវាយតំលៃពីប្រសិទ្ធិភាពនៃប្រព័ន្ធព្រៃសម្បទានក្នុងលក្ខណៈជាឧបករណ៍សំរាប់ដោះស្រាយគោលដៅខាងអភិវឌ្ឍន៍ ។ បញ្ហានានាដែលលើកឡើងក្នុងអត្ថបទនេះ សង្ឃឹមថានឹងអាចជួយដល់កិច្ចពិភាក្សាដ៏ប្រាកដនិយមនានាអំពីសក្តានុពលសំរាប់ឱ្យសម្បទានិកទទួលយក SFM ហើយផ្អែកលើសេចក្ដីសង្ឃឹមនេះ ព្រមទាំងប្រវត្តិនៃ ប្រព័ន្ធព្រៃសម្បទានផង និងពិចារណាថា តើការកែប្រែផ្សេងៗក្នុងយុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើមានលក្ខណៈសមស្របឬទេ ។

## ជំនួយទ្រទ្រង់របស់ទាយក ចំពោះ SFM នៅក្នុងព្រៃសម្បទាន

គំរូមួយដែលធនធានព្រៃឈើកម្ពុជាអាចរួមចំណែកបំរើគោលដៅអភិវឌ្ឍន៍ត្រូវបានលើកឡើងជាដំបូងក្នុងឆ្នាំ១៩៩៦ ដោយក្រុមបេសកកម្មចំរុះមួយរបស់ធនាគារពិភពលោក, UNDP, និង FAO ។ ក្រុមបេសកកម្មបានគាំទ្រការប្រើប្រាស់ប្រព័ន្ធព្រៃសម្បទានថា ជាឧបករណ៍សមស្របសំរាប់ការអភិវឌ្ឍន៍ធនធានព្រៃឈើកម្ពុជា ហើយបានកត់សំគាល់ថា "ប្រទេសសំបូណ៌ព្រៃឈើជាច្រើនបានប្រើប្រាស់ប្រព័ន្ធសម្បទាន ហើយប្រព័ន្ធនេះអាចរួមចំណែកបានយ៉ាងសំខាន់ក្នុងគោលដៅអភិវឌ្ឍន៍តាមវិស័យនានាដែលពង្រាំងឱ្យវាក្លាយជាឧបករណ៍ដ៏មានប្រយោជន៍សំរាប់គោលនយោបាយព្រៃឈើ" (World Bank *et al* 1996) ។ ការគាំទ្រចំពោះប្រព័ន្ធសម្បទាននេះក៏មានរួមបញ្ចូលផងដែរនូវការអំពាវនាវឱ្យមានកំណែទំរង់ដែលសំដៅធានានូវចីរភាពនៃទិន្នផលឈើបានពីព្រៃសម្បទានព្រមទាំងកំណើនចំណូលព្រៃឈើ ដល់ថវិការដ្ឋ ។ ក្រុមបេសកកម្មបានផ្តល់យោបល់ថា "កំណែទំរង់គោលនយោបាយតាមគោលការណ៍សេដ្ឋកិច្ចទីផ្សារដែលបានលើកឡើងក្នុងរបាយការណ៍ (របស់ក្រុមបេសកកម្ម) និងការកែលំអការត្រួតពិនិត្យតំបន់ព្រៃឈើ អាចបង្កើនចំណូលព្រៃឈើចំពោះថវិការដ្ឋប្រហែល ១០០លានដុល្លារក្នុងមួយឆ្នាំ, ព្រមទាំងធ្វើឱ្យមានចីរភាពប្រសើរថែមទៀតនូវធនធានទាំងនេះ និងដំណើរការល្អខាងបរិស្ថាន និងខាងសង្គមរបស់វា" ។

ដើម្បីជួយទ្រទ្រង់ដល់កំណែទំរង់ទាំងនេះ ធនាគារពិភពលោកបានផ្តល់មូលនិធិសំរាប់ជំនួយបច្ចេកទេស ដោយធ្វើការសិក្សាផ្សេងៗខាងវិស័យព្រៃឈើនៅឆ្នាំ១៩៩៧-៩៨ នៅក្នុងគំរោងកំណែទំរង់គោលនយោបាយព្រៃឈើ ។ លទ្ធផលនៃការសិក្សាបានបង្ហាញនូវបញ្ហាធំៗជាច្រើននៃការកាប់ឈើដោយគ្មានការត្រួតពិនិត្យ និងដោយខុសច្បាប់ទាំងនៅក្នុងនិងនៅជុំវិញព្រៃសម្បទាន, និងចំណូលពីព្រៃឈើដ៏តិចតួចទៅក្នុងថវិការដ្ឋ ។ ឧទាហរណ៍ ប្រហែល ៩៤% នៃឈើផលិតបានក្នុងឆ្នាំ១៩៩៧ គឺជាឈើខុសច្បាប់ ហើយចំណូលថវិការដ្ឋបានពីព្រៃសម្បទានមានប្រហែលតែ ៦លានដុល្លារក្នុងឆ្នាំ១៩៩៧ និង ១០លានដុល្លារក្នុងឆ្នាំ១៩៩៨ (DAI 1998) ។ ទោះបីមានបញ្ហាចោទយ៉ាងនេះក៏ដោយ ក៏គំរោងបានធ្វើការសន្និដ្ឋានថា "ប្រព័ន្ធព្រៃសម្បទានមានលក្ខណៈសមស្របបំផុតសំរាប់ការអភិវឌ្ឍន៍ខាងពាណិជ្ជកម្មនូវធនធានព្រៃឈើកម្ពុជា ប៉ុន្តែត្រូវមានការកែសំរួលខ្លះដើម្បីសំរបតាមស្ថានភាពកម្ពុជា" (Associate for Rural Development 1998) ។ បន្ទាប់មក ធនាគារពិភពលោកបានបូកសរុបនូវលទ្ធផលរកឃើញទាំងនេះ ដោយចេញជាចក្ខុវិស័យយុទ្ធសាស្ត្រមួយសំរាប់វិស័យព្រៃឈើ និងបញ្ជាក់ឡើងវិញពីការគាំទ្រដល់ការគ្រប់គ្រងព្រៃសម្បទានមានចីរភាពនៅប្រទេសកម្ពុជា ប៉ុន្តែបានកែតំរូវដោយបញ្ចុះតួលេខប៉ាន់ស្មាននៃចំណូលព្រៃឈើដល់ថវិការដ្ឋពី ១០០លានដុល្លារ មកត្រឹម ៤០-៨០លានដុល្លារវិញ (World Bank 1999) ។

**គេតែងគិតថា សម្បទានិកបានរារែកក្នុងការទទួលយកកំណែទំរង់ SFM ដោយសារកង្វះការយល់ដឹងពីរបៀបរបបអនុវត្ត SFM និងដោយសារតំរូវការកសាងសមត្ថភាពបន្ថែមទាំងសំរាប់រដ្ឋាភិបាល និងសម្បទានិក, ប៉ុន្តែតាមពិតទៅប្រហែលវាឆ្លុះបញ្ចាំងច្រើនជាងពីលក្ខណៈមិនស៊ីគ្នារវាង SFM និងកិរិតចំណេញរបស់សម្បទាន ។**

ពីឆ្នាំ១៩៩៩ ដល់ ២០០០ គំរោងគ្រប់គ្រងព្រៃឈើមានចីរភាព (Sustainable Forest Management Project: SFMP) ផ្តល់មូលនិធិដោយ ADB បានសិក្សាឡើងវិញពី ប្រព័ន្ធព្រៃសម្បទាន ហើយបានសន្និដ្ឋានថា ការប្រតិបត្តិមិនត្រឹមត្រូវនៃព្រៃសម្បទាន នានាគឺជាសញ្ញានៃ "បរាជ័យទាំងស្រុងរបស់ប្រព័ន្ធ" ។ ការសិក្សាបានរកឃើញថា គ្មានព្រៃសម្បទានណាមួយដែលត្រូវបានគ្រប់គ្រងឱ្យមានចីរភាពទេ ហើយការកាប់ឈើវាសំរុកខ្លាំងណាស់ធៀបនឹងអាជ្ញាប័ណ្ណអាជីវកម្មឈើដែលមានរយៈពេលដល់ទៅ ២៥ឆ្នាំ ។ ក្នុងចំណោមសម្បទាននានាដែល SFMP អាចប្រមូលពត៌មានបានគ្រប់គ្រាន់, ៤០%នៅសល់ឈើសំរាប់កាប់បាន ៥ឆ្នាំទៀត, ៥០%នៅសល់សំរាប់ ៥-១០ឆ្នាំ, និង ១០%នៅសល់សំរាប់ ១០-១៥ឆ្នាំ (Fraser Thomas 2000) ។ លទ្ធផលរកឃើញនេះគឺស្របតាមការសន្និដ្ឋានក្នុងគំរោងកំណែទំរង់គោលនយោបាយព្រៃឈើដែលបានព្រមានថា ធនធានព្រៃឈើកម្ពុជាអាចអស់តំលៃខាងសេដ្ឋកិច្ចក្នុងរយៈពេល ៥ឆ្នាំ បើសិនជាល្បឿនកាប់ឈើក្នុងឆ្នាំ១៩៩៧ នៅបន្តទៅមុខដូច្នេះទៀត (DAI 1998) ។

ទោះបី SFMP រកឃើញលទ្ធផលយ៉ាប់យ៉ឺនដូច្នេះក៏ដោយ ក៏គំរោងបានផ្តល់មតិឱ្យបន្តការគាំទ្រដល់ប្រព័ន្ធព្រៃសម្បទាននៅកម្ពុជា ដែលក្នុងនេះអាចមានការរៀបចំឡើងវិញ ឬកំណែទំរង់ខ្លះៗ ។ ក្នុងចំណោមអនុសាសន៍ផ្សេងទៀត មានជាអាទិការអំពាវនាវឱ្យសម្បទានិករៀបចំផែនការគ្រប់គ្រងមានចីរភាពឱ្យបានមុនដំណាច់ខែវិច្ឆិកា ២០០១។ សម្បទានិក, នាយកដ្ឋានរុក្ខាប្រមាញ់ (DFW) និងពួកទាយក បាន ឯកភាពចំពោះអនុសាសន៍នេះក្នុងខែឧសភា ២០០០ ដោយកំណត់ថា សម្បទានិកត្រូវ ដាក់ជូនពិនិត្យផែនការគ្រប់គ្រងឱ្យបានមុនដំណាច់ខែកញ្ញា ២០០១ ហើយរដ្ឋាភិបាលត្រូវសំរេច អនុម័តឱ្យបានមុនដំណាច់ខែវិច្ឆិកា ២០០១ ។

ដើម្បីទ្រទ្រង់ដល់ដំណើរការនេះ ក្រុមការងារចំរុះសំរាប់គ្រប់គ្រងព្រៃសម្បទាន ដែលផ្តល់ថវិកាដោយនាយកដ្ឋានសំរាប់ការអភិវឌ្ឍន៍ អន្តរជាតិនៃប្រទេសអង់គ្លេស (DfID) បានបង្កើត ឡើងរវាងសមាគមឧស្សាហកម្មឈើកម្ពុជា (Cambodia Timber Industry Association: CTIA) និងនាយកដ្ឋានរុក្ខាប្រមាញ់ ។ ក្នុងសម័យប្រជុំនាខែតុលា ២០០០ និងខែឧសភា ២០០១, ក្រុមការងារចំរុះបានអនុម័តយកខែកញ្ញា ២០០១ ជាកាលកំណត់សំរាប់ការដាក់ស្នើឡើងនូវផែនការគ្រប់គ្រង ប៉ុន្តែកាលកំណត់នេះបានកន្លងផុតទៅដោយគ្មានសម្បទានិកណាមួយបានអនុវត្តទេ ។ CTIA បានផ្តល់ពត៌មានថា សម្បទានិកភាគច្រើនត្រូវការច្រើនខែទៀត ដើម្បីបង្ហើយផែនការគ្រប់គ្រងសម្បទាន ហើយ មានមួយចំនួនមិនទាន់បានចាប់ផ្តើមធ្វើនៅឡើយទេ ។

ថ្មីៗនេះទៀត ធនាគារពិភពលោកបានបន្តជំនួយទ្រទ្រង់ដល់ប្រព័ន្ធសម្បទានព្រៃ

ឈើ ដោយបានចាប់ផ្តើមគំរោងគ្រប់គ្រងព្រៃសម្បទាននិងការត្រួតពិនិត្យសាក ល្បង (២០០១-២០០៣) ។ គំរោងនេះមានគោលដៅកែលំអប្រសិទ្ធិភាពនៃការគ្រប់គ្រងព្រៃឈើ, កសាងឯកសារណែនាំអនុវត្តន៍, កំណត់នីតិវិធីត្រួតពិនិត្យនៅក្នុងតំបន់ ព្រៃសម្បទាន, និងកសាងសមត្ថភាពតាមដាននិងទប់ស្កាត់បទឧក្រិដ្ឋព្រៃឈើ (World Bank 2000) ។

## និរន្តភាពខាងសេដ្ឋកិច្ចនៃ SFM ចំពោះសម្បទាន

គេតែងគិតថា សម្បទានិកបានរារែកក្នុងការទទួលយកកំណែទំរង់ SFM ដោយសារកង្វះការយល់ដឹងពីរបៀបរបបអនុវត្ត SFM និងដោយសារតំរូវការកសាងសមត្ថភាពបន្ថែមទាំងសំរាប់រដ្ឋាភិបាល និងសម្បទានិក, ប៉ុន្តែតាមពិតទៅប្រហែលវាឆ្លុះបញ្ចាំងច្រើនជាងពីលក្ខណៈមិនស៊ីគ្នារវាង SFM និងកំរិតចំណេញរបស់សម្បទាន ។ ការអនុវត្តន៍ SFM បង្កើតបន្ទុកចំណាយជាច្រើនចំពោះសម្បទានិក ដែលត្រូវកាប់ឈើឱ្យមានចីរភាព និងប្រតិបត្តិ តាមការតំរូវផ្សេងៗខាងបរិស្ថាន និងសង្គមកិច្ច ។ បន្ទុកចំណាយធំជាងគេ ប្រហែលជាប់ទាក់ទងនឹងការផ្លាស់ប្តូរពីការកាប់ឈើអតិផល (intensive logging) មកអនុវត្តរបបកាប់ឈើមានចីរភាពវិញ ។ ការប៉ះពាល់ដល់កំរិតចំណេញនៃសម្បទាន ដោយសារវិធីគ្រប់គ្រងឱ្យទិន្នផលមានចីរភាពនេះ គេបានទទួលស្គាល់តាំងពីឆ្នាំ១៩៩៦ មកម្លេះ ។

*ដើម្បីទប់ស្កាត់ការកាប់ឈើលើសកំរិត... រដ្ឋាភិបាលគួរតំរូវថាទំហំនៃការកាប់ឈើត្រូវស្របតាមស្តង់ដាកំណត់របស់កម្ពុជាគឺ ប្រហែល ១០ម៉ែត្រគូប/ហិកតា មិនមែន ៥០ម៉ែត្រគូប/ហិកតា ឬក៏លើសពីនេះដូចដែលសម្បទានិកខ្លះបានស្នើឡើងនោះទេ ។ បើសិនកាប់ឈើតែត្រឹមកំរិតមានចីរភាពនេះ ទោះបីជាមានឧបត្ថម្ភកធនខាងសួយខ្លះក៏ដោយ ក៏សម្បទានបច្ចុប្បន្នមិនអាចដំណើរការបានដោយមានចំណេញដូចការគ្រោងទុកនោះទេ ដោយសារអត្រាចំណេញទាបលើការកែច្នៃពីឈើដុលទៅជាផលិតផល យុទ្ធសាស្ត្រម៉ាឃីទីងនៅខ្សោយ និងចំណាយមូលធនកំរិតខ្ពស់* (*World Bank et al 1996*) ។

**ដោយផ្អែកលើពតិមានដែលមានស្រាប់ស្តីពី អត្រាលូតលាស់នៃព្រៃឈើ និងឈើឈរដែលអាចបំរើពាណិជ្ជកម្មបាន, ការអនុវត្តន៍ SFM នៅកម្ពុជាតំរូវឱ្យមានការកាត់បន្ថយបរិមាណឈើកាប់មក ត្រឹមប្រហែល ១០ម៉ែត្រគូប /ហិកតា ឬឈើ ១-៣ដើម/ហិកតា ។**

ទាក់ទិននឹងការកែប្រែពីការកាប់ឈើអតិផល មកជារបៀបមានចីរភាពវិញ ឯកសារផែនការគ្រប់គ្រងព្រៃសម្បទាន(២000)របស់នាយកដ្ឋានរុក្ខាប្រមាញ់តំរូវថា: ១)ការកំណត់ឡើងនូវ ២0-៣0ព្រៃគុប ជាចំណែកចាំបាច់មួយនៃផែនការគ្រប់គ្រងទូទៅសំរាប់ការទាញយកផលវិលពីព្រៃគុបមួយទៅព្រៃគុបមួយក្នុងរយៈពេល ២៥ ឬ ៣0ឆ្នាំ និង ២)ការកាប់ឈើក្នុងព្រៃគុបជ្រើសរើសណាមួយក្នុងមួយឆ្នាំក្នុងកំរិតមិនលើសពី ៣0%នៃឈើឈរដែលអាច លក់បាន (ឈើប្រភេទពាណិជ្ជកម្មដែលមានអង្កត់ផ្ចិតធំជាងកំរិតអប្បបរមា) ។ ការកាប់ឈើដោយជ្រើសរើសបែបនេះអនុញ្ញាតឱ្យឈើឈរដែលនៅសល់អាចលូតលាស់ធំកើតជាព្រៃដូចធម្មតាវិញ ។

នៅឆ្នាំ១៩៩៧ មានតែ ៦% នៃព្រៃកម្ពុជា ប៉ុណ្ណោះ (៦២៥.១៧៧ហិកតា)ដែលជាប្រភេទព្រៃស្រោង (dense evergreen) មានតំលៃសំរាប់ពាណិជ្ជកម្ម, ឯ ៣0%ទៀត (៣.១៨៣.៣៩៥ហិកតា) ជាប្រភេទព្រៃបៃតងរបោះ (disturbed evergreen) ដែលបញ្ជាក់ថាមានការកាប់ឈើខ្លះៗឬធ្ងន់ធ្ងរ ។ ព្រៃនៅសល់ច្រើនតែជាប្រភេទព្រៃជ្រុះស្លឹកប្រចាំឆ្នាំ (deciduous) ដែលគេគិតថា មិនអាចបំរើផលិតកម្មឈើជាលក្ខណៈពាណិជ្ជកម្មបានចំណេញនោះទេ ។

ដោយផ្អែកលើពតិមានដែលមានស្រាប់ស្តីពីអត្រាលូតលាស់នៃព្រៃឈើ និងឈើឈរដែលអាចបំរើពាណិជ្ជកម្មបាន, ការអនុវត្តន៍ SFM នៅកម្ពុជាតំរូវឱ្យមានការកាត់បន្ថយបរិមាណឈើកាប់មកត្រឹមប្រហែល ១0ម៉ែត្រគូប/ហិកតា ឬឈើ ១-៣ ដើម/ហិកតា (World Bank *et al* 1996; DFW 2000) ។ ទោះបីកិច្ចសន្យាសម្បទាន កំណត់ឱ្យសម្បទានិកអនុវត្តរបបកាប់ឈើមានចីរភាពក៏ដោយ ក៏កិច្ចសន្យាបានលើកពីបរិមាណកាប់ ៤0-៥0ម៉ែត្រគូប/ហិកតា ដែលជាកំរិត "កាប់យកទាំងអស់នូវឈើដែលមានតំលៃខាងពាណិជ្ជកម្ម គឺប្រហែលមិនទុកឱ្យព្រៃឈើអាចលាស់ឡើងវិញបានគ្រប់គ្រាន់សំរាប់ការប្រមូលផលលើកទី២ នៅចុងបញ្ចប់វដ្ត ៣0ឆ្នាំនៃការកាប់ឈើនោះទេ (World Bank *et al* 1996) ។

ការដាក់អនុវត្តន៍របបកាប់ឈើមានចីរភាព ១0ម៉ែត្រគូប/ហិកតា មានការពិបាកបំផុត ពីព្រោះអាជីវកម្មព្រៃសម្បទានប្រហែលពុំអាចមានចំណេញទេក្នុងអត្រាកាប់ឈើទាបបែបនេះ ។ ដូចនាយកដ្ឋានរុក្ខាប្រមាញ់បានរំលេចនៅក្នុងឯកសារ ធ្វើផែន ការគ្រប់គ្រងព្រៃសម្បទាន (២000) "ការវិភាគសេដ្ឋកិច្ចបង្ហាញថា ប្រតិបត្តិការ កាប់ឈើជាលក្ខណៈពាណិជ្ជកម្មមិនអាចធានាបានទេនៅកំរិត ១0ម៉ែត្រគូប/ហិកតា នេះ" ។ ទោះបីសម្បទានិកអាចបានចំណេញគួរសមនៅក្នុងរបបទិន្នផល មានចីរភាព ក៏ដោយ ក៏ពួកគេមានគ្រឿងលើកទឹកចិត្តខាងហិរញ្ញវត្ថុធំណាស់ដែលជំរុញឱ្យកាប់ឈើតាមរបៀបអតិផលជាបន្តទៀត ពីព្រោះវិធីនេះបង្កើនកំរិតចំណេញលើទុនវិនិយោគ និងកាត់បន្ថយហានិភ័យ ។ គ្រឿងលើកទឹកចិត្តសំខាន់ៗមានពិពណ៌នាដូចខាងក្រោម:

### ***១. ការកាប់ឈើលឿន និងរបៀបអតិផលកាត់បន្ថយហានិភ័យរបស់សម្បទានិក ។***

ការកាប់ឈើពីសម្បទានរយៈ ២៥-៣0ឆ្នាំ តាមរបបទិន្នផលមានចីរភាព (ខុសពីការកាប់ឈើក្នុង ៥-១0ឆ្នាំ ដូចកំពុងអនុវត្តសព្វថ្ងៃ) ធ្វើឱ្យហានិភ័យចំពោះសម្បទានិកកើនខ្ពស់ណាស់ ។ នៅកម្ពុជា ហានិភ័យមានជាអាទិ ការកាប់ឈើខុសច្បាប់ដោយស្ថាប័នផ្សេងទៀត, ច្បាប់ព្រៃឈើតឹងតែងជាងមុន, ការបញ្ចប់កិច្ចសន្យា, ភាព មិនច្បាស់លាស់ខាងនយោបាយ, គ្រោះធម្មជាតិដូចជាជំងឺដើមឈើ, អគ្គីភ័យ, ទឹក ជំនន់... ដែលជំរុញឱ្យសម្បទានិកបន្តការកាប់ឈើក្នុងកំរិត ៤0-៥0ម៉ែត្រគូប/ហិកតា (មិនមែន ១0ម៉ែត្រគូប/ហិកតាទេ) ដោយសង្ឃឹមថា ក្នុង ២៥-៣0ឆ្នាំក្រោយមក នឹងអាចប្រមូលផលឈើជាលើកទី២ បាន ១0ម៉ែត្រគូប/ហិកតាទៀត ។

### ***២. អត្រាចំណេញប្រចាំឆ្នាំអាចឡើងខ្ពស់ខ្លាំងតាមការកាប់ឈើអតិផល ហើយអាចយកប្រាក់ចំណេញទៅវិនិយោគនៅកន្លែងផ្សេងទៀត ។***

ចំពោះសម្បទានិក អត្ថប្រយោជន៍នៃការផ្លាស់ប្តូរពីវិធីកាប់ឈើអតិផលមកវិធីទិន្នផលមានចីរភាពវិញ គឺការទុកព្រៃស្រោង ដែលមិនទាន់កាប់លក់ឱ្យលូតលាស់ និងកើនតំលៃតាមពេលវេលា ហើយអាចប្រមូលផលបានជា លើកទី២ ក្នុងរយៈពេល ២៥-៣0ឆ្នាំ ។ ដើម្បីវាយតំលៃពីកំរិតចំណេញប្រចាំឆ្នាំដែលជាប់ទាក់ទិននឹងការប្តូរមកអនុវត្តរបបទិន្នផលមានចីរភាព យើងអាចពិចារណាតាមសេណារីយ៉ូសាមញ្ញមួយដែលសម្បទានិកមានជំរើសពីរ: ក-កាប់ឈើមួយ ដើមនៅថ្ងៃនេះ និង ខ-

កាប់ឈើមួយដើមដដែលតែនៅ ៣០ឆ្នាំខាងមុខ ។ ក្នុងជំរើស "ក" ប្រាក់ចំណេញពីការកាប់ឈើលក់ភ្លាមៗអាចយកទៅវិនិយោគនៅកន្លែងផ្សេង ដើម្បីបានចំណេញប្រចាំឆ្នាំថែមទៀត ។ ជាការប្រៀបធៀបកំរិតចំណេញប្រចាំឆ្នាំនៃការរង់ចាំកាប់ឈើក្នុងជំរើស "ខ" គឺជាទំហំដើមឈើដែលកើនឡើងប្រចាំឆ្នាំបូកនឹងកំណើនពិត (កែតំរូវតាមអតិផរណា) នៃថ្លៃឈើនៅទីផ្សារ ។

សំរាប់ជំរើស "ខ" គេប៉ាន់ស្មានថា នៅកម្ពុជាព្រៃឈើលូតលាស់បានប្រហែល 0,៣៣ម៉ែត្រគូប/ហិកតា/ឆ្នាំ គឺទាបគួរឱ្យកត់សំគាល់បើធៀបនឹងឥណ្ឌូណេស៊ី (១,0ម៉ែត្រគូប/ហិកតា/ឆ្នាំ) និងម៉ាឡេស៊ី (១,0-១,៥ម៉ែត្រគូប/ហិកតា/ឆ្នាំ) (Koum 1992; World Bank *et al* 1996) ។ ផ្អែកតាមអត្រាលូតលាស់នេះ និងតាមតួលេខប៉ាន់ស្មាននៃឈើនៅកម្ពុជាដែលអាចកាប់លក់បានត្រឹមតែ ៣៣ម៉ែត្រគូប/ហិកតា, ដូច្នេះ ឈើកើនឡើងតាមអត្រាលូតលាស់ជាមធ្យមប្រហែល ១ភាគរយ/ហិកតា/ឆ្នាំ ។ ប៉ុន្តែត្រូវសំគាល់ថា តួលេខនេះគឺជាការប៉ាន់ស្មានច្បោលៗ ពីព្រោះវាប្រែប្រួលទៅតាមរបបគ្រប់គ្រងខុសៗគ្នា ហើយចំនួនពិតនៃឈើពាណិជ្ជកម្មមិនទាន់ដឹងទេ ដោយសារសម្បទានិកមិនទាន់ធ្វើផែនការគ្រប់គ្រងថ្មីរបស់ខ្លួន ។

ទិន្នន័យស្តីពីកំណើនថ្លៃឈើតំបន់ត្រូពិចមិនបានបង្ហាញនូវកំណើនតំលៃច្រើនទេ ក្នុងការអនុវត្តន៍របបទិន្នផលមានចីរភាព ។ ពីឆ្នាំ១៩៩៥ ដល់ ២000 កំណើន ថ្លៃពិតប្រចាំឆ្នាំនៃឈើតំបន់ត្រូពិចមានកំរិតពី 0,២% ដល់ ២,៧% ។ ក្នុងបួនទសវត្សន៍កន្លងទៅកំណើនថ្លៃពិតមានជាមធ្យមត្រឹម ១,២%ប៉ុណ្ណោះ (Rice *et al* 2001) ។ ដូច្នេះ ការគួបផ្សំរវាងអត្រាលូតលាស់ឈើយឺត និងកំណើនថ្លៃឈើយឺត បានផ្តល់អត្រាចំណេញប្រចាំឆ្នាំក្នុងជំរើស "ខ" ប្រហែល ២-៣% ។ ដោយសារនៅកម្ពុជា ការធ្វើអាជីវកម្មព្រៃសម្បទានមានហានិភ័យកំរិតខ្ពស់ ដូច្នេះសម្បទានិកយល់ថា ការកាប់ឈើតាមរបៀបទិន្នផលមានចីរភាព ដោយបានចំណេញ ២-៣%ក្នុងមួយឆ្នាំ មិនមែនជាគំនិតល្អទេ ។

**ក្នុងឆ្នាំ១៩៩៦ ធនាគារពិភពលោក, UNDP, FAO, បានប៉ាន់ស្មានថា ចំណូលរដ្ឋពីព្រៃឈើអាចបានលើសពី ១00លានដុល្លារ/ឆ្នាំ ។ ក្រោយមកទៀត ធនាគារពិភពលោកបានកែបញ្ចុះតួលេខមកត្រឹម ៤0-៨0លានដុល្លារក្នុងមួយឆ្នាំវិញ ។ តាំងពីឆ្នាំ១៩៩៦ ចំណូលរដ្ឋ ពីព្រៃឈើបានពី ៦-១២លានដុល្លារ ។**

ជំរើស "ក" មានចំណេញខាងហិរញ្ញវត្ថុច្រើនជាងជំរើស "ខ" ពីព្រោះប្រាក់ចំណេញបានពីការកាប់យកឈើភ្លាមៗ គឺអាចយកទៅវិនិយោគបានចំណេញកាន់តែ ច្រើនឡើង ។ ឧទាហរណ៍ វិនិយោគនៅកម្ពុជាតែងផ្តល់ចំណេញប្រចាំឆ្នាំយ៉ាងតិច ១៥-២0% (ដូចអាចពិនិត្យឃើញតាមអត្រាការប្រាក់នៅកម្ពុជា) ។ ដូច្នេះហើយ ធៀបនឹងការអនុវត្តន៍របបទិន្នផលមានចីរភាពដែលមានកំរិតចំណេញប្រចាំឆ្នាំទាប និងហានិភ័យខ្ពស់, សម្បទានិកមានការលើកទឹកចិត្តខាងហិរញ្ញវត្ថុយ៉ាងច្រើន ក្នុងការបន្តកាប់ឈើឱ្យបានច្រើន និងឱ្យបានឆាប់បំផុតតាមអាចធ្វើបាន ។

### *៣. សមត្ថភាពកែច្នៃឈើដែលសម្បទានិកបានដាក់ទុនវិនិយោគរួចហើយ អាចប្រើមិនអស់លទ្ធភាព បើសិន SFM កាត់បន្ថយឈើកាប់ ។*

ការបូកសរុបពីព្រៃសម្បទានកម្ពុជា (២000) បានប៉ាន់ស្មានថា សមត្ថភាពកែឆ្នៃឈើនៅកម្ពុជាក្នុងពេលសព្វថ្ងៃគឺប្រហែល ១,២-២,0លានម៉ែត្រគូបក្នុងមួយឆ្នាំ ។ សមត្ថភាពកែច្នៃនេះ វាខ្ពស់ច្រើនជាងកំរិតកាប់ឈើមានចីរភាពត្រឹម 0,៥-១,0 លានម៉ែត្រគូបក្នុងមួយឆ្នាំ ។ ដោយអត្រាចំណេញពីទុនវិនិយោគលើសមត្ថភាពកែច្នៃឈើ ត្រូវកើនខ្ពស់តាមកំរិតប្រើប្រាស់ខ្លាំងនូវសមត្ថភាពនេះ (កំណើនឈើយកមកកែច្នៃ) ដូច្នេះការអនុវត្តន៍ SFM ដែលនាំដល់ការកាត់បន្ថយបរិមាណឈើកាប់ នឹងធ្វើឱ្យការប្រើប្រាស់សមត្ថភាពកែច្នៃថយចុះ ហើយកំរិតចំណេញលើទុនវិនិយោគជាប់លាប់ក៏ថយចុះដែរ ។

**តារាង១. ចំណូលព្រៃឈើដល់ថវិការដ្ឋ និងកំរិតចំណេញសុទ្ធជាមធ្យមរបស់សម្បទានិក (១៩៩៦-២00១)**

| ឆ្នាំ | ចំណូលព្រៃឈើដល់ថវិការដ្ឋ (លានដុល្លារ) | ចំណេញសុទ្ធរបស់សម្បទានិកមុនពេលបង់សួយ និងពន្ធនាំចេញ (ដុល្លារ/ម៉ែត្រគូបឈើមូល) |
|---|---|---|
| 1996 | 10 | គ្មានតួលេខ |
| 1997 | 12 | -17.34 |
| 1998 | 6 | -49.53 |
| 1999 | 10 | 7.73 |
| 2000 | 11 | គ្មានតួលេខ |
| 2001 | 7* | គ្មានតួលេខ |

* មកដល់ខែតុលា ២00១ ។ ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, និង KPMG (2001), *(ពង្រាង) លក្ខណៈស្មើភាពនៃប្រព័ន្ធយកពន្ធព្រៃឈើនៅកម្ពុជា ។*

## ស្ថានភាពពិតនៃប្រព័ន្ធសម្បទាន

ដោយសារមានការបង្អាក់ទឹកចិត្តខាងហិរញ្ញវត្ថុ ធំធេងបែបនេះ ការដែលសម្បទានិកមិនបានធ្វើ ផែនការគ្រប់គ្រងមានចីរភាព និងធ្វើកំណែទំរង់របៀបរបបអនុវត្តន៍របស់ខ្លួន គឺគ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ។ ទៅអនាគត ការគ្រប់គ្រងព្រៃឈើនៅកម្ពុជា អាចមាន SFM ឬប្រព័ន្ធសម្បទានបច្ចុប្បន្ន ប៉ុន្តែការគួបផ្សំរវាងវិធីទាំងពីរដែលគេស្វែងរកយូរមកហើយប្រហែលធ្វើមិនកើតទេ ពីព្រោះវិធីទាំងពីរហាក់ដូចប្រឆាំងគ្នាទាំងស្រុង ។ ដូច្នេះ គេគួរពិនិត្យឱ្យបានដិតដល់ពីប្រសិទ្ធិភាពនៃប្រព័ន្ធសម្បទានបច្ចុប្បន្ន (ដែលគ្មានចីរភាព) ក្នុងការដោះស្រាយគោលដៅខាងអភិវឌ្ឍន៍ ដើម្បីកំណត់ថា តើលទ្ធផលដែលទទួលបានវាសមរម្យគួរអនុវត្តរបបនេះតទៅអនាគតដែរឬទេ ។

គោលដៅចំបងមួយនៃការកសាងប្រព័ន្ធសម្បទាននៅក្នុងប្រទេសកម្ពុជាគឺការបង្កើតចំណូលរដ្ឋ ដែលគេអាចយកទៅប្រើប្រាស់ក្នុងគោលដៅអភិវឌ្ឍន៍ ។ ដូចបានលើកឡើងហើយ ក្នុងឆ្នាំ១៩៩៦ ធនាគារពិភពលោក, UNDP, FAO, បានប៉ាន់ស្មានថា ចំណូលរដ្ឋពីព្រៃឈើអាចបានលើសពី ១00 លានដុល្លារ/ឆ្នាំ ។ ក្រោយមកទៀត ធនាគារពិភពលោកបានកែបញ្ចុះតួលេខមកត្រឹម ៤0-៨0លានដុល្លារក្នុងមួយឆ្នាំវិញ ។ តាំងពីឆ្នាំ១៩៩៦ (ដែលមានការព្យាករណ៍ចំណូលថវិកាជាលើកដំបូង) ចំណូលរដ្ឋពីព្រៃឈើបានពី ៦-១២លានដុល្លារ (តារាង១) ។ ឥឡូវនេះ គេឃើញមានទាយកជាច្រើនបានទទួលស្គាល់រៀងៗខ្លួនថា វិស័យព្រៃឈើប្រហែលមិនអាចផ្តល់ចំណូលថវិការដ្ឋបានជាដុំកំភួននោះទេ ។ គេគួរកត់សំគាល់ដែរថា បើសិនរបប SFM ត្រូវបានអនុវត្ត ឈើកាប់អាចតិចជាងក្នុងបណ្តាឆ្នាំកន្លងមកដែលធ្វើឱ្យចំណូលរដ្ឋជាសួយ និងពន្ធនាំចេញរឹតតែថយចុះថែមទៀត ។

តាមពង្រាងឯកសារសិក្សាមួយរៀបចំឡើងក្នុងឆ្នាំ២00១ ដោយក្រុមហ៊ុនគណនេយ្យ KPMG, ប្រព័ន្ធសម្បទានមិនទាន់ផ្តល់ចំណេញឱ្យសម្បទានិកនៅឡើយទេ (តារាង១) ។ ដោយបានជំនួយពី CTIA, ក្រុមហ៊ុន KPMG បានប្រមូលទិន្នន័យដើមពីប្រាំសម្បទានិកដែលតំណាងឱ្យអាជីពនេះ ដើម្បីវាយតំលៃពីកំរិតចំណេញមធ្យម និងលទ្ធភាពក្នុងការបង់សួយ និងពន្ធនាំចេញ ។ សម្បទានទាំងនេះតំណាងឱ្យ ៤0% នៃផ្ទៃដីសរុបដែលស្ថិតក្រោមរបបព្រៃសម្បទាន ។ KPMG បានសន្និដ្ឋានថា "ក្នុង ៣ឆ្នាំកន្លងទៅ (១៩៩៧-៩៩) អ្នកផលិតឈើកម្ពុជាជាមធ្យមមិនទាន់បានចំណេញវិជ្ជ

មានសុទ្ធក្នុងកំរិតគួរឱ្យកត់សំគាល់នៅឡើយទេ ហើយក៏មិនដែលសំរេចបានសោះដែរ នូវកំរិតចំណេញដ៏សមរម្យមួយដូចការរពឹងទុក"។ KPMG បានលើកឡើងថា "លទ្ធផលយ៉ាប់យ៉ឺនបំផុត" របស់សម្បទានិកសឹងតែគ្មានបន្សល់ចំណេញអ្វីសោះសំរាប់ការបង់សួយ និងពន្ធនាំចេញជូនរដ្ឋ ។ មានតែក្នុងឆ្នាំ១៩៩៩ ទេ ដែលក្រុមហ៊ុនជាមធ្យម សំរេចបាននូវចំណេញជាវិជ្ជមានតូចមួយ ហើយវាមិនទាន់ទាំងបានកាត់ចេញនូវបន្ទុកសួយ និងពន្ធនាំចេញផង ។ ដូច្នេះ ក្នុងឆ្នាំនិមួយៗ ដែល KPMG បានសិក្សាគឺគ្មានសល់អ្វីសោះសំរាប់យកទៅបង់សួយ ឬបង់ពន្ធ ។

ក្រៅពីបរាជ័យនៃការបង្កើតចំណូលរដ្ឋ និងប្រាក់ចំណេញដល់ក្រុមហ៊ុន (ដែលគេអាចមើលឃើញយ៉ាងច្បាស់) នៅមានបញ្ហាធ្ងន់ធ្ងរជាច្រើនទៀតទាក់ទិននឹងប្រព័ន្ធសម្បទានដែលគេបានយកចិត្តទុកដាក់តែពុំបានលើកយកមកពិភាក្សាក្នុងអត្ថបទនេះ គឺមានជាអាទិ:

១. ផលប៉ះពាល់ដល់ជីវភាពនៅជនបទដោយសារការថយចុះនូវលទ្ធភាពប្រើប្រាស់ធនធានព្រៃឈើ
២. ទំនាស់រវាងសម្បទានិក និងសហគមន៍មូលដ្ឋាន
៣. ការបាត់បង់ និងការខូចខាតព្រៃឈើយ៉ាងធ្ងន់ធ្ងរដែលបង្កឱ្យមានការបាត់បង់ជីវចំរុះ កំណើនទឹកជំនន់ ការហូរច្រោះខូចដី និងការដុះដីល្បប់យ៉ាងច្រើនដែល ប៉ះពាល់មិនល្អដល់មច្ឆាជាតិ ។

## ជំរើសផ្សេងទៀតសំរាប់ការគ្រប់គ្រងព្រៃឈើ

កម្ពុជាមិនមែនជាប្រទេសទីមួយដែលជួបការលំបាកក្នុងការអនុវត្តន៍ការគ្រប់គ្រងព្រៃសម្បទានមានចីរភាពនោះទេ ។ នៅក្នុងពិភពលោក ប្រទេសជាច្រើន ដែលមានឧស្សាហកម្ម និងមានប្រព័ន្ធច្បាប់គ្រប់គ្រងអាជីវកម្មឈើ មានកំរិតលូត លាស់ និងមានលក្ខណៈរឹងមាំជាងកម្ពុជា ក៏នៅតែបរាជ័យក្នុងការដាក់អនុវត្តន៍ SFM ទោះបីបានខំប្រឹងប្រែងអស់ជាង ២០ឆ្នាំ និងបានចំណាយទុនវិនិយោគ និងជំនួយអភិវឌ្ឍន៍អស់ច្រើនរយលានដុល្លារក៏ដោយ ។ នៅក្នុងទំហំព្រៃឈើធម្មជាតិតំបន់ក្តៅ ប្រមាណ ១,៧ពាន់លានហិកតានៅក្នុងពិភពលោក មានតែ ១,១លានហិកតាប៉ុណ្ណោះ ដែលគ្រប់គ្រងតាមរបប SFM (Rice *et al* 2001) ។

> **ក្នុងពិភពលោក ប្រទេសជាច្រើនដែលមានឧស្សាហកម្ម និងមានប្រព័ន្ធច្បាប់គ្រប់គ្រងអាជីវកម្មឈើមានកំរិតលូតលាស់ និងមានលក្ខណៈរឹងមាំជាងកម្ពុជា ក៏គេនៅតែបរាជ័យក្នុងការដាក់អនុវត្តន៍ SFM ទោះបីបានខំប្រឹងប្រែងអស់ជាង ២០ឆ្នាំ ហើយបានចំណាយទុនវិនិយោគ និងជំនួយអភិវឌ្ឍន៍អស់ច្រើនរយលានដុល្លារក៏ដោយ ។**

គ្រឿងបង្អាក់ចិត្តខាងហិរញ្ញវត្ថុផ្សេងៗចំពោះសម្បទានិកក្នុងការទទួលយក SFM, បានផ្តល់គំនិតថា ការប្រឹងប្រែងធ្វើកំណែទំរង់ប្រហែលមិនអាចសំរេចបានទេ នូវគោលដៅនានានៃ ការគ្រប់គ្រងព្រៃឈើ ការបង្កើតចំណូល និងការអភិវឌ្ឍន៍តាមវិស័យ ដែលគេបានគ្រោងសំរាប់វិស័យព្រៃឈើនៅកម្ពុជា ។ សព្វថ្ងៃមានតំរូវការយ៉ាងខ្លាំងនូវការស្រាវជ្រាវពីវិធីផ្សេងទៀតនៃការគ្រប់គ្រងព្រៃឈើ ក្រៅពីប្រព័ន្ធសម្បទាន ដើម្បីឱ្យប្រជាជនជំនាន់ក្រោយអាចបានទទួលអត្ថប្រយោជន៍ពីធនធានព្រៃឈើកម្ពុជាផងដែរ ។ ការវាយតំលៃលំអិតពីជំរើសនានានៃការគ្រប់គ្រងព្រៃឈើ វាមិនមែនជាកម្មវត្ថុនៃអត្ថបទនេះទេ ប៉ុន្តែគំនិតខ្លះៗស្តីពីលទ្ធភាពកំណត់ឡើងវិញនូវចំណុចផ្តោតនៃការប្រឹងប្រែងធ្វើកំណែទំរង់ព្រៃឈើមានដូចតទៅ:

### *១. ទទួលស្គាល់ថា គំរូអភិវឌ្ឍន៍ព្រៃសម្បទាន ដែលក្នុងនេះ ចំណូលព្រៃឈើហូរចូលថវិការដ្ឋ រួចហូរត្រឡប់ទៅតំបន់ជនបទវិញដើម្បីបំរើគោលដៅអភិវឌ្ឍន៍បានទទួលបរាជ័យហើយ ។*

ចំណូលថវិការដ្ឋបានពីព្រៃសម្បទានមានតិចតួចណាស់ ហើយប្រព័ន្ធសម្បទានបានប៉ះពាល់មិនល្អ ចំពោះជីវភាពនៅជនបទ ដោយកាត់បន្ថយលទ្ធភាពចេញចូល និងប្រើប្រាស់ធនធានព្រៃឈើ ។ ការកែលំអកំរិតជីវភាពនៅជនបទគឺជាគោលដៅអភិវឌ្ឍន៍ដ៏ចំបងមួយរបស់រដ្ឋាភិបាល ដូច្នេះត្រូវតែសិក្សាស្រាវជ្រាវពីវិធីសាស្ត្រគ្រប់គ្រងព្រៃឈើ ដើម្បីស្វែងរកវិធីដែលបង្កើនអត្ថប្រយោជន៍ធនធានព្រៃឈើចំពោះប្រជាជននៅជនបទ ។ ឧទាហរណ៍ ចំពោះកន្លែងណាដែលជីវភាពនៅជនបទពឹងផ្អែកលើការយកជ័រ និងការលក់ជ័រ រដ្ឋាភិបាលអាចជួយទ្រទ្រង់ដល់រចនាសម្ព័ន្ធគ្រប់គ្រងព្រៃឈើនៅមូលដ្ឋានដើម្បីការពារដើមឈើយកជ័រ និងព្រៃ នៅជុំវិញ, លុបចោលឧបសគ្គផ្សេងៗចំពោះ ពាណិជ្ជកម្មដូចជា លិខិតអនុញ្ញាតឱ្យដឹកជញ្ជូនជា ដើម និងជួយរកទីផ្សារនាំចេញ ។

### *២. បញ្ចប់សម្បទាននានាដែលពុំមានឈើពាណិជ្ជកម្មអាចធានាឱ្យអាជីវកម្មរស់បាន ឬដែលសម្បទានិកបានរំលោភច្រើនលើកច្រើនសានូវលក្ខខណ្ឌនៃកិច្ចសន្យាសម្បទានព្រៃឈើ ឬបទប្បញ្ញត្តិផ្សេងៗនៅក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន ។*

ការបញ្ចប់កិច្ចសន្យាអាចចាប់ផ្តើមធ្វើចំពោះសម្បទាន ៨ ដែលឯកសារបូកសរុបព្រៃសម្បទានកម្ពុជា (២000) បានរកឃើញថា ប្រហែលមិនអាចធ្វើផែនការគ្រប់គ្រងធានាដល់ការរស់រាននៃអាជីវកម្មបាន ដោយសារ "ស្ថានភាពខូចខាតយ៉ាងធ្ងន់ធ្ងរនៃធនធានព្រៃឈើនៅក្នុងតំបន់សម្បទាន" ។ មានលេចឮពីការព្រួយបារម្ភជាច្រើន ពីហេតុបច្ច័យខាងផ្លូវច្បាប់នៃការបញ្ចប់ជាឯកតោភាគីនូវកិច្ចសន្យាសម្បទាន ប៉ុន្តែការព្រួយបារម្ភនេះហាក់ដូចបំផ្លើសពេកហើយ ។ ទីមួយ ក្នុងឆ្នាំ១៩៩៩ រដ្ឋាភិបាលបានលុបចោលនូវសម្បទាន ១២ និងតំលើងសួយជាឯកតោភាគីពី ១៤ដុល្លារ ដល់ ៥៤ដុល្លារ ក្នុងមួយម៉ែត្រគូប ដោយពុំមានការប្តឹងផ្តល់ពីសម្បទានិកទេ ។ ទីពីរ រដ្ឋាភិបាលហាក់ដូចមានមូលដ្ឋានផ្លូវច្បាប់រឹងមាំដើម្បីបញ្ចប់កិច្ចសន្យា ។ ដូចមានចុះនៅក្នុង*ឯកសារបូកសរុបព្រៃសម្បទាននៅកម្ពុជា*(២000):

> *គ្មានសម្បទានណាមួយដែលគោរពបាននូវលក្ខខណ្ឌនានាស្តីពី: លទ្ធភាពបង្ហាញថាខ្លួនបំពេញបាននូវកាតព្វកិច្ចខាងវិនិយោគរបស់ខ្លួន, ការបង់សួយ, របាយការណ៍គណនេយ្យប្រចាំឆ្នាំ... ។ គុណភាពអន់បំផុតនៃផែនការគ្រប់គ្រងបច្ចុប្បន្ន, កង្វះខាតធ្ងន់ធ្ងរនូវសមត្ថភាពបច្ចេកទេសនៃសម្បទានិកជាច្រើន, កង្វះទាំងស្រុងនូវការវាយតំលៃធនធាន, ការតាមដាន និងការធ្វើផែនការប្រតិបត្តិការដាំព្រៃឈើ, ហេដ្ឋារចនាសម្ព័ន្ធយ៉ាប់យ៉ឺនបំផុតនៅក្នុងសម្បទានភាគច្រើន, ការមិនយកចិត្តទុកដាក់ដល់សហគមន៍ និងការអភិវឌ្ឍន៍សហគមន៍, ទាំងអស់នេះគឺជាភស្តុតាងដ៏ច្បាស់ថា សម្បទានិកមិនបានប្រតិបត្តិតាមការព្រមព្រៀងក្នុងកិច្ចសន្យាទេ ។ លើសពីនេះទៀត មានតិចករណីណាស់ដែលសម្បទានិកបានរាយការណ៍ពីការកាប់ឈើខុសច្បាប់ដល់អាជ្ញាធរ ។*

សំខាន់បំផុត រដ្ឋាភិបាលមានការទទួលខុសត្រូវដាច់ខាតក្នុងការគ្រប់គ្រងធនធានព្រៃឈើរបស់ជាតិ ។ ពិតមែនហើយ រដ្ឋាភិបាលបានផ្តល់សិទ្ធិជាដៃគូដល់សម្បទានិក

ក្នុងការគ្រប់គ្រងព្រៃឈើ ប៉ុន្តែក្នុងករណីសម្បទានិកគ្រប់គ្រងព្រៃឈើដោយគ្មានការទទួលខុសត្រូវភាពជាដៃគូនេះត្រូវតែពិចារណាឡើងវិញ ។ ដូច*ឯកសារបូកសរុបព្រៃសម្បទាននៅកម្ពុជា* (២000) បានផ្តល់មតិ "ពុំមានភាពមិនសមរម្យណាមួយនៅក្នុងកិច្ចព្រមព្រៀង ឬការរំលោភបំពានមានភស្តុតាងបញ្ជាក់ណាមួយ ដែលអាចរារាំងរដ្ឋាភិបាលក្នុងការចាត់វិធានការការពារធនធានរបស់ជាតិ ។ ព្រៃឈើនៅតែជាធនធានមួយដែលសំខាន់ដល់អាយុជីវិត ហើយរដ្ឋាភិបាលរក្សាទុកជានិច្ចនូវសិទ្ធិអំណាចក្នុងការញ៉ាំងឱ្យមានការគ្រប់គ្រងព្រៃឈើយ៉ាងសក្តិសិទ្ធិ" ។

***៣. កំណត់តំបន់ព្រៃឈើសំរាប់ទុកព្រៃត្រូវការពារទាំងស្រុង ក្នុងករណីដែលជីវចំរុះ, តំបន់រងទឹកភ្លៀង, កិច្ចអភិរក្ស និង/ឬ សក្តានុពលខាងអេកូទេសចរណ៍ត្រូវបានសំគាល់ថា មានសារៈសំខាន់ ។***

រដ្ឋាភិបាលឈានទៅមុខបានច្រើនដំណាក់ហើយក្នុងការកសាង "ព្រៃបំរុង" នៅក្នុងជួរភ្នំក្រវាញកណ្តាល ទោះបីតំបន់នេះភាគច្រើនស្ថិតនៅក្រោមសម្បទានខុសៗគ្នាក៏ដោយ ។ សកម្មភាពនេះជាការទទួលស្គាល់ជាក់ស្តែងថា សម្បទានិកគ្មានសមត្ថភាពអនុវត្ត SFM ដើម្បីការពារតំលៃផ្សេងៗខាងបរិស្ថានទេ ។ នៅក្នុងតំបន់សម្បទានឯទៀត កាលណាតំលៃខាងបរិស្ថាន ត្រូវបានចាត់ទុកថាមានសារៈសំខាន់ខ្លាំង គួរអនុវត្តវិធានការដូចគ្នាដើម្បីកំណត់ព្រៃបំរុង ។ វិធានការការពារទាំងនេះ ប្រហែលមានប្រសិទ្ធិភាពខ្ពស់ជាងវិធីប្រគល់ឱ្យសម្បទានិកនូវការទទួលខុសត្រូវក្នុងការការពារព្រៃឈើនៅក្រោមរបបកំណែទំរង់ SFM ដែលបានស្នើឡើង ។

**ជាជាងបន្តប្រើប្រាស់មូលនិធិ និងសមត្ថភាពដែលមានយ៉ាងកំរ (សំរាប់ការគ្រប់គ្រងព្រៃឈើ) ទៅលើការកសាង SFM នៅក្នុងសម្បទាននានា ធនធានរបស់រដ្ឋាភិបាល និងរបស់ទាយកគួរបង្វែរទៅចំណាយលើការ សិក្សាស្រាវជ្រាវ និង-ការកសាងបែបបទគ្រប់គ្រងព្រៃឈើមួយបែប ផ្សេងទៀតសំរាប់ជំនួស**

***៤. បង្កើនធនធានសំរាប់ការកសាង និងការដាក់សាកល្បងនូវគំរូគ្រប់គ្រង "ព្រៃឈើសហគមន៍"***

ដោយធនធានមួយភាគធំប្រមូលផ្តុំលើការអភិវឌ្ឍន៍ និងកំណែទំរង់ប្រព័ន្ធព្រៃសម្បទាន, ដូច្នេះរបបព្រៃឈើសហគមន៍មិនសូវបានគេយកចិត្តទុកដាក់ទេនៅក្នុងប្រទេសកម្ពុជា ។ ឧទាហរណ៍ របាយការណ៍ធនាគារពិភពលោកដ៏មានឥទ្ធិពល "*ប្រទេសកម្ពុជា: ចក្ខុវិស័យសំរាប់ការអភិវឌ្ឍន៍វិស័យព្រៃឈើ*" (១៩៩៩) បានអំពាវនាវឱ្យមានវិស័យព្រៃឈើមួយដែលក្នុងនោះ ព្រៃឈើ "ក្រាស់គួរសម" ទុកសំរាប់ផលិតកម្មជាលក្ខណៈពាណិជ្ជកម្ម ឯ "ព្រៃតូចៗ និងឈើដុះរាយប៉ាយ" ទុកឱ្យសហគមន៍មូលដ្ឋានគ្រប់គ្រង ។ គេត្រូវទទួលស្គាល់ "ព្រៃឈើសហគមន៍" ថា ជាមធ្យោបាយមួយដើម្បីសំរេចបានការគ្រប់គ្រងមានចីរភាពនូវធនធានព្រៃឈើធំៗដែលមិនសមស្របសំរាប់ផលិតកម្មជាលក្ខណៈពាណិជ្ជកម្ម ឬដែលនៅក្រៅលទ្ធភាពគ្រប់គ្រងផ្ទាល់ពីសំណាក់រដ្ឋាភិបាល" ។ ចក្ខុវិស័យនេះ មិនបានផ្តល់មតិថា តើសហគមន៍នានាដែលរស់នៅក្នុង ឬនៅជាប់នឹងព្រៃឈើមានតំលៃខាងពាណិជ្ជកម្ម គួរមានសិទ្ធិជាអាទិភាពឬទេក្នុងការទាញយកអត្ថប្រយោជន៍ពីធនធានទាំងនេះ ឬក៏ថាតើសហគមន៍មានចំណូលចិត្តប៉ុណ្ណាក្នុងការគ្រប់គ្រងព្រៃឈើដែលមានតំលៃទាប ឬខូចខាតស្រាប់បែបនេះ ។លើសពីនេះទៀត ក្នុង "សកម្មភាពជាអាទិភាព" នានាដែលមានចុះក្នុងរបាយការណ៍ គ្មានមួយណាសោះដែលលើកថាការងារអភិវឌ្ឍន៍ការគ្រប់គ្រងព្រៃឈើសហគមន៍ គឺជាអាទិភាពមួយសំរាប់ការជួយទ្រទ្រង់ពីទាយក ។

ក្នុងពេលថ្មីៗនេះទៀត ព្រៃឈើសហគមន៍បានទទួលការយកចិត្តទុកដាក់ច្រើនខ្លាំងណាស់ ក្នុងលក្ខណៈជាមធ្យោបាយសំរាប់ជំនួស (ឬបំពេញបន្ថែម) នូវការគ្រប់គ្រងព្រៃសម្បទាន ។ សញ្ញានានានៃកំណើនការគាំទ្រដល់គំនិតនេះ មានជាអាទិ ការធ្វើសិក្ខាសាលាកំរិតជាតិស្តីពីព្រៃឈើសហគមន៍ក្នុងឆ្នាំ ២០០១, ជំនួយទ្រទ្រង់កាន់តែធំឡើងចំពោះគំរោងព្រៃឈើសហគមន៍ផ្សេងៗ, និងដំណើរការទៅមុខនៃការតាក់តែងអនុក្រឹត្យស្តីពីព្រៃសហគមន៍ ។ ដោយហេតុថា ព្រៃសហគមន៍មិនទាន់បានឆ្លងកាត់ការសាកល្បងក្នុងលក្ខណៈជាឧបករណ៍ផ្លូវការសំរាប់ការគ្រប់គ្រងព្រៃឈើនៅកម្ពុជា ដូច្នេះត្រូវសិក្សារៀនសូត្រច្រើនថែមទៀតពីបែបបទដែលព្រៃឈើសហគមន៍អាចមានតួនាទីសំខាន់នៅក្នុង ការងារគ្រប់គ្រងព្រៃឈើ ហើយដែលក្នុងនេះ គេត្រូវបង្កើនជំនួយទ្រទ្រង់ ការអភិវឌ្ឍន៍បន្ថែម និងការពិសោធន៍ជាក់ស្តែង ។

## សេចក្តីសន្និដ្ឋាន

តាំងពីឆ្នាំ១៩៩៦ មក កំណែទំរង់វិស័យព្រៃឈើនៅកម្ពុជាបានផ្តោតលើការកសាងប្រព័ន្ធគ្រប់គ្រងព្រៃសម្បទានមានចីរភាព ។ ប៉ុន្តែការប្រឹងប្រែងនេះបានបរាជ័យ និងបន្តទទួលបរាជ័យ ដោយសារសម្បទានិកមានការលើកទឹកចិត្តខាងហិរញ្ញវត្ថុច្រើន ដែលជំរុញឱ្យជៀសវាងការអនុវត្តន៍របប SFM ។ ទោះបីសមត្ថភាពរដ្ឋាភិបាល ក្នុងការ តាមដាន និងដាក់អនុវត្តយ៉ាងតឹងរ៉ឹងនូវ SFM អាចកសាងបានយ៉ាងឆាប់ក៏ដោយ ក៏ SFM នឹងញ៉ាំងឱ្យព្រៃសម្បទានដល់ទីបញ្ចប់ដដែល ពីព្រោះវាត្រូវប៉ះពាល់អវិជ្ជមានទៅលើកំរិតចំណេញនៃសម្បទាន ។

ហេតុផលគាំទ្រដល់ការរក្សាទុកនូវប្រព័ន្ធព្រៃសម្បទានបច្ចុប្បន្ន ហាក់ដូចមានតិចតួចទេ ។ បញ្ហាជាច្រើនទាក់ទិននឹងការបង្កើតចំណូលរដ្ឋ កំរិតចំណេញនៃសម្បទាន ការបាត់បង់ឬខូចខាតព្រៃឈើ និងផលប៉ះពាល់ផ្សេងៗខាងសង្គមកិច្ច និងបរិស្ថាន គឺជាភស្តុតាងបញ្ជាក់ថា ប្រព័ន្ធសម្បទានសំរេចលទ្ធផលបានតិចណាស់ ធៀបនឹងគោលដៅនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ព្រៃឈើ ។ ដូច្នេះ ជាជាងបន្តប្រើប្រាស់មូលនិធិ និងសមត្ថភាពដែលមានយ៉ាងកំរ (សំរាប់ការគ្រប់គ្រងព្រៃឈើ) ទៅលើការកសាង SFM នៅក្នុងសម្បទាននានា, ធនធានរបស់រដ្ឋាភិបាល និងរបស់ទាយក គួរបង្វែរទៅចំណាយលើការសិក្សាស្រាវជ្រាវ និងការកសាងបែបបទគ្រប់គ្រងព្រៃឈើមួយបែបផ្សេងទៀតសំរាប់ជំនួសឱ្យប្រព័ន្ធសម្បទាននេះ ។

## កំណត់សំគាល់

១. ព្រៃគុបគឺជាដីព្រៃសំរាប់កាប់ឈើមួយកន្លែងដែលមានព្រំប្រទល់ភូមិសាស្ត្រកំណត់ច្បាស់លាស់ ហើយដែលជាមូលដ្ឋាននៃការធ្វើអាជីវកម្មក្នុងមួយឆ្នាំៗ ដូចមានចែងនៅក្នុងផែនការគ្រប់គ្រងព្រៃសម្បទាន និងផែនការប្រតិបត្តិការប្រចាំឆ្នាំ ។

២. នាយកដ្ឋានរុក្ខាប្រមាញ់បញ្ជាក់ថា មានឈើប្រភេទពាណិជ្ជកម្មជាង ៧០មុខ ប៉ុន្តែក្នុងនេះមានតែ ៤-៥ប្រភេទប៉ុណ្ណោះ ដែលសម្បទានិកសំគាល់ថាជាប្រភេទពាណិជ្ជកម្ម និងកាប់យកធ្វើអាជីវកម្ម ។

៣. ការប៉ាន់ស្មានដែលកាន់តែមានប្រយោជន៍សំរាប់ធ្វើវិភាគពីការគ្រប់គ្រងព្រៃឈើ នៅកម្ពុជា គឺអត្រាលូតលាស់គិតតាមរបបកាប់ព្រៃខុសៗគ្នា ។ ក្នុងពេលបច្ចុប្បន្ន មិនទាន់មានការសិក្សាបែបនេះនៅឡើយទេនៅកម្ពុជា ។

៤. ការធ្វើសារពើភ័ណ្ឌដល់កន្លែងក្នុងទសវត្សរ៍១៩៦០ និង ១៩៧០ បានបង្ហាញថា បរិមាណមធ្យមនៃឈើអាចកាប់លក់បានក្នុងព្រៃស្រោង គឺ ៨០ម៉ែត្រគូប/ហិកតា (FAO 1962 and Legris and Blanco 1972 cited in World Bank *et al* 1996) ។ ការរកឃើញក្នុងពេលថ្មីៗបានបង្ហាញពីការថយចុះគួរឱ្យកត់សំគាល់នូវចំនួនឈើដែលអាចលក់ដូរបាន (៣២,៩ម៉ែត្រគូប ដោយមានបំរែបំរួលយ៉ាងធំពី ១០,៨ ដល់ ៦៣,៩ ម៉ែត្រគូប: Fraser Thomas 2000 cited in DFW 2000) ។

៥. លទ្ធភាពមួយទៀតគឺ ប្រាក់ចំណេញក្នុងជំរើស "ក" អាចយកទៅវិនិយោគបានចំណេញស្មើគ្នានឹងជំរើស "ខ" ប៉ុន្តែមានកំរិតហានិភ័យទាបជាងច្រើនណាស់ (ឧទាហរណ៍ វិនិយោគលើប័ណ្ណរតនាគារអាមេរិក ដែលសឹងតែគ្មានហានិភ័យអ្វីសោះ ហើយដែលផ្ដល់ចំនេញពី ៣-៥%) ។

៦. "ព្រៃឈើសហគមន៍" គឺជាតំបន់មួយនៃ "ព្រៃរដ្ឋ" ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងគ្រប់គ្រងនិងប្រើប្រាស់ព្រៃឈើតាមបែបបទមានចីរភាព រវាងប្រធានរដ្ឋបាលព្រៃឈើក្នុងតំបន់ និងសហគមន៍នៅមូលដ្ឋាន ឬ ប្រជាជនចងក្រងគ្នាជាក្រុមជាក់លាក់ដែលរស់នៅក្នុង ឬនៅជិតតំបន់ព្រៃ ហើយពឹងផ្អែកលើព្រៃឈើសំរាប់ការ រកចិញ្ចឹមជីវិត ឬការប្រើប្រាស់តាមទំលាប់" (សេចក្ដី ព្រាងច្បាប់ព្រៃឈើ ចុះថ្ងៃទី ២០ កក្កដា ២០០១) ។

## ឯកសារយោង


Associates for Rural Development (1998), "Proceeds of Meeting to Brief the International Community and Senior Officials of the Royal Government of Cambodia on Forest Policy Reform" (Phnom Penh: Fortech Presentation).

Chan S., S. Tep, and S. Acharya (2001), *Land Tenure in Cambodia: A Data Update* (Phnom Penh: CDRI) Working Paper No. 19

DAI (Development Alternative Inc.) (1998), *Findings and Recommendations of the Log Monitoring and Log Control Project: Main Report* (Bethesda, MD: Submitted to the Ministry of Agriculture, Forestry and Fisheries, Royal Government of Cambodia).



# ឯកសារចេញផ្សាយថ្មីៗ

ចាប់តាំងពីខែតុលា ឆ្នាំ២០០១ មក វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) បានបោះពុម្ពផ្សាយនូវឯកសារស្រាវជ្រាវថ្មីៗមួយចំនួនដូចខាងក្រោម:

ឯកសារពិភាក្សាលេខ ១៩: **ការកាន់កាប់ដីធ្លីនៅក្នុងប្រទេសកម្ពុជា**

(ជាភាសាអង់គ្លេស ១០ដុល្លារ, ភាសាខ្មែរនឹងចេញផ្សាយនៅពេលខាងមុខ)

ឯកសារពិភាក្សាលេខ ២០: **ការប៉ាន់ស្មានសង្គមស្ដីពីដីធ្លីនៅកម្ពុជា**

(ជាភាសាអង់គ្លេស ១០ដុល្លារ, ភាសាខ្មែរនឹងចេញផ្សាយនៅពេលខាងមុខ)

ឯកសារពិភាក្សាលេខ ២១: **កម្ពុជាឆ្នាំ១៩៩៩_២០០០:** ដីធ្លី កំលាំងពលកម្ម និងជីវភាពរស់នៅតាមជនបទ

(ជាភាសាអង់គ្លេស ១០ដុល្លារ, ភាសាខ្មែរ នឹងចេញផ្សាយនៅពេលខាងមុខ)

របាយការណ៍មួយស្ដីអំពី **ការអង្កេតលើការគ្រប់គ្រងទំនាស់នៅតាមភូមិដ្ឋានខ្មែរ**

(ជាភាសាអង់គ្លេស ១០ដុល្លារ, ភាសាខ្មែរនឹងចេញផ្សាយនាពេលខាងមុខ)

ឯកសារជាភាសាខ្មែរស្ដីពី **របាយការណ៍ប្រចាំឆ្នាំស្ដីអំពីសេដ្ឋកិច្ចកម្ពុជា_២០០១** ឥឡូវនេះមានលក់នៅ វបសអ តំលៃ ១០.០០០រៀល និងចុះថ្លៃ ៥០% សំរាប់សិស្ស/និស្សិត (ដោយបង្ហាញប័ណ្ណសំគាល់ខ្លួនសិស្ស/និស្សិតដែលមានសុពលភាព) ។

ឯកសារបោះពុម្ពផ្សាយទាំងនេះមានលក់នៅ វបសអ, តាមការបញ្ជាទិញដោយសំបុត្រ រឺអ៊ីម៉ែល និងមានដាក់លក់នៅតាមហាងសៀវភៅផ្សេងៗដូចជានៅ ហាងម៉ូនូម៉ែនប៊ុក បណ្ណាគារអន្ដរជាតិ ស៊ីធីប៊ុក និងនៅតាមតូបលក់សៀវភៅនានានៅក្នុងរាជធានីភ្នំពេញ ។ សេចក្ដីសង្ខេបនៃឯកសារទាំងនេះមាននៅលើទំព័រ website: http://www.cdri.org.kh ។

អាសយដ្ឋាន វបសអ, ផ្ទះលេខ ៥៦ ផ្លូវលេខ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា

ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (៨៥៥-០២៣) ៣៦៨-០៥៣/៨៨០-៧៣៤/៨៨៣-៦០៣

# ការអភិវឌ្ឍន៍ឧត្តមសិក្សា

**រដ្ឋាភិបាលកំពុងផ្តួចផ្តើមការងារចំបងៗជាច្រើនដើម្បីលើកកំពស់គុណភាព និងប្រសិទ្ធិភាពនៃឧត្តមសិក្សានៅកម្ពុជា ។ បណ្ឌិត Luise Ahrens និង បណ្ឌិត Frances Kemmerer បានសង្ខេបពីសាវតារ ស្ថានភាព និងយុទ្ធសាស្ត្របច្ចុប្បន្នសំរាប់ការអភិវឌ្ឍន៍វិស័យនេះ ។**

## សាវតារ

ប្រទេសកម្ពុជាមានស្ថានភាពពិសេសមួយ ទោះបីធៀបនឹងបណ្តាប្រជាជាតិទើបបញ្ចប់ទំនាស់ក៏ដោយ ។ ការរីកវរក្រឡាប់ចាក់នៅក្នុង ៥០ឆ្នាំចុងក្រោយបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដល់ប្រព័ន្ធសេដ្ឋកិច្ច-សង្គមកិច្ច និងក្របខ័ណ្ឌស្ថាប័នរបស់ប្រទេស ហើយដោយឡែកវិស័យអប់រំបានខូចខាតខ្លាំងជាងគេ ។ របបខ្មែរក្រហមពីឆ្នាំ ១៩៧៥-៧៩ បានធ្វើឱ្យខូចខាតសឹងគ្រប់វិស័យនៃសង្គមកម្ពុជា ។ ប្រជាជនប្រុសស្រីកុមារពីមួយលាន ទៅ ពីរលាននាក់ត្រូវស្លាប់ ក្នុងនេះមានទាំងសាស្ត្រាចារ្យ និងអ្នកដែលបានទទួលការបណ្តុះបណ្តាលខាងវិជ្ជាជីវៈ ដ៏ច្រើននាក់ផងដែរ ។ អគារសិក្សា និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងៗដែលមិនទាន់ខូចខាតខ្ទេចខ្ទីរ ក៏ត្រូវបានបោះបង់ចោល ឬគ្មានការថែទាំ នៅក្នុងរយៈពេលនោះ ។ ដូច្នេះហើយ ទោះបីខ្មែរក្រហមបាន ដួលរលំក្នុងឆ្នាំ១៩៧៩ ក៏ដោយ ក៏ដំណើរការកសាងប្រទេសឡើងវិញជួបការលំបាកជា ខ្លាំង ។ នៅក្នុងប្រព័ន្ធអប់រំមានសាស្ត្រាចារ្យមហាវិទ្យាល័យតែមួយចំនួនតូចប៉ុណ្ណោះ ដែលបានរួចរស់ជីវិត ហើយការខូចខាតចំពោះឧត្តមសិក្សានៅតែជះឥទ្ធិពលបន្តទៀតនៅក្នុងការបណ្តុះបណ្តាលសាស្ត្រាចារ្យ និងចរន្តគំនិតដែលជាមូលដ្ឋាននៃប្រព័ន្ធអប់រំទាំងមូល ។ លើសពីនេះទៀត អន្តរកាលជាបណ្តើរៗរបស់ប្រទេសកម្ពុជាទៅកាន់សេដ្ឋកិច្ចទីផ្សារតាំងពីឆ្នាំ១៩៨៩ មក បានបង្កើតតំរូវការកាន់តែធំឡើងចំពោះ ស្ថាប័នឧត្តមសិក្សា ។

> **អន្តរកាលជាបណ្តើរៗរបស់ប្រទេសកម្ពុជាទៅកាន់សេដ្ឋកិច្ចទីផ្សារតាំងពីឆ្នាំ១៩៨៩ មក បានបង្កើតតំរូវការកាន់តែធំឡើងចំពោះស្ថាប័នឧត្តមសិក្សា ។ ដោយសារហេតុផលដូចខាងលើ តាំងពីឆ្នាំ១៩៩០ មក គេឃើញមានការយកចិត្តទុកដាក់យ៉ាងខ្លាំងលើផ្នែកឧត្តមសិក្សា ។**

ដោយសារហេតុផលដូចខាងលើ តាំងពីឆ្នាំ១៩៩០ មក មានការយកចិត្តទុកដាក់យ៉ាងខ្លាំងលើផ្នែកឧត្តមសិក្សា ។ ការសិក្សាតាមអនុវិស័យទាំងអស់បានពិនិត្យឃើញតំរូវការនូវយុទ្ធសាស្ត្រដ៏សក្តិសិទ្ធិមួយសំរាប់ធ្វើកំណែទំរង់ ហើយបានស្របមតិគ្នាលើអនុសាសន៍ដ៏ជាក់លាក់ និងច្រើនចំណុចគួរឱ្យកត់សំគាល់ដូចមានរៀបរាប់សង្ខេបនៅខាងក្រោម ។ ការសិក្សា មានជាអាទិ ការសិក្សារបស់ក្រសួងអប់រំឧបត្ថម្ភ ដោយ UNESCO (RGC and UNESCO 1994), ការសិក្សាដែលឧបត្ថម្ភដោយ ADB (RGC and ADB 1994) ផែនការសកម្មភាពជាតិដែលឧបត្ថម្ភដោយពួកទាយក (NHETF 1997) និងការសិក្សាឧបត្ថម្ភដោយធនាគារពិភពលោក (Zhang 1997) ។

### គុណភាពកម្មវិធីសិក្សា និងលក្ខណៈសមស្របនឹងតំរូវការ

១. កែលំអគុណភាពសាស្ត្រាចារ្យ តាមរយៈការផ្តល់ឱកាសរៀនសូត្រក៏រិតខ្ពស់ថែមទៀត ។

២. សើរើរៀបចំកម្មវិធីសិក្សា ដើម្បីឆ្លើយតបបានល្អថែមទៀតចំពោះតំរូវការរបស់សេដ្ឋកិច្ចជាតិ និងសង្គម ។

៣. បង្កើតប្រព័ន្ធឯកតាឥណទានដើម្បីជួយសំរួលការផ្ទេរនិស្សិត ។

៤. ផលិតសំភារៈក្នុងស្រុកសំរាប់បង្រៀនតាមបែបបទជាប្រព័ន្ធ ។

### ធនធាន

១. បង្កើនធនធានសំរាប់ស្ថាប័នសាធារណៈនានា តាមរយៈប្រព័ន្ធបែងចែកបន្ទុកចំណាយដែលមានឧបត្ថម្ភកធនរបស់រដ្ឋ, ប្រាក់កំរៃបង់ដោយនិស្សិត, និងប្រាក់កំចី/អាហារូបករណ៏របស់រដ្ឋសំរាប់និស្សិត

២. កសាងក្នុងស្ថាប័ននានានូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុមួយដែលមានតម្លាភាព និងគណនេយ្យភាព

៣. សើរើរៀបចំឡើងវិញនូវគោលនយោបាយជួយឧបត្ថម្ភខាងហិរញ្ញវត្ថុដល់និស្សិត ដើម្បីកែលំអលទ្ធភាព សមភាពសំរាប់ស្ត្រី និងសំរាប់និស្សិតជួបការលំបាកតែមានសមត្ថភាព ។

### អភិបាលកិច្ច ការចាត់តាំង និងរចនាសម្ព័ន្ធ

១. បង្កើតក្របខ័ណ្ឌច្បាប់មួយសំរាប់ឧត្តមសិក្សា

២. កសាងផែនការជាតិសំរាប់ឧត្តមសិក្សា

៣. កំណត់ឡើងវិញនូវតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋាភិបាល និងស្ថាប័ននានា ដោយផ្តល់ស្វ័យភាពច្រើនថែមទៀតដល់បណ្តាស្ថាប័ន

៤. កែទំរង់ប្រព័ន្ធជ្រើសចូលរៀន និងការប្រឡងផ្សេងៗ

៥. ធ្វើសនិទានកម្ម (rationalise) ចំនួនសាស្ត្រាចារ្យ និងការចាត់តាំង

៦. ពង្រីកលទ្ធភាពតាមរយៈការលើកទឹកចិត្តដល់ស្ថាប័នឯកជន កម្មវិធីមិនពេញម៉ោង វគ្គសិក្សាពីចំងាយ និងទីតាំងឧត្តមសិក្សាសាធារណៈនៅក្រៅភ្នំពេញ ។

ផែនការសកម្មភាពជាតិ ត្រូវបានកសាងឡើងលើការសិក្សាមួយចំនួនដែលផ្តោតចំលើបញ្ហានានា ដែលគេរកឃើញតាមរយៈការសិក្សាតាមវិស័យផ្សេងៗនៅឆ្នាំ១៩៩៤ ហើយផែនការនេះត្រូវបានដាក់ជូនរដ្ឋាភិបាលនៅខែមេសា ឆ្នាំ១៩៩៧ ។ ប៉ុន្តែមុនពេលក្រុមប្រឹក្សារដ្ឋមន្ត្រីបានឯកភាពលើផែនការ និងបញ្ជូនទៅរដ្ឋសភាដើម្បីអនុម័ត ជាផ្លូវការ ដំណើរការធ្វើផែនការត្រូវផ្អាកដោយសារព្រឹត្តិការណ៏ខែកក្កដា ១៩៩៧ ។ ការបោះឆ្នោតដោយសន្តិភាពខែកក្កដា ១៩៩៨ បានបង្ហាញពីលទ្ធភាពមានការរីកចំរើនជាផ្លូវការឡើង វិញនៅក្នុងឧត្តមសិក្សា ។ ក្នុងខែមិនា ១៩៩៩ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើសិក្ខាសាលា មួយស្តីពីឧត្តមសិក្សា ដោយមានការចូលរួមពី តំណាងនៃស្ថាប័នកំរិតឧត្តមសិក្សាទាំងអស់ និងអ្នកជាប់ពាក់ព័ន្ធកម្ពុជាផ្សេងៗទៀត ។ សិក្ខាសាលាបានបញ្ជាក់ពីការគាំទ្រដល់អនុសាសន៍ជាច្រើនក្នុងផែនការសកម្មភាពជាតិ ប៉ុន្តែការដាក់អនុវត្តន៍អនុសាសន៍ទាំងនេះត្រូវយឺតយ៉ាវ ដោយសារការជជែកវែកញែកកំពុងធ្វើបន្ត ស្តីពីបញ្ហាគ្រប់គ្រង និងហិរញ្ញវត្ថុ ។

ទោះបីការជជែកវែកញែកនៅតែធ្វើបន្ត, ធនាគារពិភពលោកតាមសំណើរបស់រដ្ឋាភិបាលកម្ពុជា បានផ្តល់ក្នុងឆ្នាំ១៩៩៩

* បណ្ឌិត Luise Ahrens ជាទីប្រឹក្សាប្រចាំនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និង បណ្ឌិត Frances Kemmerer ជាទីប្រឹក្សាប្រចាំនៅឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និង កីឡា នាទីក្រុងភ្នំពេញ។

នូវជំនួយបច្ចេកទេសដើម្បីរៀបចំមូលដ្ឋាន គ្រឹះនៃប្រព័ន្ធធានារ៉ាប់រងគុណភាព និងការគ្រប់គ្រងហិរញ្ញវត្ថុស្ថាប័ន ។ ជោគជ័យនៃ ការងារនេះ បាននាំដល់សំណើមួយទៀតរបស់រដ្ឋាភិបាលនូវជំនួយហិរញ្ញវត្ថុសំរាប់ទ្រទ្រង់ដល់ការបង្កើតក្របខ័ណ្ឌច្បាប់សំរាប់ឧត្ដមសិក្សា ការអភិវឌ្ឍន៍ប្រព័ន្ធផ្ដល់សិទ្ធិ និងធានាគុណភាព និងការពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុនៅឧត្ដមសិក្សា ។

ក្នុងពេលជាមួយគ្នានេះ នៅក្នុងផែនការយុទ្ធសាស្ត្រអប់រំ ឆ្នាំ២០០១-០៥ កម្មវិធីទ្រទ្រង់វិស័យអប់រំឆ្នាំ២០០១-០៥ ក្រសួងអប់រំបានបញ្ជាក់ពីការប្ដេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការអនុវត្តន៍អនុសាសន៍នៃផែនការសកម្មភាពជាតិ ។ ដូច្នេះ គោលដៅសំរាប់ ៥ឆ្នាំខាងមុខ មានជាអាទិ: ក្របខ័ណ្ឌច្បាប់ថ្មីមួយ ប្រព័ន្ធជ្រើសចូលរៀនមានតម្លាភាព និងមានប្រសិទ្ធិភាពខ្ពស់ថែមទៀត ការបង្កើនសមត្ថភាពសាស្ត្រាចារ្យ ការកែលំអភាពសមស្របនៃកម្មវិធីសិក្សា ប្រព័ន្ធថ្មីមួយសំរាប់ធានាគុណភាព និងការផ្ដល់ សិទ្ធិ និងការកែលំអអភិបាលកិច្ចស្ថាប័នតាមរយៈការបង្កើតក្រុមប្រឹក្សាភិបាលដែលមានសមាជិកចេញមកពីមជ្ឈដ្ឋានធំទូលាយ ។ ការអនុវត្តន៍គោលដៅទាំងនេះ នឹងប្រើថវិកាបានមកពីអំណោយរដ្ឋាភិបាល និងពីសម្ព័ន្ធភាពជាដៃគូរវាងរដ្ឋាភិបាល, មាតាបិតា និងនិស្សិត, និងពីប្រាក់កំចី និងអំណោយរបស់ទាយក ។ ក្រសួងអប់រំរំពឹងថា វិស័យឧត្ដមសិក្សានឹងរីកធំបាន ១០០%នៅឆ្នាំ ២០០៥ ដោយក្នុងនេះវិស័យឯកជនតំណាងឱ្យ ៨៥%នៃការលូតលាស់ ។

**ស្ថាប័នសាធារណៈជាច្រើនខ្វះខាតថវិកាខ្លាំងណាស់ ដោយសារឧបត្ថម្ភកធនរបស់រដ្ឋាភិបាលមានចំនួនតិចតួចពេក ហើយស្ថាប័នទាំងនេះមិនអនុវត្តយកកំរៃពីនិស្សិតគ្រប់គ្នាទេ ប៉ុន្ដែពួកមានគោលការណ៍បែងចែកដាច់ស្រឡះរវាងនិស្សិតបង់ប្រាក់ និងនិស្សិតអាហារូបករណ៍ ។**

## ស្ថានភាពនៃផ្នែកឧត្ដមសិក្សា

សំរាប់ឆ្នាំសិក្សា២០០០-២០០១ ប្រព័ន្ធឧត្ដម សិក្សារួមមាន ៥ សកលវិទ្យាល័យសាធារណៈ ៣ ស្ថាប័នឯកទេសពាក់កណ្ដាលឯករាជ្យ ឬមហាវិទ្យាល័យ និង ៦ ស្ថាប័នឧត្ដមសិក្សាឯកជនដែលមាន ការទទួលស្គាល់ ។ ស្ថាប័នទាំងនេះទទួលនិស្សិតបានប្រហែល ២៥.០០០នាក់ ។

ស្ថិតិសង្ខេបចុះក្នុងតារាងមិនបានបង្ហាញពីការប្រែប្រួលនៅក្នុងប្រព័ន្ធទេ ។ ទី១: ស្ថាប័នថ្មីៗដែលមានកំរិតគុណភាពខុសៗគ្នាបានបើកទ្វារដំណើរការជារៀងរាល់ខែ និងទី២: បណ្ដាស្ថាប័នដែលមានការទទួលស្គាល់ហើយ កំពុងពង្រីកចំនួនកម្មវិធីសិក្សារបស់ខ្លួន ។ ខណៈដែលមិនទាន់មានប្រព័ន្ធផ្ដល់សិទ្ធិ "ការទទួលស្គាល់" គឺជាដំណើរការមួយដែលមានរូបភាពនយោបាយស្មើគ្នានឹងរូបភាពបច្ចេកទេស ។

ស្ថាប័នសាធារណៈជាច្រើនខ្វះខាតថវិកាខ្លាំងណាស់ ដោយសារឧបត្ថម្ភកធនរបស់រដ្ឋាភិបាលមានចំនួនតិចតួចពេក ហើយស្ថាប័នទាំងនេះមិនអនុវត្តយកកំរៃពីនិស្សិត គ្រប់គ្នាទេ ប៉ុន្ដែមានគោលការណ៍បែងចែកដាច់ស្រឡះរវាងនិស្សិតបង់ប្រាក់ និងនិស្សិតអាហារូបករណ៍។[1] ការបែងចែកបែបនេះ នាំឱ្យមានអប្រសិទ្ធិភាពយ៉ាងធ្ងន់ធ្ងរក្នុងការងារហិរញ្ញវត្ថុ និងគ្រប់គ្រង ដោយហេតុថាថវិកាមានលក្ខណៈវិមជ្ឈការនៅកំរិតមហាវិទ្យាល័យ ហើយពេលវេលារបស់សាស្ត្រាចារ្យ និងធនធានផ្សេងទៀត មិនត្រូវបានប្រើប្រាស់ដោយអស់លទ្ធភាពទេ ។ វិធីនេះបានប៉ះពាល់អវិជ្ជមានចំពោះការលើកទឹកចិត្ត ដល់សាស្ត្រាចារ្យ ពីព្រោះសាស្ត្រាចារ្យនៅក្នុងកម្មវិធីសិក្សាឈ្នួលបានទទួលកំរៃ បៀវត្សរ៍បន្ថែម ចំណែកឯសាស្ត្រាចារ្យក្នុងកម្មវិធីសិក្សាមានអាហារូបករណ៍ទទួលតែបៀវត្សរ៍រដ្ឋប៉ុណ្ណោះ ។

ទាំងចំនួនស្ថាប័នឧត្ដមសិក្សាដែលបើកថ្មី ទាំងកំណើនកម្មវិធីសិក្សាបង់កំរៃ នៅក្នុងស្ថាប័នសាធារណៈបានបង្ហាញថា នៅក្នុងសង្គមមានតំរូវការខ្ពស់នូវការបណ្ដុះបណ្ដាលកំរិតឧត្ដមសិក្សា ។ ដោយចំនួននិស្សិតនៅមធ្យមសិក្សាទុតិយភូមិរំពឹងថា នឹងកើនឡើងបួនដងក្នុងដប់ឆ្នាំខាងមុខ ដូច្នេះចំនួនកន្លែងនៅឧត្ដមសិក្សាត្រូវតែកើនបួនដងដែរដល់ ១០០.០០០នាក់ ដើម្បីរ៉ាប់រងអត្រាបច្ចុប្បន្ននៃការផ្ទេរនិស្សិតពីមធ្យមសិក្សាទៅឧត្ដមសិក្សា ។

គេអាចជជែកវែកញែកថា ទោះបី កំណើនបានបួនដងក្ដី ក៏ប្រព័ន្ធឧត្ដមសិក្សានៅតែតូច ពេកដដែល ដើម្បីបំពេញតំរូវការនៃការអភិវឌ្ឍន៍ ប្រទេស ។ អត្រាចូលរៀនសរុបនៅផ្នែកឧត្ដមសិក្សា កម្ពុជាគឺ ១,២% ធៀបនឹង ២០,៧%

**តារាង១. ការចូលរៀនឧត្ដមសិក្សាក្នុងឆ្នាំ ២០០០-២០០១**

| | សរុប | ភាគរយនៃស្ត្រី | ភាគរយនៃអាហារូបករណ៍ | ភាគរយនៃអាហារូបករណ៍សំរាប់ស្ត្រី |
|---|---|---|---|---|
| **សាធារណៈ** | | | | |
| សាកលវិទ្យាល័យភូមិន្ទកសិកម្ម | 815 | 12% | 91% | 12% |
| សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | 519 | 23% | 100% | 23% |
| សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | 4705 | 26% | 53% | 32% |
| សាកលវិទ្យាល័យមហាឫស្សី | 423 | 6% | 86% | 4% |
| វិទ្យាស្ថានជាតិគ្រប់គ្រង | 8526 | 36% | 8% | 30% |
| វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | 268 | 6% | 77% | 7% |
| មហាវិទ្យាល័យច្បាប់ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច | 3196 | 23% | 25% | 26% |
| សាកលវិទ្យាល័យវេជ្ជសាស្ត្រ | 852 | 26% | 100% | 26% |
| **ឯកជន** | | | | |
| សាកលវិទ្យាល័យន័រតុន | 3619 | 23% | | |
| វិទ្យាស្ថានបច្ចេកទេស និងគ្រប់គ្រង | 543 | 26% | | |
| មហាវិទ្យាល័យគ្រប់គ្រង និងច្បាប់ | 612 | 22% | | |
| មហាវិទ្យាល័យក្រុងវ៉ាស៊ីងតោន ឌីស៊ី | 281 | 32% | | |
| វិទ្យាស្ថានគ្រប់គ្រង និងសេដ្ឋកិច្ច | 195 | 22% | | |
| វិទ្យាស្ថានអន្ដរជាតិនៃកម្ពុជា | 329 | 28% | | |

កំណត់សំគាល់: ការចូលរៀនថ្នាក់ត្រៀមមិនបានគិតបញ្ចូលទេ ។ ប្រភព: នាយកដ្ឋានឧត្ដមសិក្សា, ក្រសួងអប់រំ យុវជន និងកីឡា ២០០១ ។

**តារាង២. អាំងឌីការទ័រជ្រើសរើស ឆ្នាំ១៩៩៧ (ឬឆ្នាំជិតបំផុតតាមអាចរកបាន)**

| | ផសស ក្នុងមនុស្សម្នាក់ (US$) | អត្រាចូលរៀនសរុបនៅឧត្តមសិក្សា | ចំនួននិស្សិតឧត្តមសិក្សាក្នុងប្រជាជន 100,000នាក់ | ចំណាយសាធារណៈខាងអប់រំគិតជា %GNP | ចំណាយចរន្តសាធារណៈជា % GNP PC | កំរិតអនក្ខរកម្មមនុស្សពេញវ័យ |
|---|---|---|---|---|---|---|
| កម្ពុជា | 280 | 1.2 | 85 | 2.9 | 29.9 | 63.7 |
| វៀតណាម | 330 | 6.9 | 678 | 3.0 | 87.8 | 7.4 |
| ថៃ | 2,720 | 22.1 | 2,252 | 4.8 | 26.7 | 5.3 |
| ម៉ាឡេស៊ី | 4,550 | 11.7 | 1,048 | 4.9 | 57.3 | 14.3 |
| អាស៊ាន | | 20.7 | | 3.8 | 49.4 | 9.0 |
| អាស៊ីខាង កើត និង ប៉ាស៊ីហ្វិក | | 15.2 | | 3.5 | 49.9 | 10.5 |
| ប្រទេសមានចំណូលទាប | | 5.1 | | 3.7 | | 43.0 |

ប្រភព: តារាងវិភាគបានពីរដ្ឋាភិបាល, ក្រសួងអប់រំ, និងធនាគារពិភពលោក (២០០១)

នៅប្រទេស អាស៊ាន និង ៥,១% នៅប្រទេសមានចំណូលទាប នានាក្នុងពិភពលោក (តារាង២) ។ កង្វះអ្នកមានជំនាញខ្ពស់ គឺជាឧបសគ្គមួយយ៉ាងធ្ងន់ធ្ងរចំពោះការរីកលូតលាស់នៅក្នុងវិស័យសាធារណៈ និងឯកជន ហើយនាំឱ្យមានការពឹងផ្អែកយ៉ាងធ្ងន់ធ្ងរទៅលើជំនួយបច្ចេកទេសបរទេសដែលមានតំលៃយ៉ាង ខ្ពស់ ។ ឧទាហរណ៍ នៅក្នុងវិស័យអប់រំ សាស្ត្រាចារ្យមិនដល់ ៥% ទេ មានសញ្ញា ប័ត្រឧត្តមសិក្សា ។ មួយចំណែកទៀត មានវេជ្ជបណ្ឌិតតែ ៥៨នាក់ និងគិលានុបដ្ឋាកតែ១៣៦នាក់ទេ សំរាប់ប្រជាជន ១០០.០០០នាក់ ហើយក្នុងឆ្នាំ២០០១ សាកលវិទ្យាល័យវេជ្ជសាស្ត្រគ្រោងថានឹងផ្តល់សញ្ញាប័ត្រដល់និស្សិតចប់ការសិក្សាតែ ១៩២ នាក់ប៉ុណ្ណោះ (ហើយកម្ពុជាគឺជាប្រទេសដែលមានអាំងឌីកាទ័រខាងសុខាភិបាលយ៉ាប់ជាងគេនៅក្នុងតំបន់) ។ សាកលវិទ្យាល័យភូមិន្ទកសិកម្មនឹងប្រគល់សញ្ញាប័ត្រចប់ការសិក្សាដល់អ្នកបច្ចេកទេសខាងព្រៃឈើ កសិកម្ម ឬវារីវប្បកម្មតែ ១០៤នាក់ ឯវិទ្យាស្ថានបច្ចេកទេសកម្ពុជានឹងបញ្ចេញអ្នកបច្ចេកទេសបានតែ ៧៨នាក់ប៉ុណ្ណោះ ។

គេអាចមើលឃើញយ៉ាងច្បាស់ពីលក្ខណៈចាំបាច់នៃការរីកចំរើន និងការអភិវឌ្ឍន៍ឧត្តមសិក្សា ។ សព្វថ្ងៃ កម្ពុជាពឹងផ្អែកលើទីប្រឹក្សាបច្ចេកទេសបរទេសជាច្រើន ដើម្បីរ៉ាប់រងតួនាទីគ្រប់គ្រងនៅកំរិតមធ្យម និងខ្ពស់ ដូច្នេះត្រូវតែចាប់ផ្តើមបណ្តុះអ្នកមានជំនាញខ្ពស់ៗឱ្យបានច្រើន ដើម្បីរ៉ាប់រងតួនាទីដឹកនាំនៅក្នុងរដ្ឋាភិបាល និងវិស័យឯកជន ។ លើសពីនេះទៀត កម្ពុជាត្រូវកសាងនូវក្របខ័ណ្ឌមនុស្សមួយក្រុមដែលមានសមត្ថភាពអាចចាត់ចែងបាន ដោយច្នៃប្រឌិតខ្ពស់នូវបញ្ហាជាប់ទាក់ទិននឹងការគ្រប់គ្រងបរិស្ថាន ការកាត់បន្ថយភាពក្រីក្រ ការផ្គត់ផ្គង់ សេវាខាងអប់រំ និងសុខាភិបាល, និងបញ្ហាខាងការលូតលាស់ និងសាកលភាវូបនីយកម្ម ។

បើសិនកម្ពុជាចង់ដើរតាមលំនាំអភិវឌ្ឍន៍របស់ប្រទេសជិតខាងខ្លួន, ប្រព័ន្ធឧត្តមសិក្សាត្រូវតែពង្រីកឱ្យខ្លាំងនៅក្នុងប៉ុន្មានទសវត្សរ៍ខាងមុខ ។ អត្រាចូលរៀនឧត្តមសិក្សានៅ វៀតណាម ថៃ និងម៉ាឡេស៊ី កំពុងកើនឡើងយ៉ាងលឿន (ក្រាហ្វិក១) នៅពេលដែលប្រទេសនិមួយៗឈានជិតដល់ចំណុច "ហក់ឡើង" ខាងសេដ្ឋកិច្ច (ក្រាហ្វិក២) ។ នៅឆ្នាំ១៩៩៧ អត្រាចូលរៀនសរុប មានកំរិត ២២%នៅថៃ, ១២% នៅម៉ាឡេស៊ី, និង ៧%នៅវៀតណាម ។ កំណើនប្រាក់ចំណូល និងការលូតលាស់ទីផ្សារពលកម្ម បានជំរុញតំរូវការកំរិតឧត្តមសិក្សាក្នុងប្រទេសទាំងនេះ ។ម្យ៉ាងវិញទៀត ការផ្គត់ផ្គង់ឥតអាក់នូវអ្នកមានសញ្ញាប័ត្រជំនាញ នឹងជួយធានាឱ្យសេដ្ឋកិច្ចបន្តរីកលូតលាស់ ។ នៅកម្ពុជា ការគួបផ្សំរវាងកំណើនសេដ្ឋកិច្ច និងកំណើនចំនួនប្រជាជនអាយុ... ចំនួនប្រជាជន អាយុ ១៨-២៣ឆ្នាំ ក្នុង ២៥ឆ្នាំខាងមុខ, នឹងបង្កើតតំរូវការកន្លែងសិក្សាសំរាប់ច្រើនម៉ឺននាក់ថែមទៀតនៅឧត្តមសិក្សា បើសិនគេចង់បង្កើនអត្រាចូលរៀនសំរាប់អ្នកគ្រប់អាយុចូលរៀនឧត្តមសិក្សាពី ១% ដល់ ៥% ។ តួនាទីរបស់វិស័យឯកជនក្នុងកំរិតឧត្តមសិក្សាក៏ប្រហែលកើនឡើងដែរ។ ដូច្នេះ សាកលវិទ្យាល័យកម្ពុជាត្រូវចូលជាបណ្តើរៗទៅក្នុង "ប្រព័ន្ធសិក្សាធិការពិភពលោក" ដោយមាននិយមន័យ និងរចនាសម្ព័ន្ធសិក្សាធិការ និងគ្រប់គ្រងដូចគ្នា, និងមានគោលការណ៍ធូរទូលាយចំពោះលំហូរឆ្លងកាត់ព្រំដែននៃនិស្សិត និងបុគ្គលិកសិក្សា ។

## យុទ្ធសាស្ត្រសំរាប់ពង្រីក និងអភិវឌ្ឍន៍ប្រព័ន្ធឧត្តមសិក្សា

ពិតមែនតែហេតុផលដែលតំរូវឱ្យមានវិនិយោគ និងការអភិវឌ្ឍន៍ក្នុងឧត្តមសិក្សាអាចមើលឃើញយ៉ាងច្បាស់ក៏ដោយ ក៏កន្លងមកយុទ្ធសាស្ត្រសក្តិសិទ្ធិដើម្បីសំរេចគោលដៅនេះ រកមិនទាន់បាននៅឡើយទេ ។ ប៉ុន្តែសព្វថ្ងៃ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ថា ក្របខ័ណ្ឌច្បាប់គឺជាជំហានជាមូលដ្ឋានដែលត្រូវធ្វើដើម្បីឈានទៅអនុវត្តគោលដៅ




ប្រភព: ក្រាហ្វិក និងការវិភាគបានពីរដ្ឋាភិបាល និងធនាគារពិភពលោក 2001b ។




ប្រភព: ក្រាហ្វិក និងការវិភាគបានពីរដ្ឋាភិបាល និងធនាគារពិភពលោក 2001b ។

ផ្សេងៗសំរាប់ការអភិវឌ្ឍន៍ ដូចដែលមានការលើកមតិឡើងក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ (RGC 2001a; RGC 2001b) ។ តំរូវការធនធានហិរញ្ញវត្ថុសំរាប់ការកែលំអ និងកំណែទំរង់ឧត្ដមសិក្សាមានទំហំធំ ដូច្នេះបើសិនគ្មានក្របខ័ណ្ឌច្បាប់ទ្រទ្រង់ទេ ទាំងពួកទាយក ទាំងរដ្ឋាភិបាលនឹងពិបាកធ្វើវិនិយោគដ៏ចាំចាច់នានានៅក្នុងវិស័យនេះណាស់ ។ រដ្ឋាភិបាលបានបញ្ជាក់ថា អាទិភាពសំរាប់ថវិកាខាងអប់រំគឺ ការអប់រំជាមូលដ្ឋាន និងការអប់រំក្រៅប្រព័ន្ធ, ទោះបីជំនួយទ្រទ្រង់ថវិកាសំរាប់បៀវត្សរ៍បុគ្គលិកបំរើការនៅកំរិតឧត្ដមសិក្សា និងសំរាប់ផែនការសកម្មភាពអាទិភាពនៅឧត្ដមសិក្សា នឹងបន្ដផ្ដល់ឱ្យក្នុងកំរិតដដែលទៀតក៏ដោយ ហើយនេះគឺជាហេតុផលកាន់តែធំមួយទៀតដើម្បីឱ្យមានច្បាប់ និងសនិទានកម្ម (rationalisation) ចំណាយនៅកំរិតឧត្ដមសិក្សា ។

រាជរដ្ឋាភិបាលកម្ពុជាបានសុំឱ្យធនាគារពិភពលោកជួយឧបត្ថម្ភដល់ការតាក់តែងក្របខ័ណ្ឌច្បាប់ និងការងារមួយចំនួនទៀតដូចតទៅ:

១. តំរូវការខាងឧត្ដមសិក្សាត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌច្បាប់កម្ពុជា និងនៅក្នុងវិស័យអប់រំ ។ ជាការមួយច្បាស់លាស់ណាស់ដែលថា បើឧត្ដមសិក្សាគ្មានគុណភាព និងមិនបានធ្វើសនិទានកម្មដើម្បីបំពេញតំរូវការនៃការអភិវឌ្ឍន៍ និងសង្គមកម្ពុជា, ក្នុងករណីនេះនឹងពុំមានការកែលំអនៅក្នុងវិស័យអប់រំណាមួយផ្សេងទៀតទេ ។ ក្នុងរយៈពេលវែង "ច្បាប់អប់រំ" ទូទៅមួយត្រូវតែកសាងឡើង ហើយឧត្ដមសិក្សាគឺជាជំហានទីមួយនៅក្នុងដំណើរការនេះ ។

២. ត្រូវកសាងគណៈកម្មាធិការផ្ដល់សិទ្ធិមួយ សំរាប់ជួយទ្រទ្រង់ឱ្យស្ថាប័នឧត្ដមសិក្សានានាចាប់ផ្ដើមដំណើរការធានាគុណភាព ទាំងនៅក្នុងស្ថាប័ន និងក្នុងចំណោមស្ថាប័នឧត្ដមសិក្សា (ទាំងសាធារណៈ និងឯកជន) នៅក្នុងប្រព័ន្ធឧត្ដមសិក្សានៅកម្ពុជា ។ ត្រូវកំណត់ស្ដង់ដាអប្បបរមាមួយ សំរាប់ឱ្យស្ថាប័នដែលមានស្រាប់ និងក្រុម/បុគ្គលនានាដែលចង់បង្កើតស្ថាប័នឧត្ដមសិក្សា, គេមានគោលការណ៍ណែនាំខ្លះៗដើម្បីធ្វើប្រតិបត្តិការ ។ ជាការពិតហើយ ប្រព័ន្ធឧត្ដមសិក្សាត្រូវ និងមុខជារីកលូតលាស់ដើម្បីឆ្លើយតបនឹងកំណើនតំរូវការ, ប៉ុន្ដែវារីកលូតលាស់យ៉ាងដូចម្ដេចខាងគុណភាព និងខាងចំណុចប្រមូលផ្ដុំ គឺសុទ្ធសឹងជាបញ្ហាដែលត្រូវដោះស្រាយ ។ និស្សិតក្នុងពេលអនាគតត្រូវការដឹងថា តើខ្លួនគេបានអ្វីនៅពេលគេចូលទៅក្នុងប្រព័ន្ធ ហើយការផ្ដល់ពត៌មានជាសាធារណៈពីរឿងគុណភាព វាមានសារៈសំខាន់ជាគន្លឹះដើម្បីឱ្យពួកគេមានសមត្ថភាពអាចជ្រើសរើសបានល្អនូវស្ថាប័នណាដែលគេចង់ចូលរៀន ។

៣. ត្រូវមានច្បាប់រួមគ្នាមួយ ដើម្បីឱ្យការផ្ទេរនិស្សិតពីស្ថាប័នមួយទៅស្ថាប័នមួយអាចធ្វើទៅកើត ។ ការផ្ទេរទាមទារនូវភាពស៊ីសង្វាក់គ្នាជាមូលដ្ឋាននៅក្នុងប្រព័ន្ធឥណទាន គោលនយោបាយវាយតំលៃ ស្ដង់ដាជ្រើសចូល ប្រវែងឆ្នាំសិក្សា។ល។ ក្នុងនេះត្រូវមានការច្បាស់លាស់ដែរថា ស្ថាប័នឧត្ដមសិក្សាដែលគេហៅថា "សាកលវិទ្យាល័យ" គឺជាសាកលវិទ្យាល័យពេញសមត្ថភាពមែន ។ កង្វះភាពច្បាស់លាស់ខាងនិយមន័យនឹងបង្កើតបញ្ហាចោទនៅក្នុងប្រព័ន្ធច្បាប់គ្រប់គ្រងដែលត្រូវមានជាចាំបាច់សំរាប់ប្រព័ន្ធឧត្ដមសិក្សា ។ ឧទាហរណ៍ មិនត្រូវមានការច្រឡូកច្រឡំអ្វីទេ រវាងស្ថាប័នបណ្ដុះបណ្ដាលវិជ្ជាជីវៈដែលធ្វើការបណ្ដុះបណ្ដាលជំនាញ ហើយស្ថាប័នបច្ចេកទេសដែលផ្ដល់បរិញ្ញាប័ត្រខាងវិស្វកម្ម ។ លើសពីនេះទៀត ត្រូវមានចំណងទាក់ទងរវាងកម្មវិធីសិក្សាក្នុងស្ថាប័នឧត្ដមសិក្សា ទីផ្សារ ហើយនិងតំរូវការរបស់ប្រទេសកម្ពុជា ។ តំរូវការទាំងនេះដែលជូនកាលមិនស្របគ្នាទេ ត្រូវតែយកមកជជែកវែកញែកនៅក្នុងវេទិកាសាធារណៈ ហើយឧត្ដមសិក្សាត្រូវតែឆ្លើយតបតាមតំរូវការនៃទីផ្សារ និងប្រទេសកម្ពុជា ។

៤. ការងារគ្រប់គ្រង និងហិរញ្ញវត្ថុនៅក្នុងស្ថាប័នឧត្ដមសិក្សា គឺជាប្រព័ន្ធទ្រទ្រង់មួយដ៏សំខាន់ដែលត្រូវសិក្សាដោះស្រាយ ។ ក្រុមប្រឹក្សាភិបាល តម្លាភាពនៃប្រតិបត្តិការហិរញ្ញវត្ថុ តារាងថ្លៃសិក្សា ឯកសារពិពណ៌នាការងារច្បាស់លាស់ និងការជ្រើសបុគ្គលិកតាមនេះ សុទ្ធសឹងជាបញ្ហាដែលត្រូវមានចែងច្បាស់លាស់ និងមានណែនាំនៅក្នុងច្បាប់ ។ អ្នកទទួលផលពីលក្ខណៈច្បាស់លាស់នេះ គឺពួកនិស្សិត និងស្ថាប័នឧត្ដមសិក្សាខ្លួនឯង ។ ស្ថាប័នឧត្ដមសិក្សាត្រូវបង្កើនស្វ័យភាពការគ្រប់គ្រងយ៉ាងល្អនូវបុគ្គលិក និងហិរញ្ញវត្ថុ នឹងការទទួលស្គាល់តាមរយៈរបាយការណ៍ជាសាធារណៈ និងការផ្ដល់ពត៌មាន ហើយទាំងអស់នេះមានសារៈសំខាន់ជាគន្លឹះសំរាប់ដំណើរការល្អនៃការងារគ្រប់គ្រង និងហិរញ្ញវត្ថុ ។

៥. ដូចបានលើកឡើងហើយ កេរ្ដិ៍ដំណែលពីទសវត្សរ៍មុនៗ គឺជាការពិតជាក់ស្ដែងដែលធ្វើឱ្យសាស្ត្រាចារ្យភាគច្រើននៅឧត្ដមសិក្សា ខ្វះសញ្ញាប័ត្រ និងខ្វះសមត្ថភាពដែលត្រូវមានជាចាំបាច់សំរាប់បង្រៀននៅកំរិតដែលត្រូវបង្រៀន ។ កង្វះខាតលទ្ធភាពខាងធនធានវិជ្ជាជីវៈដូចជា សៀវភៅ ទស្សនាវដ្ដី អ៊ិនធឺណិត វគ្គបណ្ដុះបណ្ដាលឡើងវិញ សញ្ញាប័ត្រ គួបផ្សំនឹងវិធីសាស្ត្របង្រៀនចាស់ហួសសម័យ បៀវត្សរ៍ទាប និងការបញ្ចូលគ្នាមិនបានល្អនូវបុគ្គលិកមួយចំនួនតូចដែលមានការបណ្ដុះបណ្ដាលល្អ ទាំងអស់នេះបានផ្សំគ្នារាំងស្ទះដល់ការលូតលាស់សមត្ថភាពសាស្ត្រាចារ្យ ទោះបីចំពោះអ្នកពូកែជាងគេនៅក្នុងប្រព័ន្ធក៏ដោយ ។ មិនមែនអ្នកទាំងនេះខ្វះសន្ទះចិត្តទេ ប៉ុន្ដែ គឺកង្វះបៀវត្សរ៍ កង្វះលក្ខណៈវិនិច្ឆ័យច្បាស់លាស់សំរាប់លើកទឹកចិត្តអ្នកមានស្នាដៃ កង្វះការធ្វើផែនការបង្រៀនដែលផ្សារភ្ជាប់នឹងការបណ្ដុះបណ្ដាលបន្ថែម កង្វះឱកាសបានរៀនសូត្រតឹងរ៉ឹងនៅក្នុងប្រទេសកម្ពុជា ហើយនិងឱកាសដ៏តិចតួចនៃការបានទៅសិក្សានៅសាកលវិទ្យាល័យបរទេស ដែលជាបញ្ហាចោទ ។

៦. បញ្ហាទាំងនេះមិនអាចដោះស្រាយទាំងអស់ក្នុងពេលតែមួយ និងក្នុងកំលាំងប៉ុនគ្នានៅក្នុងក្របខ័ណ្ឌនៃច្បាប់ថ្មីនោះទេ ។ ប៉ុន្ដែរាជរដ្ឋាភិបាលកម្ពុជាសង្ឃឹមថា ច្បាប់ឧត្ដមសិក្សាថ្មីនឹងក្លាយជាគ្រឹះសំរាប់ការកសាងប្រព័ន្ធឧត្ដមសិក្សាមួយដែលមានគុណភាពខ្ពស់ មានចីរភាព និងឆ្លើយតបនឹងតំរូវការ ។ ដោយសារមានប្រព័ន្ធឧត្ដមសិក្សាល្អ ជួយទ្រទ្រង់កិច្ចខំប្រឹងប្រែងកសាងធនធានមនុស្សរបស់រាជរដ្ឋាភិបាលកម្ពុជា នឹងបានទទួលជោគជ័យ ។

## កំណត់សំគាល់

១. បច្ចុប្បន្នរដ្ឋាភិបាលបានកំណត់ចំនួននិស្សិតអាហារូបករណ៍សំរាប់ស្ថាប័នសាធារណៈនិមួយៗ ។ ប៉ុន្ដែឧបត្ថម្ភកធនរបស់រដ្ឋាភិបាលរ៉ាប់រងមិនបានពេញលេញទេនូវចំណាយពិតក្នុងការបង្រៀនពួកនិស្សិតទាំងនេះ ។

២. តាមការព្យាករណ៍ ប្រជាជនអាយុ ១៨-២៣ឆ្នាំ នឹងកើនពី ៩៨៣.០០០នាក់ក្នុងឆ្នាំ២០០០ ដល់ ១.៨០៥.០០០នាក់ ក្នុងឆ្នាំ ២០២៥ ។ កំណើនអត្រាចូលរៀនដុលដល់ ៥% នឹងបង្កើតតំរូវការប្រហែល ៩០.០០០កន្លែងសិក្សានៅឧត្ដម សិក្សា (បច្ចុប្បន្នមាន ១០.០០០កន្លែង) ។

៣. ចំពោះការវែកញែក និងការពិពណ៌នាលំអិតស្ដីអំពីនិន្នាការ និងការអភិវឌ្ឍន៍ឧត្ដមសិក្សានៅក្នុងប្រទេសអាស៊ីនានា សូមអានឯកសាររបស់ Gerard and Mak 1997 ។

## ឯកសារយោង

Gerard and Mak (1997), Gerard A. Postiglione and Grace C.L. Mak. (eds.) *Asian Higher Education in An International Handbook and Reference Guide* (London: Greenwood Press).

NHETF (National Higher Education Task Force) (1997), *The National Action Plan*, (Phnom Penh).

# ពលកម្មចំណាកស្រុកនៅក្នុងសេដ្ឋកិច្ចអន្តរកាលនៃអាស៊ីអគ្នេយ៍

## ភស្តុតាងមួយចំនួនបង្ហាញពីផលប៉ះពាល់លើភាពក្រីក្រនៅ កម្ពុជា ឡាវ និង វៀតណាម ។*

អត្ថបទនេះមានគោលដៅធ្វើការប៉ាន់ស្មានពីចំនួនពលករចំណាកស្រុកបែងចែកតាមប្រភេទ និងកំណត់ពីកំរិតដែលចំណាកស្រុកបានជួយដោះស្រាយដល់បញ្ហាភាពក្រីក្រនៅក្នុងបណ្តាប្រទេសមានសេដ្ឋកិច្ចអន្តរកាលនៅអាស៊ីអគ្នេយ៍ ។ អត្ថបទផ្អែកជាសំខាន់លើទិន្នន័យ និងការសិក្សាលើប្រទេសបីគឺកម្ពុជា ឡាវ និងវៀតណាម ដែលត្រូវបានប្រមូលនិងធ្វើឡើងដោយបណ្តាញវិភាគអភិវឌ្ឍន៍ (Development Analysis Network: DAN) ក្នុងឆ្នាំ២០០០-២០០១ (សូមអានឯកសារ DAN 2001) ។

### លំនាំនៃការអភិវឌ្ឍន៍ក្នុងតំបន់

នៅក្នុងសេដ្ឋកិច្ចអន្តរកាលទាំងអស់ក្នុងតំបន់ និងនៅក្នុងប្រទេសជិតខាងផ្សេងទៀត ចលនាជនចំណាកស្រុកបានកើតមានឡើងតាំងពីសម័យអាណានិគម និងពីមុនសម័យអាណានិគមទៀតផង ។ ចំណាកស្រុកបានកើតមានបន្តរហូតមកដល់សព្វថ្ងៃ ហើយជាក់ស្តែងថែមទាំងបានកើនឡើងក្នុងរូបភាពខ្លះៗទៀតផង ។ ចំណាកស្រុកមានតួនាទីបំពេញគំលាតរវាងតំរូវការ និងការផ្គត់ផ្គង់ពលកម្មនៅក្នុងចំណែកខ្លះនៃទីផ្សារ ព្រមទាំងជួយកាត់បន្ថយអតុល្យភាពរវាងតំបន់ផ្សេងៗ ។ ក្នុងដំណើរការនេះ ចំណាកស្រុកបានក្លាយជាយុទ្ធសាស្ត្រស្រោចស្រង់ជីវិតរបស់ប្រជាជនមួយភាគធំ ។ នៅក្រោមសម្ពាធនៃកំណើនប្រជាសាស្ត្រ ការផ្លាស់ប្តូរកន្លែងជាចាំបាច់ដើម្បីដោះស្រាយជីវភាព គឺកាន់តែមានចំនួនច្រើនឡើង ។ លក្ខណៈពិសេសមួយទៀតនៃសេដ្ឋកិច្ចអន្តរកាល គឺប្រវត្តិមានសង្គ្រាមយូរឆ្នាំក្នុងពេលថ្មីៗ ការឆ្លងកាត់របបសង្គមនិយម និងអន្តរកាលទៅកាន់សេដ្ឋកិច្ចទីផ្សារជាបន្តមកទៀត ។ កត្តាទាំងនេះបាន បង្កឱ្យមានអស្ថិរភាពក្នុងរយៈពេលដ៏វែងៗ ដែលបាន រាំងស្ទះដល់វិនិយោគ ធ្វើឱ្យខូតខាតដល់ហេដ្ឋារចនា សម្ព័ន្ធ និងការអភិវឌ្ឍន៍ធនធានមនុស្ស ហើយកំរិតជីវភាពប្រជាជនក៏បានទទួលរងនូវផលប៉ះពាល់ជាអវិជ្ជមាន ។

**ចលនាជនចំណាក ស្រុកបានកើតមានឡើងតាំងពីសម័យ
អាណានិគម និងពីមុនសម័យអាណានិគមទៀតផង ។ វាបាន
កើតមានបន្តរហូតមកដល់សព្វថ្ងៃ ហើយនៅក្នុងដំណើរការនេះ
ចំណាកស្រុកប
ានក្លាយជា-
យុទ្ធសាស្ត្រស្រោចស្រង់ជីវិតរបស់ប្រជាជនមួយភាគធំ ។
នៅក្រោមសម្ពាធនៃកំណើនប្រជា សាស្ត្រ ការ-**

កម្ពុជាទើបឆ្លងផុតពីសង្គ្រាម និងការវឹកវរផ្ទៃក្នុងដែលបានអូសបន្លាយអស់ជិតបីទសវត្សរ៍ ហើយជាលទ្ធផល ស្ថាប័ននានាខាងសង្គមកិច្ច ហិរញ្ញវត្ថុ និងអភិបាលកិច្ចបានទទួលរងការខូចខាតយ៉ាងធ្ងន់ធ្ងរ ។ បច្ចុប្បន្នស្ថាប័នទាំងនេះទើបតែចាប់ផ្តើមមានដំណើរការឡើងវិញប៉ុណ្ណោះ ។ ក្នុងឆ្នាំ១៩៩៣ កិច្ចប្រឹងប្រែងធ្វើការអភិវឌ្ឍន៍ធំៗមួយចំនួនត្រូវបានផ្តួចផ្តើមឡើង ហើយ ៤ឆ្នាំក្រោយមក សេដ្ឋកិច្ចសំរេចបានអត្រាកំណើន ៧-៨% ។ ប៉ុន្តែអត្រាកំណើននេះបានធ្លាក់ចុះជាថ្មីដោយការប្រយុទ្ធគ្នាក្នុងឆ្នាំ១៩៩៧ ហើយរហូតមកដល់ឆ្នាំ១៩៩៨ ទើបសកម្មភាពអាជីវកម្មមានដំណើរការធម្មតាឡើងវិញ ។ ក្នុងឆ្នាំ១៩៩៩ ប្រជាជនរស់នៅក្រោមបន្ទាត់ក្រីក្រមានប្រហែល ៣៦% ។ គំលាតដ៏ធំរវាងជនបទ-ទីក្រុង កំណើនដ៏លឿននៃចំនួនប្រជាជន និងកង្វះដ៏ធ្ងន់ធ្ងរនៃធនធានរូបវន្ត និងធនធានមនុស្ស គឺជាបញ្ហាធំៗដែលកម្ពុជាត្រូវប្រឈមមុខក្នុងពេលនេះ ។ បញ្ហាទាំងនេះក៏បានបង្កឱ្យមានលក្ខខណ្ឌនានាដែល "ជំរុញ" ឱ្យចំណាកស្រុក ។

នៅឡាវ និងវៀតណាម សង្គ្រាមបានចប់តាំងពីពាក់កណ្តាលទសវត្សរ៍១៩៧០ ប៉ុន្តែរហូតមកដល់ចុងទសវត្សរ៍១៩៨០ ទើបឃើញផុសចេញនូវលក្ខខណ្ឌនានាដែលអនុញ្ញាតឱ្យមានកំណើនលឿន ។ សំរាប់មួយចំណែកធំនៃការអភិវឌ្ឍន៍ក្នុងបីទសវត្សរ៍កន្លងមក ប្រទេសឡាវបានស្ថិតនៅខាងក្រៅប្រព័ន្ធបែងចែកការងារអន្តរជាតិ ពីព្រោះបានអនុវត្តរបបនយោបាយ និងសេដ្ឋកិច្ច ក្នុងរូបភាពបំរើកសិកម្ម និងតាមផែនការប្រមូលផ្តុំ ។ ទោះបីដង់ស៊ីតេប្រជាជននៅទាបនៅឡើយក៏ដោយ ក៏ធនធានរូបវន្ត និងធនធានមនុស្សនៅអន់ថយខ្លាំងណាស់ ។ យន្តការសេដ្ឋកិច្ចថ្មី ដែលឡាវបានអនុម័តក្នុងឆ្នាំ១៩៨៦ បាននាំឱ្យមានសេរីភាវូបនីយកម្មសេដ្ឋកិច្ចមួយចំនួន និងធ្វើឱ្យសេដ្ឋកិច្ចមានកំណើនដល់ ៦% សំរាប់មួយរយៈពេលខ្លីក្នុងទសវត្សរ៍១៩៩០ ។ ប៉ុន្តែគិតជារួម ក្នុងទសវត្សរ៍១៩៩០ ចំនួនប្រជាជនរស់នៅក្រោមបន្ទាត់ក្រីក្រនៅតែខ្ពស់រហូតដល់ទៅ ៤៦% ។

វៀតណាមមានសន្ទុះសេដ្ឋកិច្ចខ្លាំងណាស់ក្នុងប៉ុន្មានឆ្នាំកន្លងទៅនេះ ។ ស្ថាប័នខាងសង្គមកិច្ច និងស្ថាប័នស៊ីវិលរបស់វៀតណាម បានឆ្លងកាត់រយៈពេលសង្គ្រាមដោយសឹងតែគ្មានការខូចខាត ហើយវាជាហេតុផលដែលវៀតណាមមានអត្រាអក្ខរកម្ម និងកំរិតអប់រំដ៏ខ្ពស់ ។ វៀតណាមបានអនុម័តគោលនយោបាយ Doi Moi នៅចុងទសវត្សរ៍១៩៨០ ហើយតាមនេះ វៀតណាមបានចាប់ផ្តើមនូវកំណែទំរង់មួយចំនួនឆ្ពោះទៅកាន់សេដ្ឋកិច្ចទីផ្សារ ដោយសំរេចអត្រាលូតលាស់ដល់ ៧-៨% ក្នុងមួយឆ្នាំនៅដើមនិងពាក់កណ្តាលទសវត្សរ៍១៩៩០ ។ អត្រាភាពក្រីក្រក្នុងប្រជាជនសរុបបានថយចុះពី ៥១%ក្នុងឆ្នាំ១៩៩៣ មកត្រឹមប្រហែល ៣៧% ក្នុងឆ្នាំ១៩៩៨។ ប៉ុន្តែមកដល់ឆ្នាំ ១៩៩៨ ហើយក៏ដោយ ក៏កំលាំងពលកម្មដែលធ្វើការក្នុងវិស័យកសិកម្មជីវព្រឹត្តិ (subsistence agriculture) មានទំហំដល់ទៅ ៧៣% ។ នៅចុងទសវត្សរ៍១៩៩០ វៀតណាមត្រូវបញ្ឈប់ពីការងារនូវពលករជាច្រើនក្នុងសហគ្រាសរដ្ឋ ដោយសារសហគ្រាសមានប្រសិទ្ធិភាពទាប និងគ្មាន ចីរភាព ហើយការបញ្ឈប់នេះគួបផ្សំនឹងឥទ្ធិពលនៃ ការរំសាយកងទ័ពផង បានធ្វើឱ្យសភាពការណ៍ក្នុង ទីផ្សារការងារដែលកំពុងលំបាកស្រាប់ឱ្យកាន់តែយ៉ាប់យ៉ឺនថែមទៀត (Anh 2001) ។

ម្យ៉ាងវិញទៀត វិបត្តិហិរញ្ញវត្ថុឆ្នាំ១៩៩៧ បាន ប៉ះពាល់ដល់ប្រទេសទាំងបី ហើយហេតុផលសំខាន់គឺមកពី កម្ពុជា ឡាវ វៀតណាម ពឹងផ្អែកលើទុនវិនិយោគរបស់ប្រទេសអាស៊ីឯទៀត ។

* អត្ថបទនេះរៀបចំឡើងដោយលោក Sarthi Acharya នាយកស្រាវជ្រាវនៃ វបសអ ក្នុងនាមនៃបណ្តាញវិភាគពីការអភិវឌ្ឍន៍ (DAN) ។

ដោយសារមូលហេតុដូចខាងលើ ប្រទេសទាំងបី មានពលកររៀងៗខ្លួនដែលស្វែងរកទីកដីថ្មីប្រសើរជាងមុន ដើម្បីឱ្យបានរួចរស់ជីវិត ឬមានជីវភាពប្រសើរឡើង ។

## លំហូរចំណាកស្រុក

### *កម្ពុជា: ចំណាកស្រុកក្នុងប្រទេស*

ជំរឿនឆ្នាំ១៩៩៨ បានរាប់ឃើញប្រជាជន ៨៨១.៤០០នាក់ដែលធ្វើចំណាកស្រុកចេញពីតំបន់ជនបទក្នុងរយៈ៥ឆ្នាំមុនពេលធ្វើជំរឿន (ជនចំណាកស្រុកថ្មី) ។ ក្នុងនេះប្រហែលមួយភាគបីបានធ្វើចំណាកស្រុកក្នុងរង្វង់ ១២ខែមុន (ជនចំណាកស្រុកថ្មីបំផុត) ។ ជាការប្រៀបធៀប អង្កេតប្រជាសាស្ត្រឆ្នាំ១៩៩៦ បានប៉ាន់ថា មានប្រជាជន ៦៤៣.៧០០នាក់បានចាកចេញពីតំបន់ជនបទក្នុងរយៈពេល ៥ឆ្នាំមុនធ្វើអង្កេត ហើយក្នុងនេះ ២៧% បានចាកចេញក្នុងរង្វង់ ១២ខែមុន ។ តួលេខនេះបង្ហាញពីកំណើនយ៉ាងលឿននៃចំណាកស្រុកចេញពីជនបទ ។ ចំងាយជាមធ្យមនៃការធ្វើចំណាកស្រុក ក៏កើនឡើងដែរពីឆ្នាំ១៩៩៦ ដល់ ១៩៩៨ ។ ជំរឿនបង្ហាញទៀតថា ក្នុងចំណោមជនចំណាកស្រុកប្រហែល ៥៧%បានចាកចេញពីភូមិរបស់ខ្លួនទៅកាន់តំបន់ជនបទមួយទៀត ២១% ចេញពីជនបទទៅកាន់តំបន់ទីក្រុង ១៤%ចេញពីទីក្រុងមួយទៅកាន់ទីក្រុងមួយទៀត, និង ៨%ចេញពីទីក្រុងទៅកាន់ជនបទ (Desbarats and Sik 2000) ។

អត្រាចំណាកស្រុកបែបនេះបានចោទសំនួរពីសមត្ថភាពរបស់តំបន់ទីក្រុងក្នុងការទទួលយកជនចំណូលថ្មី ហើយធ្ងន់ធ្ងរជាងនេះទៀតគឺលទ្ធភាពការតែតូចឡើងនៃតំបន់ជនបទក្នុងការដោះស្រាយជីវភាពឱ្យប្រជាជន ។

**ជំរឿនបានបង្ហាញថា ក្នុងចំណោមជនចំណាកស្រុកប្រហែល ៥៧%បានចាកចេញពីភូមិរបស់ខ្លួនទៅកាន់តំបន់ជនបទមួយទៀត ២១% ចេញពីជនបទទៅកាន់តំបន់ទីក្រុង ១៤% ចេញពីទីក្រុងមួយទៅកាន់ទីក្រុងមួយទៀត និង ៨% ចេញពីទីក្រុងទៅកាន់ជនបទ ។**

យុវជន (អាយុ ១៥-២៤ឆ្នាំ) ដែលស្មើនឹង ១៨%នៃប្រជាជនសរុប, តំណាងឱ្យ ៣០% នៃលំហូរចំណាកស្រុកថ្មីបំផុត ។ មនុស្សពេញវ័យនៅក្មេង (អាយុ ២៥-២៩ ឆ្នាំ) ដែលស្មើនឹង ៨%នៃប្រជាជនសរុប, តំណាងឱ្យ ១៣%នៃលំហូរចំណាកស្រុកក្នុង ឆ្នាំ១៩៩៨ ។ នេះជាក្រុមអាយុដែលត្រូវចូលទៅក្នុងទីផ្សារពលកម្ម ហើយបើសិនជាគេរកកន្លែងធ្វើការនៅឯមូលដ្ឋានមិនបានទេ ពួកគេនឹងចាកចេញហើយ ។

### *ចំណាកស្រុកកម្ពុជាទៅថៃ*

កម្ពុជាទទួលពលករចំណាកស្រុកពីវៀតណាម ដើម្បីដោះស្រាយតំរូវការពិសេសៗខ្លះនៃទីផ្សារ ហើយក៏មានពលករខ្លួនមួយចំនួនធ្វើដំណើរទៅថៃដើម្បីធ្វើការក្នុងផ្នែកខ្លះនៃទីផ្សារថៃដែលត្រូវការពលកម្ម ។ មិនសូវមានពតិមានច្រើនទេពីលំហូរ (មិនផ្លូវការ) ទាំងនេះ ។ វបសអ បានធ្វើអង្កេតតូចៗរយៈ ពេលខ្លីចំនួនពីរដងក្នុងឆ្នាំ១៩៩៩ និង ២០០០ ដើម្បី ស្វែងយល់ពីរឿងនេះ (Godfrey *et al* 2001) ។

ជនចំណាកស្រុកភាគច្រើនមានអាយុពី ១៧-៣៥ ឆ្នាំ គឺបានន័យថាជនក្មេងៗមិនអាចរកកន្លែងបានទេ នៅក្នុងទីផ្សារពលកម្មក្នុងស្រុក ។ ជនចំណាកស្រុកផ្លូវ ជិត (ភាគច្រើនស្ត្រី) ត្រូវធ្វើដំណើរជារៀងរាល់ថ្ងៃ ឬត្រឹមពីរ-បីអាទិត្យក្នុងមួយ លើកៗដើម្បីទៅធ្វើការនៅតាមកសិដ្ឋាន ។ ជនចំណាកស្រុកផ្លូវឆ្ងាយ (ភាគច្រើន បុរស) ធ្វើដំណើរចូលជ្រៅទៅក្នុងប្រទេសថៃ ហើយតាមធម្មតាច្រើនចូលធ្វើជាកម្មករ សំណង់ អ្នកលីសែង ពលករក្នុងកសិដ្ឋាន ឬពលករគ្មានជំនាញផ្សេងទៀត ។

ទិន្នន័យស្រង់ពីមូលដ្ឋានបានបង្ហាញពីការធ្លាក់ចុះចំនួនជនចំណាកស្រុកកម្ពុជាទៅថៃក្នុងឆ្នាំ១៩៩៧-៩៨ ដោយសារវិបត្តិសេដ្ឋកិច្ចនៅថៃ ។ ក្នុងឆ្នាំ១៩៩៩ តំរូវការបានរើបឡើងវិញ ប៉ុន្តែមិនទាន់ដល់កំរិតមុនវិបត្តិឆ្នាំ១៩៩៧ ទេ ។ ដូច្នេះ គេអាចមើលឃើញថា កំលាំងដែលជំរុញឱ្យមានការធ្វើចំណាកស្រុកចេញបានបន្តកើនឡើង ប៉ុន្តែតំរូវការកំលាំងពលកម្មប្រែប្រួលនៅក្នុងសេដ្ឋកិច្ចនៃប្រទេសអ្នកទទួលពលករ ។

ជនចំណាកស្រុកកម្ពុជាទៅថៃ អាចកំណត់ថាជាប្រភេទអ្នកធ្វើដំណើរសំរាប់មួយរយៈពេលខ្លី ដោយមានបំណងត្រឡប់មកវិញ ។

### *លំនាំចំណាកស្រុកនៅឡាវ*

នៅឡាវ ដោយសារការពង្រីកទីក្រុង និងឧស្សាហកាវូបនីយកម្ម ជាពិសេសនៅក្រុងវៀងច័ន្ទ ប៉ាក់សេ ថាខែក និង លួងប្រាបាង ចំណាកស្រុក (ផ្ទៃក្នុង)ជនបទ-ទីក្រុងនៃពលករបានកើនឡើងក្នុងប៉ុន្មានឆ្នាំចុងក្រោយ ។ ប៉ុន្តែយើងមិនអាចពិភាក្សាលំអិតពីចំណាកស្រុកផ្ទៃក្នុងបានទេ ដោយហេតុថា ក្នុងចំណោមអង្កេតធំៗដែលបានធ្វើកន្លងមក គ្មានមួយណាបានប្រមូលពតិមានគ្រប់គ្រាន់ពីរឿងនេះសោះ ។

តាមការប៉ាន់ស្មានក្រៅផ្លូវការ ចំនួនពលករឡាវមិនស្របច្បាប់នៅថៃ មានប្រហែល ៩៥.០០០នាក់ ។ ពលករឡាវធ្វើចំណាកស្រុកទៅថៃ ពីព្រោះអាចរកចំណូលបានច្រើនជាងនៅឡាវ ទោះបីជាទូទៅ ពលករមិនស្របច្បាប់បានប្រាក់កំរៃទាបជាងពលករថៃដែលធ្វើការងារប្រហែលៗគ្នាក៏ដោយ ។ មួយចំណែកទៀត វត្តមានការងារសំរាប់រយៈពេលវែងក្នុងមួយឆ្នាំៗក៏ជាកត្តាជំរុញឱ្យធ្វើចំណាកស្រុកដែរ ។

ជនចំណាកស្រុកឡាវភាគច្រើន (ប៉ុន្តែមិនមែនទាំងអស់ទេ ) ពុំមានកន្លែងឈរជើងជាប់លាប់នៅថៃទេ ដូច្នេះនឹងត្រឡប់ចូលប្រទេសវិញនៅពេលណាមួយ ។

ឡាវបានអនុញ្ញាតឱ្យពលករបរទេសមួយចំនួនចូលមកក្នុងប្រទេសជាសំខាន់គឺដើម្បីធ្វើការងារជំនាញផ្សេងៗ ។ ពតិមានបានពីទីភ្នាក់ងារនានាស្តីពីពលករបរទេសបំរើការងារនៅឡាវ គឺប្រែប្រួលខុសគ្នាយ៉ាងច្រើន ។ អង្កេតឆ្នាំ២០០០ របស់វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចជាតិ បានរកឃើញថា ពលករបរទេស*ចុះបញ្ជី* មានចំនួន ៦.៨៨៩នាក់ ក្រសួងពលកម្ម និងសង្គមកិច្ចរាយការណ៍ថា មានពលករបរទេស ២,៣២៨នាក់ ក្នុងឆ្នាំ១៩៩៩ ទីភ្នាក់ងារសហប្រតិបត្តិការឡាវ-វៀតណាម រាយការណ៍ថា មានពលករវៀតណាម ១៥.០០០នាក់នៅឡាវក្នុងឆ្នាំ១៩៩៩,... (NSC and NERI, 2001) ។ ជាក់ស្តែង ពលករបរទេសប្រហែលមានច្រើនជាងតួលេខខាងលើទៀត ។ ពលករបរទេសភាគច្រើនគឺ ចិន វៀតណាម ឬថៃ ។ ក្នុងពេលខ្លះជនអន្តោប្រវេសន៏ខុសច្បាប់ ចូលមកជំនួសពលករក្នុងស្រុកនៅក្នុងការងារពិសេសៗ ដោយបានកាត់បន្ថយដល់សន្ទុះនៃការកសាងសមត្ថភាពក្នុងស្រុក ហើយក្នុងន័យនេះ វាជាឧបសគ្គមួយចំពោះការកាត់បន្ថយភាពក្រីក្រ ។

### *ចំណាកស្រុកផ្ទៃក្នុងនៅវៀតណាម*

ជាលក្ខណៈប្រវត្តិសាស្ត្រ ចំណាកស្រុកផ្ទៃក្នុងនៅវៀត ណាម មានលំហូរចំបងពីរៈ លំហូរទៅខាងត្បូង (ខេត្តវៀតណាមនៅភាគខាងត្បូង មានធនធានប្រសើរជាងខេត្តនៅខាងជើង) និងលំហូរពីជនបទទៅ ទីក្រុង ។ ទិន្នន័យបានបញ្ជាក់លំហូរជនចំណាកស្រុក ពីជនបទទៅទីក្រុងយ៉ាងច្រើន (Ba *et al,* 2001) ។ តាមអង្កេតកំរិតជីវភាពនៅវៀតណាមឆ្នាំ១៩៩៨ ប្រហែលពាក់កណ្តាលនៃប្រជាជននៅទីក្រុងមានទីកន្លែងកំណើតនៅឯជនបទ ។ អត្រាចំណាកស្រុកពីតំបន់មួយទៅតំបន់មួយក៏ប្រែប្រួលខុសគ្នាច្រើនដែរ ឧ. តំបន់ខ្ពង់រាបភាគកណ្តាលមានអត្រាជនចំណាក ស្រុកចូលខ្ពស់បំផុត ដែលភាគច្រើនមកពីតំបន់មាត់សមុទ្រភាគខាងត្បូង-កណ្តាល (ដែលបញ្ជាក់ពីការបែងចែកធនធានមិនស្មើគ្នា) ។

ផ្ទុយពីជនចំណាកស្រុកកម្ពុជា, ជនចំណាកស្រុកវៀតណាមភាគច្រើនធ្វើដំណើរដោយមានបំណងទៅតាំងលំនៅ ឬរស់នៅរយៈពេលវែងនៅកន្លែងថ្មី ។ ជាក់ស្តែងពួកគេផ្លាស់លំនៅពីតំបន់ក្រខ្សត់ធនធាន ទៅកាន់តំបន់សំបូណ៌ធនធានជាង ហើយជូនកាលគេធ្វើវិនិយោគ ឬធ្វើការងារក្នុងសកម្មភាពនានាដែលមិនដើរតាមរដូវកាល ហើយដែលប្រើជំនាញ ។ ដង់ស៊ីតេប្រជាជនខ្ពស់ក្នុងតំបន់ខ្លះក៏ជាកត្តាជំរុញមួយដែរ ។

ទោះជាយ៉ាងនេះក្តី លំហូរចំណាកស្រុកមិនអាចកាត់បន្ថយការពឹងផ្អែកយ៉ាងធំរបស់ប្រជាកសិករទៅលើកសិកម្មជីវព្រឹត្តិ (subsistence agriculture) ទេ ។

### *ចំណាកស្រុកអន្តរជាតិចេញពីវៀតណាម*

ក្នុងទសវត្សរ៍១៩៨០ មានចំណាកស្រុកពលករយ៉ាងច្រើនទៅកាន់អតីតសហភាពសូវៀត និងបណ្តាប្រទេសក្នុងប្លុកអឺរ៉ុបខាងកើត (ប្រហែល ២០០.០០០នាក់) ។ មកដល់ទសវត្សរ៍១៩៩០ ពួកគេភាគច្រើនបានត្រឡប់ទៅវៀតណាមវិញហើយ ។ ចំណាកស្រុកមួយសារក្រោយទៀតទៅកាន់ប្រទេសជប៉ុន កូរ៉េ មជ្ឈិមបូពា៌ និងអាហ្វ្រិកខាងកើត បានចាប់ផ្តើមក្នុងទសវត្សរ៍១៩៩០ និងមានប្រហែល ៦០-៧០ពាន់នាក់ ។ មានលំហូរចំណាកស្រុកមួយទៀតបានចាប់ផ្តើមតាំងពីដើមទសវត្សរ៍១៩៨០ ឆ្ពោះទៅកាន់ប្រទេសឡាវ បន្ទាប់មកទៅកម្ពុជា ។ នៅឡាវ ជនចំណាកស្រុកវៀតណាមមានសកម្មភាពជាសំខាន់នៅក្នុងការងារប្រើជំនាញទាប ។ ការប៉ាន់ស្មានពីចំនួន និងការងាររបស់ជនចំណាកស្រុកវៀតណាមនៅកម្ពុជា អាចធ្វើឡើងបាននៅពេលនេះ តែតាមរយៈអង្កេតគំរូតាងតូចៗរបស់ វិបសអ ដូចមានបង្ហាញជូននៅខាងក្រោម (So, 2001; Chan and So, 1999) ។

**ជនចំណាកស្រុកផ្ទៃក្នុងប្រទេសកម្ពុជាបានបញ្ជាក់ថា មូលហេតុចំបងនៃការធ្វើចំណាកស្រុក គឺស្វែងរកការងារធ្វើ ហើយហេតុផលទីពីរ គឺតំរូវការទៅតាមគ្រួសារ ។ ក្នុងករណីជាច្រើន ហេតុផលខាងគ្រួសារក៏ជាប់ទាក់ទងនឹងរឿងការងារដែរ ពីព្រោះជនចំណាកស្រុក និងសហព័ទ្ធរបស់គេត្រូវធ្វើដំណើរជាមួយគ្នាដើម្បីស្វែងរកការងារធ្វើ ។**

ក្នុងទសវត្សរ៍១៩៨០ ជនចំណាកស្រុកវៀតណាមបានចាប់ផ្តើមត្រឡប់មកវិញជាបណ្តើរៗក្រោយពីបានធ្វើមាតុភូមិនិវត្តន៍ក្នុងទសវត្សរ៍១៩៧០ ។ ក្នុងទសវត្សរ៍១៩៩០ ជនចំណាកស្រុកច្រើនទៀតត្រូវបានទាក់ទាញដោយការបើកចំហសេដ្ឋកិច្ចទីផ្សារយ៉ាងឆាប់រហ័សនៅកម្ពុជា ។ អ្នកសិក្សាខាងប្រជាសាស្រ្តបានគណនាថា នៅចុងទសវត្សរ៍១៩៩០ នៅកម្ពុជាមានជនអន្តោប្រវេសន៏ជាងមួយលាននាក់បន្តិច ក្នុងនេះមួយភាគធំណាស់ចូលមកពីវៀតណាម ។

ជនចំណាកស្រុកវៀតណាមមកធ្វើនេសាទនៅកម្ពុជា ពីព្រោះមានការប៉ិនប្រសប់ជាងគេក្នុងរបរនេះ ហើយវាជាមូលហេតុធ្វើឱ្យពួកគេបានជោគជ័យល្អក្នុងការរក្សាការក្តោបក្តាប់របស់ខ្លួនទៅលើវិស័យនេះនៅកម្ពុជា ។ នៅភ្នំពេញពួកគេធ្វើជាកម្មករសំណង់ អ្នកលក់ដូរ កម្មករជំនាញក្នុងហាងជួសជុលគ្រឿងយន្ត និងគ្រឿងអគ្គិសនីក្នុងសហគ្រាសកែច្នៃឈើ... ។ នៅកម្ពុជា ប្រហែល ៨០% នៃអ្នកម៉ៅការតូចៗ និងមេការនៅ ក្នុងឧស្សាហកម្មសំណង់ ប្រហែលមានដើមកំណើត វៀតណាម ។ ការសិក្សាដល់ទីកន្លែងបានបង្ហាញថា ពួកនិយោជកចូលចិត្តជួលពលករវៀតណាម ពីព្រោះមានជំនាញខ្ពស់ជាងធ្វើការខ្លាំង ជាង និងអំណត់ជាង ។

វៀតណាមមានលក្ខណៈចំលែកមួយ ព្រោះមានកំលាំងពលកម្មមានជំនាញខ្ពស់គួរសម ប៉ុន្តែមានសមត្ថភាពតូចក្នុងការប្រើប្រាស់ពលកម្មនេះ ។

### មូលហេតុនៃការធ្វើចំណាកស្រុក ប្រាក់ចំណូល លក្ខខណ្ឌធ្វើការងារ និងភាពក្រីក្រ

តាមជំរឿនឆ្នាំ១៩៩៨, ជនចំណាកស្រុកផ្ទៃក្នុងប្រទេសកម្ពុជាបានបញ្ជាក់ថា មូលហេតុចំបងនៃការធ្វើចំណាកស្រុក គឺស្វែងរកការងារធ្វើ (២៩%នៃចំនួនសរុប) ហើយហេតុផលទីពីរគឺតំរូវការទៅតាមគ្រួសារ (២៥%) ។ ក្នុងករណីជាច្រើន ហេតុផលខាងគ្រួសារក៏ជាប់ទាក់ទងនឹងរឿងការងារដែរ ពីព្រោះជនចំណាកស្រុក និងសហព័ទ្ធរបស់គេត្រូវធ្វើដំណើរជាមួយគ្នាដើម្បីស្វែងរកការងារធ្វើ ។

គំលាតប្រាក់កំរៃរវាងកាងារកសិកម្ម និងការងារគ្មានជំនាញនៅភ្នំពេញមានទំហំគួរឱ្យកត់សំគាល់: អ្នកស៊ីឈ្នួលធ្វើស្រែបានកំរៃប្រហែល ៤.០០០រៀល/ថ្ងៃ (ប្រហែល ១ដុល្លារ) ឯប្រាក់កំរៃជាទូទៅនៅក្នុងក្រុង សំរាប់កម្មករគ្មានជំនាញ/ពាក់កណ្តាលជំនាញ គឺប្រហែល ៦.០០០-១០.០០០រៀល/ថ្ងៃ (Pon and Acharya, 2001) ។ កម្មករកាត់ដេរដែលភាគច្រើនជាជនចំណាកស្រុក អាចរកកំរៃបាន ៦០-៧៥ដុល្លារ/ខែ (Sok *et al*, 2001) ។ លើសពីនេះទៀត នៅជនបទការងារមានមិនលើសពីពីរ-បីខែទេ ប៉ុន្តែនៅទីក្រុងលទ្ធភាពមានការងារមិនគួរឱ្យកត់សំគាល់ទៅនឹងរដូវកាលទេ ។ ចំនួនថ្ងៃធ្វើការច្រើនធ្វើឱ្យកើនចំណូល ។ ទោះបីក្នុងចំណាកស្រុកពីជនបទទៅជនបទ ក៏ដោយ ក៏ប្រជាជនធ្វើដំណើរចេញពីតំបន់ដាំដុះតែមួយលើកទៅកាន់តំបន់ដាំដុះពីរ លើក ឬទៅនេសាទ កាប់ឈើ ឬធ្វើការនៅការដ្ឋានសាងសង់ ។

ចំពោះពលករកម្ពុជាដែលទៅធ្វើការនៅថៃ គំលាតប្រាក់កំរៃគឺជាចំណុចទាក់ទាញសំខាន់: ប្រាក់កំរៃនៅថៃអាចខ្ពស់ជាងនៅកម្ពុជាដល់ទៅ ២-៦ដង សំរាប់ការងារប្រហាក់ប្រហែលគ្នា (So, 2001) ។

ប៉ុន្តែ ការរស់នៅក្នុងប្រទេសថៃ មិនបានងាយស្រួលទេសំរាប់ជនចំណាកស្រុកកម្ពុជា ។ ដោយហេតុថា ភាគច្រើនគឺជាជនចំណាកស្រុកមិនស្របច្បាប់ ដូច្នេះត្រូវប្រឈមមុខនឹងការរំខានរុកគួន ការបង់សំណូកច្រើនៗ និងការជំរិតយកប្រាក់ ។ ក្នុងអង្កេតរបស់ វិបសអ អ្នកឆ្លើយសំភាសន៏បានប្រាប់ថា ចំណាកស្រុកអាចបង្ករការលំបាកដល់អ្នកនៅឯផ្ទះ ដូចជា ឪពុក-ម្តាយចាស់ៗគ្មានអ្នកណាជួយថែទាំ ចោរលួចទ្រព្យសម្បត្តិ គេរំលោភយកដី... ប៉ុន្តែគេនៅតែធ្វើចំណាកស្រុក ហើយជាក់ស្តែងភាគច្រើនអាចរកប្រាក់បាន និងអាចទទួលបានជំនាញខ្លះៗ ។

អង្កេតរបស់ វិបសអ ក៏ដូចជាការស្រាវជ្រាវនៅវៀតណាមបង្ហាញថា ផលប្រយោជន៏ខាងសេដ្ឋកិច្ច គឺជាមូលហេតុចំបងនៃលំហូរជនចំណាកស្រុកវៀតណាម ។ សឹងតែគ្រប់គ្នាបានរាយការណ៏ពីលទ្ធភាពរកប្រាក់កាសប្រសើរជាង ដោយសារកង្វះពលករជំនាញនៅកម្ពុជាបានផ្តល់ឱកាសឱ្យជនអន្តោប្រវេសន៏វៀតណាមចូលធ្វើការជាមេជាងសំណង់ អ្នកកែច្នៃឈើ អ្នកជួសជុលម៉ាស៊ីន... ។ ការត្រួតពិនិត្យអន្តោប្រវេសន៏ទន់ខ្សោយ និងការអនុគ្រោះផ្សេងៗ ជាថ្នូរនឹងការបង់ប្រាក់កំរៃក្រៅផ្លូវការនៅក្នុងប្រទេសកម្ពុជាបានជួយសំរួលដល់លំហូរពលករចូល ។

អ្នកនេសាទវៀតណាមធុនតូច និងមធ្យម រកបានជាមធ្យម ១០.០០០រៀល/ថ្ងៃ គឺច្រើនជាងពីរ ដុល្លារ ដែលជាកំរិតប្រាក់កំរៃនៃបន្ទាត់ក្រីក្រស្រាលនៃធនាគារពិភពលោក ។ អ្នកផ្តល់ពត៌មានបានបញ្ជាក់ ថា ប្រាក់កំរៃមានកំរិតខ្ពស់ជាងនេះយ៉ាងច្រើននៅក្នុង អាជីវកម្មនេសាទធុនមធ្យម និងធុនធំ ដែលភាគច្រើន កាន់កាប់ដោយជនចំណាកស្រុកវៀតណាម ។ អ្នកម៉ៅការនេសាទវៀតណាមបានប្រជែងដណ្តើមយកសម្បទាននេសាទ ហើយជាញឹកញយពួកគេបានទទួលជោគជ័យ ពីព្រោះមានសមត្ថភាពខ្ពស់ជាងទាំងខាងបច្ចេកទេសនេសាទ និងការរកស៊ី។ ចំពោះចំណុចមិនអំណោយផលវិញ គឺមានការកើតឡើងយ៉ាង

ច្រើននូវកន្លែងត្រួតពិនិត្យក្រៅផ្លូវការដែលទាមទារឱ្យបង់ប្រាក់កំរៃផ្សេងៗ ។ ដើម្បីដោះស្រាយការទាមទារច្រើនហួសហេតុនេះ អ្នកនេសាទបានប្រើវិធីនេសាទខុសច្បាប់ដែលបង្ករអន្តរាយដល់មច្ឆាជាតិ ។ អ្នកឆ្លើយសំភាសន៍បានឱ្យដឹងថា បរិមាណត្រីដែលចាប់បាននៅក្នុងតំបន់អង្កេតធ្លាក់ចុះប្រហែល ៤0% នៅចុងទសវត្សរ៍១៩៩0 បើធៀបនឹងទសវត្សរ៍ ១៩៨0 ។

តើចលនាពលករដូចខាងលើ មានផលប៉ះពាល់យ៉ាងដូចម្តេចទៅលើភាពក្រីក្រ? ភស្តុតាងនានាបានបង្ហាញថា ក្នុងករណីភាគច្រើនគឺរវាងកន្លែងដើមទី និងកន្លែងគោលដៅនៃចំណាកស្រុក ប្រាក់កំរៃមានកំរិតខុសគ្នា ក្នុងករណីមួយចំនួនផ្សេងគឺវត្តមាននៃការងារ ឬរយៈពេលវែងជាងនៃការងារ និងក្នុងករណីខ្លះៗទៀតគឺដំណើរការរៀនសូត្រដែលជួយឱ្យពលករអាចចូលធ្វើការបាននៅក្នុងមុខងារមានប្រាក់កំរៃខ្ពស់ ។ ដូច្នេះ យូរៗទៅពលករកាន់តែចល័តខ្លាំងឡើង ដោយសុខចិត្តធ្វើដំណើរកាន់តែឆ្ងាយ និងកាន់តែហ៊ានប្រថុយនឹងហានិភ័យ ។ ក្នុងទិដ្ឋភាពនេះ ចំណាកស្រុកគឺជាឧបករណ៍មួយដ៏ខ្លាំងក្លាសំរាប់ប្រយុទ្ធនឹងភាពក្រីក្រ ។

**ចលនាពីកន្លែងមួយទៅកន្លែងមួយនៃកំលាំងពលកម្ម បានជួយកាត់បន្ថយភាពក្រីក្រ ។ ក្នុងន័យនេះ ត្រូវផ្តល់សារៈសំខាន់ដល់គោលនយោបាយចំណាកស្រុកដែលមានលក្ខណៈសមស្រប ។ ព្រមគ្នានេះដែរ គេត្រូវផ្តល់សារៈសំខាន់ប៉ុនគ្នាដល់គោលនយោបាយដែលលើកកំពស់ការលូតលាស់មានតុល្យភាពនៅក្នុងតំបន់ លើកទឹកចិត្តដល់សកម្មភាព និងឧស្សាហកម្ម នានាដែលប្រើពលកម្មច្រើន និងជួយកសាងធនធានមនុស្សឱ្យបាន**

ចំពោះឥទ្ធិពលប្រយោលវិញ ទិន្នន័យពីប្រភពផ្សេងៗបង្ហាញថា ក្នុងករណីភាគច្រើន ទោះបីជាចំណាកស្រុកក្នុងប្រទេសឬឆ្លងដែនក្តី ពួកគេអាចផ្ញើប្រាក់មកផ្ទះបាន ។ ការផ្ញើប្រាក់នេះ វាជួយរក្សាស្ថិរភាពសន្តិសុខស្បៀងនៅឯផ្ទះក្នុងភូមិកំណើត និងអាចសន្សំបានជាទុនខ្លះផង ។ ក្នុងករណីមួយចំនួនតូច វាជាផ្លូវមួយសំរាប់ឱ្យជនចំណាកស្រុកក្នុងពេលអនាគតចូលទៅក្នុងទីផ្សារពលកម្មខាងក្រៅ ។ បន្ទាប់មកទៀត ការចាយវាយនូវប្រាក់កាសផ្ញើមកផ្ទះ វាជួយបង្កើតការងារឱ្យជនក្រីក្រដែលមិនអាចធ្វើចំណាកស្រុកបាន ។ ឥទ្ធិពលប្រយោលក៏មានរូបភាពជាការបំពេញចន្លោះប្រហោងនៅក្នុងផ្នែកខ្លះនៃទីផ្សារពលកម្មជាគោលដៅនៃចំណាកស្រុក ហើយសេដ្ឋកិច្ចក៏ត្រូវបានកែលំអតាមនេះ ។ ផលប៉ះពាល់អាក្រក់ក៏មានខ្លះដែរ ប៉ុន្តែចំពោះជនចំណាកស្រុក ផលអាក្រក់នេះវាមិនធ្ងន់ធ្ងរទេ បើធៀបនឹងផលចំណេញដែលបានលើកឡើងហើយ ។

ការរៀបរាប់នៅខាងលើបានបង្ហាញថែមទៀតថា ទោះបីពលករទាំងអស់មានមូលហេតុដូចគ្នា (បង្កើនប្រាក់ចំណូល និងកំរិតជីវភាព) ប៉ុន្តែគេមានសមាសភាព លក្ខខណ្ឌធ្វើការងារ និងសន្តិសុខខាងសង្គមកិច្ចមិនដូចគ្នាទេ ។ ធនធានមនុស្ស បណ្តាញសង្គមកិច្ច និងលទ្ធភាពរកឃើញតំរូវការពិសេសៗក្នុងទីផ្សារពលកម្ម វាមានសារៈសំខាន់ខ្លាំងណាស់ ដោយជួយឱ្យជនចំណាកស្រុកមានជំហរល្អក្នុងការចរចា ។ សរុបមក ចំណាកស្រុកមានផលប៉ះពាល់មិនស្មើគ្នាទេ ។

## អំពីគោលនយោបាយ

កម្ពុជា និងឡាវ មិនទាន់បានអនុវត្តវិធានការ ដើម្បីជំរុញ ឬត្រួតពិនិត្យយ៉ាងសកម្មនូវចំណាកស្រុកក្នុងប្រទេស ឬអន្តរជាតិ ដូចដែល ថៃ ហ្វីលីពិន ឬ បឹងក្លាដេស អនុវត្តន៍នោះទេ ។ នៅកម្ពុជា គេអាចមើលឃើញច្បាស់តែគោលនយោបាយមួយសំដៅកាត់បន្ថយចំណាកស្រុកជនបទ-ទីក្រុង និងផ្តល់ដីឱ្យអ្នកគ្មានដីធ្លីដែលរស់នៅជនបទ ដើម្បីឱ្យគេ អាចរកចិញ្ចឹមជីវិតបាននៅឯមូលដ្ឋាន ។ វៀតណាមមានគោលនយោបាយជាក់លាក់សំរាប់តែ ចំណាកស្រុកអន្តរជាតិប៉ុណ្ណោះ ។ នៅឆ្នាំ២000 ទាំងក្រុមហ៊ុនរដ្ឋ និងឯកជន បានទទួលការ អនុញ្ញាតឱ្យចូលរួមក្នុងការនាំចេញពលកម្ម ។ ប៉ុន្តែចំពោះចំណាកស្រុកក្នុងប្រទេស និងចំណាកស្រុកឆ្លងដែនវិញ សព្វថ្ងៃមិនទាន់ឃើញមានជំហរជាផ្លូវការអ្វីច្បាស់លាស់ទេ ។

ចលនាពីកន្លែងមួយទៅកន្លែងមួយនៃកំលាំងពលកម្ម បានជួយកាត់បន្ថយភាពក្រីក្រ ។ ប៉ុន្តែតាមបែបបទល្អ ចំណាកស្រុកត្រូវតែដឹកនាំដោយតំរូវការ ទើបការចែកចាយកំលាំងពលកម្មបំរើផលប្រយោជន៍សង្គមបានប្រសើរបំផុត ។ ក្នុងន័យនេះ ត្រូវផ្តល់សារៈសំខាន់ដល់គោលនយោបាយចំណាកស្រុក ដែលមានលក្ខណៈសមស្រប ។


## Consider an Annual Subscription to all CDRI Publications

For one convenient fee, which includes delivery, it is now possible to receive all the publications CDRI produces in a calendar year. This subscription includes:

1. **4 to 6 Working Papers**, each of which presents the results of one of CDRI's studies.
2. The collected papers from the annual Development Analysis Network (DAN) study which CDRI coordinates with 6 other DAN-member research institutes in Cambodia, Thailand, Laos, and Vietnam.
3. **4 issues of CDRI's quarterly journal**, *Cambodia Development Review*, which publishes articles on the latest socio-economic research, key development issues and analysis of the Cambodian and regional economies.
4. **4-6 *Policy Briefs*** which summarise findings and policy recommendations from important CDRI studies.
5. **Monthly bilingual (English and Khmer) *Flash Reports*** which provide a snap shot of the Cambodian and regional economies.
6. **The *Annual Economic Review*,** analyses trends in key sectors of the Cambodian economy and presents comprehensive analysis of economic development and refom policy, plus key indicators of economic performance.

*A **subscription** to all of CDRI's publications **for 2002** can be purchased anytime during the calendar year, and all materials published in 2002 prior to commencement of the subscription, will be shipped immediately.*

For prices and more information, please contact **Publications section** at **CDRI, 56, street 315, Tuol Kork, Phnom Penh, Cambodia, Tel: (023) 880-734 / 883-603, Fax: (023) 366-094, email: pubs@cdri.forum.org.kh**

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

ទិន្នន័យសេដ្ឋកិច្ចថ្មីៗបង្ហាញថា ធៀបនឹងត្រីមាសទី២ ឆ្នាំ២០០១ សភាពការណ៍សេដ្ឋកិច្ចពិភពលោកបានធ្លាក់ចុះនៅក្នុងត្រីមាសទី៣ នេះ ។ ភាពគ្មានការងារធ្វើ និងភាពក្រីក្របានកើនឡើង ។ ដើម្បីទ្រទ្រង់ដល់សេដ្ឋកិច្ចរៀងៗខ្លួន ធនាគារកណ្តាលក្នុងប្រទេសជាច្រើនបានបន្តជំរុញតំរូវការក្នុងស្រុកដោយបន្ធូរគោលនយោបាយខាងឥណទានតាមរយៈការកាត់បន្ថយអត្រាការប្រាក់ ។ ដោយមូលហេតុនេះ អត្រាអតិផរណានៅក្នុងពិភពលោកបានថយចុះមួយកំរិត ទោះបីអត្រាប្តូរប្រាក់និងថ្លៃផលិតផលផលក្នុងទីផ្សារពិភពលោកមានការប្រែប្រួលចុះឡើងមិនទៀងទាត់ក៏ដោយ ។

## កំណើនសេដ្ឋកិច្ចពិភពលោក

តាមទិន្នន័យសេដ្ឋកិច្ចថ្មីៗបំផុត ព្រឹត្តិការណ៍ខែកញ្ញានៅសហរដ្ឋអាមេរិក បានធ្វើឱ្យកាន់តែយ៉ាប់យ៉ឺនថែមទៀតលើសេដ្ឋកិច្ចប្រទេសភាគច្រើន ដែលសព្វថ្ងៃកំពុងតែធ្លាក់ចុះ ។ ផលិតកម្មឧស្សាហកម្មសហរដ្ឋអាមេរិកក្នុងរយៈមួយឆ្នាំមកដល់ខែតុលា ២០០១ បានធ្លាក់ចុះដល់ -៦,៤% ធៀបនឹង -៣,២%មកដល់ខែកក្កដា ។ នៅជប៉ុនផលិតកម្មឧស្សាហកម្មកាន់តែធ្លាក់ធ្ងន់ធ្ងរជាងនេះគឺ-១១,៩%ក្នុងរយៈមួយឆ្នាំមកដល់ខែតុលា ធៀបនឹង -៨,៥%មកដល់ខែកក្កដា ។ ប៉ុន្តែនៅអឺរ៉ុប សន្ទស្សន៍ផលិតកម្មឧស្សាហកម្មគ្មានការប្រែប្រួលទេក្នុងរយៈពេលនេះ ។ ដើម្បីគ្រប់គ្រងការធ្លាក់ចុះសេដ្ឋកិច្ច ធនាគារកណ្តាលសហរដ្ឋអាមេរិកបានបញ្ចុះអត្រាការប្រាក់រយៈពេលខ្លីជាថ្មីទៀតនៅដើមខែធ្នូ ២០០១ ដែលជាការបញ្ចុះលើកទី១១ ក្នុងឆ្នាំ២០០១។ ប៉ុន្តែនយោបាយរូបិយវត្ថុនេះត្រូវការពេលមួយរយៈ ដើម្បីហុចលទ្ធផល ។

ការធ្លាក់ចុះសេដ្ឋកិច្ចនៅបស្ចិមប្រទេស បានអូសទាញឱ្យសេដ្ឋកិច្ចប្រទេសអាស៊ីមួយចំនួនធ្លាក់ចុះដែរ។ នៅសិង្ហបុរី និងតៃវ៉ាន់ សេដ្ឋកិច្ចមានកំណើនអវិជ្ជមានអស់ពីរត្រីមាសហើយ (គិតត្រឹមត្រីមាសទី៣ ឆ្នាំ ២០០១) ឯសេដ្ឋកិច្ចហុងកុង និងម៉ាឡេស៊ីក៏គេចមិនផុតពីការធ្លាក់ចុះដែរ។ ពីត្រីមាសទី៣ ឆ្នាំ២០០០ ដល់ត្រីមាសទី៣ ឆ្នាំ ២០០១ កំណើន ផសស ពិត បានធ្លាក់ចុះ ៥,៦%នៅសិង្ហបុរី ៤,២%នៅតៃវ៉ាន់, ១,៣%នៅម៉ាឡេស៊ី និង ០,៣%នៅហុងកុង ។ ប៉ុន្តែប្រទេសចិនមានកំណើនសេដ្ឋកិច្ចមាំមួនដដែល (ផសស កើន ៧%ក្នុងត្រីមាសទី៣) ទោះបីការនាំចេញបានធ្លាក់ចុះខ្លាំងក៏ដោយ ។ សន្ទុះនេះកើតចេញមួយចំណែកពីវិនិយោគផ្ទាល់ពីបរទេស ដែលនៅតែបន្តហូរចូលប្រទេសចិន (ប្រហែល ៤០ពាន់លានដុល្លារតាំងពីឆ្នាំ១៩៩៤) ។ ដោយសារការធ្លាក់ចុះសេដ្ឋកិច្ចទូទាំងពិភពលោក តំរូវការនៅក្រៅប្រទេសបានថយចុះ ដូច្នេះចិនត្រូវជួបបញ្ហាប្រឈមនៃការជំរុញតំរូវការក្នុងស្រុក ដើម្បីរក្សាសន្ទុះកំណើនសេដ្ឋកិច្ច ។ តាមពិត តំរូវការក្នុងស្រុកនៅប្រទេសចិន បានកើនមួយកំរិតហើយ ។ ក្នុង ៧ខែដើមឆ្នាំនេះ សកម្មភាពលក់រាយក្នុងស្រុកបានកើនប្រហែល ១០% ឯវិនិយោគខាងសំណង់អគារផ្សេងៗបានកើន ៣០% ។

ផលប៉ះពាល់ខាងសង្គមកិច្ចនៃការធ្លាក់ចុះសេដ្ឋកិច្ចកាន់តែមើលឃើញច្បាស់។នៅសហរដ្ឋអាមេរិក អត្រាគ្មានការងារធ្វើកើនដល់ ៥,៤% នៃកំលាំងពលកម្មក្នុងខែ តុលា ២០០១, ធៀបនឹង ៤,៥%ក្នុងខែកក្កដា, និង ៣,៩% កាលពីមួយឆ្នាំមុន ។ នៅជប៉ុនអត្រាគ្មានការងារធ្វើកើនដល់ ៥,៤%ក្នុងខែតុលា ធៀបនឹង ៥% ក្នុងខែកក្កដា និង ៤,៧%កាលពីមួយឆ្នាំមុន ។ ក្នុងតំបន់អឺរ៉ូ អត្រាគ្មានការងារធ្វើនៅនឹងត្រឹម ៨,៣%នៃកំលាំងពលកម្មក្នុងត្រីមាសទី៣, ធៀបនឹង ៨,៨%កាលពីមួយឆ្នាំមុន ។ នៅក្នុងប្រទេសមួយចំនួនដែលទើបធ្វើឧស្សាហភាវូបនីយកម្មថ្មី ផលប៉ះពាល់ខាងសង្គមកិច្ចទៅលើប្រជាជនក៏មានលក្ខណៈគួរឱ្យបារម្ភដូចគ្នា ។ តាមទស្សនាវដ្តី Far Eastern Economic Review, រដ្ឋាភិបាលម៉ាឡេស៊ីរំពឹងថា នៅចុងឆ្នាំ ២០០១ នឹងមានប្រជាជន ជាង ៣៩០.០០០នាក់ត្រូវបាត់បង់ការងារ ហើយអត្រាគ្មានការងារធ្វើនឹងកើនដល់ ៣,៩% ធៀបនឹង ៣,១% ក្នុងឆ្នាំ ២០០០ ។ នៅហុងកុង អត្រាគ្មានការងារធ្វើកើនដល់ ៥,៣%ក្នុងត្រីមាសទី៣ ធៀបនឹង ៤,៦%កាលពីត្រីមាសមុន ។ នៅថៃ ភាពក្រីក្រកាន់តែរីកធំឡើងគឺចំនួនអ្នកក្រកើនដល់ប្រហែល ១០លាននាក់ក្នុងឆ្នាំ២០០១ ធៀបនឹង ៧លាននាក់កាលពីឆ្នាំ១៩៩៦ (តាមតួលេខផ្សព្វផ្សាយថ្មីរបស់ធនាគារពិភពលោក) ។

កម្ពុជាមានស្ថានភាពប្លែកពីគេ ជាពិសេសក្នុងពេលសព្វថ្ងៃនេះ ពីព្រោះបែរជាបានអត្ថប្រយោជន៍ពីភេរវកម្មវាយប្រហារនៅអាមេរិក ។ ឧទាហរណ៍ ក្នុងអាជីវកម្មខាងសំលៀកបំពាក់ អតិថិជននៅអាមេរិក និងអឺរ៉ុប បានបង្កើនការបញ្ជាទិញសំលៀកបំពាក់ពីកម្ពុជា ដោយកាត់បន្ថយបរិមាណទិញពីប្រទេសអ៊ីស្លាមនានា (ឧ. ប៉ាគីស្ថាន បង់ក្លាដេស ឥណ្ឌូណេស៊ី...) ។ សភាពការណ៍នេះអាចមើលឃើញយ៉ាងច្បាស់ក្នុងខែតុលា ។ បច្ចុប្បន្ន និន្នាការកាត់បន្ថយការងារក្នុងវិស័យនេះហាក់ដូចជាលែងមានហើយជាក់ស្តែង កម្មកររោងចក្រកាត់ដេរបានចាប់ផ្តើមធ្វើការងារបន្ថែមម៉ោងទៀតផង ។ ដូចគ្នានេះដែរ ស្ថានការណ៍ក្នុងវិស័យទេសចរណ៍ហាក់ដូចជាគ្មានការប៉ះពាល់អ្វីទេ ។ ទេសចរដែលភាគច្រើនមកពីបណ្តាប្រទេសនៅអាស៊ី ដែលពីមុនរំពឹងថា ទៅធ្វើទស្សនកិច្ចនៅអាមេរិក ឥឡូវនេះបែរជាធ្វើដំណើរមកខាងប្រទេសអាស៊ី មិនកាន់អ៊ីស្លាមវិញ ក្នុងនេះមានទាំងប្រទេសកម្ពុជាផង ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់ក្នុងទីផ្សារអន្តរជាតិ

ការបន្តធ្លាក់ចុះតំរូវការក្នុងពិភពលោក និងការបញ្ចុះអត្រាការប្រាក់បាននាំឱ្យមានការថយចុះអតិផរណាក្នុងពិភពលោក ។ នៅអាមេរិក អតិផរណាថយចុះដល់ ២,១% ក្នុងខែតុលា ២០០១ ធៀបនឹង ២,៧%ក្នុងខែកក្កដា និង ៣,៤% កាលពីមួយឆ្នាំមុន ។ ក្នុងតំបន់អឺរ៉ូ អតិផរណាថយចុះដល់ ២,៤%ក្នុងខែតុលា ២០០១ ធៀបនឹង ២,៨%ក្នុងខែកក្កដា និង ២,៧%កាលពីមួយឆ្នាំមុន ។ នៅអាស៊ី អតិផរណាក្នុងប្រទេសជាច្រើនមាននិន្នាការប្រហាក់ប្រហែលនេះដែរ។ នៅជប៉ុន អតិផរណានៅតែអវិជ្ជមានដដែល ។

អនាគតសេដ្ឋកិច្ចមិនច្បាស់លាស់ បានធ្វើឱ្យអត្រាប្តូរប្រាក់ឡើងចុះយ៉ាងខ្លាំងក្នុងទីផ្សារអន្តរជាតិ ។ ពីខែកញ្ញា ដល់ពាក់កណ្តាលខែធ្នូ ២០០១, ដុល្លារ អាមេរិកមានភាពនឹងនជាទូទៅធៀបនឹងប្រាក់អឺរ៉ូ ទោះបីវាមានការប្រែប្រួលចុះ ឡើងពីមួយថ្ងៃទៅមួយថ្ងៃក៏ដោយ (ក្នុងរង្វង់ ១,០៩អឺរ៉ូ ក្នុងមួយដុល្លារអាមេរិក) ។ ក្នុងរយៈពេលនេះ ដុល្លារអាមេរិកបានឡើងថ្លៃធៀបនឹងរូបិយវត្ថុជប៉ុន ដោយមួយដុល្លារប្តូរបាន ១២៧ យ៉េននៅពាក់កណ្តាលខែធ្នូ ធៀបនឹង ១១៨យ៉េន កាលពីដើមខែកញ្ញា ។ ដុល្លារអាមេរិកក៏ឡើងថ្លៃគួរឱ្យកត់សំគាល់ធៀបនឹងដុល្លារសិង្ហបុរី គឺមួយដុល្លារអាមេរិក ប្តូរបាន ១,៨៤ដុល្លារសិង្ហបុរីនៅពាក់កណ្តាលខែធ្នូ ធៀបនឹង ១,៧៥ ដុល្លារសិង្ហបុរីកាលពីដើមខែកញ្ញា ។ ប៉ុន្តែក្នុងរយៈពេលដដែលនេះ ដុល្លារអាមេរិកមានស្ថិរភាពធៀបនឹងប្រាក់បាតថៃ ប្រាក់រីងហ្គីតម៉ាឡេស៊ី និងប្រាក់វ៉ុនកូរ៉េខាងត្បូង ។

## ថ្លៃផលិតផលក្នុងទីផ្សារពិភពលោក

ក្រៅពីអង្ករ ថ្លៃផលិតផលផ្សេងៗក្នុងទីផ្សារពិភពលោកបានធ្លាក់ចុះនៅត្រីមាសទី៣ ឆ្នាំ២០០១ ។ ថ្លៃអង្ករលេខ១ នៅបាងកកបានរើបឡើងវិញបន្តិចដោយលក់បាន ១៧០ដុល្លារ/តោនក្នុងត្រីមាសទី៣ ឆ្នាំ២០០១ (ធៀបនឹង ១៦៥ ដុល្លារ/តោនក្នុងត្រីមាសមុន) ប៉ុន្តែវានៅទាបជាងកាលពីត្រីមាសទី៣ ឆ្នាំ២០០០ (១៨៥ដុល្លារ/តោន) ។ ថ្លៃសណ្តែកសៀង, ឈើ, និងកៅស៊ូ, បានបន្តធ្លាក់ចុះ ។ គួរកត់សំគាល់ដែរថា ការធ្លាក់ចុះសេដ្ឋកិច្ចក្នុងទូទាំងពិភពលោក បានជះឥទ្ធិពលសង្កត់ថ្លៃប្រេងឆៅឱ្យធ្លាក់ចុះមួយកំរិត ។ ក្នុងត្រីមាសទី២ ឆ្នាំ២០០១ ប្រេងឆៅនៅឌូបៃ លក់បាន

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

## តារាង១. កំនើន GDP ពិតនៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ១៩៩៩-២០០១ (កំណើនភាគរយធៀបនឹងឆ្នាំមុន)

| | 1999 | | 2000 | | | | 2001 | | 2000 | 2001* |
|---|---|---|---|---|---|---|---|---|---|---|
| | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q1-Q4 | Q1-Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | - | - | - | - | - | - | - | - | 4.0 | 4.5 |
| ឥណ្ឌូនេស៊ី | 5.8 | 3.2 | 4.1 | 5.1 | 5.2 | 4.0 | 3.5 | 3.5 | 4.8 | 4.0 |
| ម៉ាឡេស៊ី | 10.6 | 11.9 | 8.7 | 7.7 | 6.6 | 3.2 | 0.5 | -1.3 | 8.6 | 3.0 |
| សិង្ហបុរី | 7.1 | 9.1 | 8.0 | 10.4 | 10.5 | 4.5 | -0.9 | -5.6 | 9.9 | 2.0 |
| ថៃ | 6.5 | 5.2 | 6.6 | 2.6 | 3.1 | 1.8 | 1.9 | - | 4.3 | 2.5 |
| វៀតណាម | - | - | - | - | - | - | - | - | 6.8 | 5.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 6.8 | 8.1 | 8.3 | 8.2 | 7.3 | 8.1 | 7.8 | 7.0 | 8.0 | 7.5 |
| ហុងកុង | 8.7 | 14.1 | 10.8 | 10.8 | 6.8 | 2.5 | 0.5 | -0.3 | 10.5 | 3.0 |
| កូរ៉េខាងត្បូង | 13.0 | 12.7 | 9.7 | 9.3 | 4.6 | 3.7 | 2.7 | 1.8 | 8.8 | 3.0 |
| តៃវ៉ាន់ | 6.8 | 7.9 | 5.4 | 6.6 | 4.1 | 1.1 | -2.4 | -4.2 | 6.0 | 2.5 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១១ | 3.1 | 3.8 | 3.9 | 3.3 | 3.0 | 2.5 | 0.2 | 1.3 | 3.4 | 1.5 |
| ជប៉ុន | 0.0 | 2.4 | 1.1 | 0.5 | 2.5 | 0.2 | -2.9 | -0.5 | 1.7 | 0.0 |
| សហរដ្ឋអាមេរិក | 4.6 | 5.3 | 6.1 | 5.2 | 3.4 | 2.7 | 1.2 | 0.6 | 4.9 | 1.0 |

Source: the International Monetary Fund, The Economist, * CDRI Estimates based on the IMF, ADB and World Bank Projections

## តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ១៩៩៩-២០០១ (កំណើនភាគរយធៀបនឹងឆ្នាំមុន)

| | 1999 | | 2000 | | | | 2001 | | 2000 | 2001* |
|---|---|---|---|---|---|---|---|---|---|---|
| | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q1-Q4 | Q1-Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 0.0 | 0.1 | -2.3 | -1.4 | 0.5 | -0.8 | 0.1 | -0.4 | -0.8 | 0.0 |
| ឥណ្ឌូនេស៊ី | 1.7 | -0.6 | 6.1 | 5.7 | 8.8 | 9.1 | 11.1 | 12.1 | 3.7 | 8.0 |
| ម៉ាឡេស៊ី | 2.1 | 1.5 | 1.4 | 1.5 | 1.7 | 1.5 | 1.6 | 1.4 | 1.5 | 1.6 |
| សិង្ហបុរី | 1.5 | 1.1 | 0.8 | 1.5 | 2.0 | 1.7 | 1.7 | 0.8 | 1.4 | 1.7 |
| ថៃ | 0.1 | 0.8 | 1.6 | 2.2 | 1.6 | 1.8 | 2.6 | 1.7 | 1.5 | 2.5 |
| វៀតណាម | - | -1.7 | -2.4 | -2.2 | -0.4 | -1.4 | -.0.8 | - | -1.7 | 0.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | -0.8 | 0.1 | 0.1 | 0.3 | 0.6 | 1.3 | 1.6 | 0.8 | 0.3 | 1.0 |
| ហុងកុង | -4.1 | -5.1 | -4.4 | -2.9 | -2.2 | -1.8 | -1.3 | -1.1 | -3.7 | -1.5 |
| កូរ៉េខាងត្បូង | 1.3 | 1.5 | 1.4 | 3.2 | 2.9 | 4.3 | 5.3 | 4.3 | 2.3 | 4.5 |
| តៃវ៉ាន់ | 0.1 | 1.1 | 1.4 | 1.0 | 2.0 | -1.0 | -0.0 | -0.5 | 1.4 | 0.0 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១១ | 1.5 | 2.0 | 2.1 | 2.5 | 2.7 | 2.5 | 3.1 | 2.7 | 2.3 | 2.5 |
| ជប៉ុន | -1.0 | -0.7 | -0.7 | -0.7 | -0.5 | -0.1 | -0.5 | -0.8 | -0.6 | -0.5 |
| សហរដ្ឋអាមេរិក | 2.6 | 3.2 | 3.3 | 3.5 | 3.4 | 3.4 | 3.4 | 2.7 | 3.4 | 3.5 |

*Source: the International Monetary Fund, The Economist, * CDRI Estimates based on the IMF, ADB and World Bank Projections*

## តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារ នៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ១៩៩៩-២០០១ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 1999 | | 2000 | | | | 2001 | | 2000 | 2001* |
|---|---|---|---|---|---|---|---|---|---|---|
| | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q1-Q4 | Q1-Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 3,808 | 3,822 | 3,845 | 3,912 | 3,906 | 3,925 | 3,932 | 3,953 | 3,871 | 3,975 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 7,193 | 7,391 | 8,287 | 8,712 | 9,297 | 9,780 | 11,242 | 9,558 | 8,422 | 10,100 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 |
| សឹង្ហបុរី (ដុល្លារសឹង្ហបុរី) | 1.67 | 1.69 | 1.72 | 1.73 | 1.74 | 1.75 | 1.81 | 1.77 | 1.72 | 1.75 |
| ថៃ (បាត) | 38.8 | 37.4 | 38.6 | 40.9 | 43.3 | 43.2 | 45.4 | 44.8 | 40.1 | 44.0 |
| វៀតណាម (ដុង) | 14,009 | 14,053 | 14,075 | 14,120 | 14,423 | 14,556 | 14,670 | 14,999 | 14,168 | 14,800 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ុន) | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.27 | 8.28 | 8.28 |
| ហុងកុង (ដុល្លារហុងកុង) | 7.77 | 7.78 | 7.78 | 7.79 | 7.79 | 7.80 | 7.80 | 7.79 | 7.79 | 7.80 |
| កូរ៉េខាងត្បូង (វ៉ុន) | 1,173 | 1,125 | 1,116 | 1,115 | 1,167 | 1,272 | 1,306 | 1,295 | 1,131 | 1,300 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 32.0 | 30.7 | 31.7 | 32.8 | 32.1 | | 34.6 | 34.6 | 31.8 | 34.0 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១១ (អឺរ៉ូ) | 0.96 | 1.01 | 1.07 | 1.10 | 1.15 | 1.08 | 1.15 | 1.11 | 1.09 | 1.10 |
| ជប៉ុន (យ៉េន) | 106 | 107 | 107 | 108 | 110 | 118 | 123 | 121 | 108 | 120 |

Source: the International Monetary Fund, The Economist, * CDRI Estimates based on the IMF, ADB and World Bank Projections

## តារាង៤. ថ្លៃផលិតផលនៅលើទីផ្សារពិភពលោក ពីឆ្នាំ១៩៩៩-២០០១ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 1999 | | 2000 | | | | 2001 | | 2000 | 2001* |
|---|---|---|---|---|---|---|---|---|---|---|
| | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q1-Q4 | Q1-Q4 |
| ឈើមូលប្រភេទរឹង - ម៉ាឡេស៊ី($/ម៣) | 199 | 189.4 | 192.7 | 192.1 | 186.0 | 171.0 | 163.8 | 159.4 | 190.1 | 163 |
| ឈើអារប្រភេទរឹង - ម៉ាឡេស៊ី ($/ម៣) | 643 | 641.0 | 633.2 | 592.7 | 529.8 | 507.0 | 492.2 | 482.0 | 599.2 | 490 |
| កៅស៊ូ - ម៉ាឡេស៊ី ($/តោន) | 689 | 729.9 | 744.4 | 712.2 | 696.6 | 632.0 | 628.9 | 597.7 | 720.7 | 620 |
| អង្ករ - បាងកក ($/តោន) | 225 | 239.8 | 204.5 | 185.4 | 185.1 | 182.0 | 164.7 | 170.4 | 203.7 | 170 |
| សណ្តែកសៀង - សហរដ្ឋ ($/តោន) | 200 | 212.3 | 223.0 | 200.7 | 209.0 | 202.0 | 186.7 | 183.3 | 211.3 | 190 |
| ប្រេងកាតឆៅ ឌូបៃ ($/តោន) | 23 | 24.3 | 25.0 | 27.6 | 27.5 | 24.0 | 25.1 | 23.9 | 26.1 | 23 |
| មាស - LONDON ($/fine ounces) | 296 | 290.2 | 280.2 | 276.5 | 269.2 | 264.0 | 267.7 | 269.8 | 279.0 | 270 |

Source: the International Monetary Fund, The Economist, * CDRI Estimates based on the IMF, ADB and World Bank Projections

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

ក្នុងឆ្នាំ២០០១ ប្រទេសកម្ពុជាបន្តមានកំណើន ផសស សមរម្យក្នុងរង្វង់ ៤-៦% ទោះបីគេនៅតែបារម្ភអំពីការរាលដាលនៃការធ្លាក់ចុះសេដ្ឋកិច្ចនៅក្នុងពិភពលោក និងឥទ្ធិពលនៃព្រឹត្តិការណ៍ថ្ងៃទី១១ កញ្ញា នៅសហរដ្ឋអាមេរិក ។ អាំងឌីកាទ័រសេដ្ឋកិច្ច សំរាប់ត្រីមាសទី៣ ឆ្នាំ២០០១ បង្ហាញថា ការនាំចេញសំលៀកបំពាក់ និងវិស័យទេសចរណ៍ (ដែលជាវិស័យចំបងគេនៃសេដ្ឋកិច្ច) នៅតែបន្តកើនឡើងទោះបីមានការធ្លាក់ចុះសេដ្ឋកិច្ចជាសាកលក៏ដោយ ។ វិស័យសាងសង់បានរើបឡើងវិញដោយសារវិនិយោគ ឯកជនបានបន្តលូតលាស់អស់បួនត្រីមាសហើយគិតមកដល់ខែកញ្ញា ២០០១ ។ ដំណើរការរូបិយវត្ថុមានស្ថិរភាពៈ អតិផរណានៅក្រុងភ្នំពេញមានកំរិតទាប ដោយធ្លាក់ចុះដល់ -0,៤% ក្នុងរយៈពេលមួយឆ្នាំ មកដល់ត្រីមាសទី៣ ឆ្នាំ២០០១ ហើយសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅតាមបណ្តាខេត្តបានធ្លាក់ចុះ -១,១% ។ ប្រាក់រៀលធ្លាក់ថ្លៃបន្តិចធៀបនឹងដុល្លារអាមេរិក និងប្រាក់បាតថៃ ។ ក្នុងត្រីមាសទី៣ មួយដុល្លារប្តូរបាន ៣.៩៥២រៀល ហើយមួយបាតប្តូរបាន ៨៨,២រៀល ។ កំណែទំរង់វិស័យធនាគារកំពុងមានដំនើរការ ប៉ុន្តែឯកជនភាវូបនីយកម្មនៃធនាគារពាណិជ្ជកម្មក្រៅប្រទេសកម្ពុជាដែលគ្រោងធ្វើនៅចុងឆ្នាំ២០០១ ប្រហែលមិនអាចធ្វើបានឆាប់ដូច្នេះទេ ។ តាមពត៌មានពីធនាគារជាតិនៃកម្ពុជា (NBC) ធនបំរុងបរទេសដុលនៅធនាគារកណ្តាលបានបន្តកើនដល់ ៥៣២,៣លានដុល្លារ នៅចុងខែកញ្ញានេះ (ស្មើនឹង ៣,៥ខែនៃការនាំចូលទំនិញនិងសេវា) ។

## សកម្មភាពសេដ្ឋកិច្ច

ទោះបីប្រទេសជាច្រើនបានទទួលស្គាល់ជាផ្លូវការពីការធ្លាក់ចុះសេដ្ឋកិច្ចក៏ដោយ ក៏កម្ពុជាអាចសំរេចបាននូវកំណើនសេដ្ឋកិច្ចគួរឱ្យកត់សំគាល់ក្នុងរយៈពេល ៩ខែដើមឆ្នាំ ២០០១ ។ កំនើនសេដ្ឋកិច្ចកម្ពុជាពឹងផ្អែកជាមូលដ្ឋានលើវិស័យមួយចំនួន ដូចជាវិស័យកាត់ដេរសំលៀកបំពាក់ និងស្បែកជើង, ទេសចរណ៍ ការនាំចេញអង្ករ និងកៅស៊ូ ។ ការនេសាទ ព្រៃឈើ និងផលដំណាំផ្សេងៗ ក៏បានផ្តល់តំលៃបន្ថែមច្រើនណាស់ដែរដល់សេដ្ឋកិច្ច ។ សកម្មភាពឧស្សាហកម្មកែច្នៃធុនតូច និងមធ្យម ហើយនិងការនាំចេញ ផលិតផលសំរេច (លើកលែងតែសំលៀកបំពាក់ និងស្បែកជើង) ពុំមានការលូតលាស់នៅឡើយទេ ។

ឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ដែលផ្តល់ការងារច្រើនបំផុត ក្រៅពីកសិកម្ម បានបន្តកើនឡើងពេញមួយឆ្នាំ ទោះបីជាយឺតៗក៏ដោយ ។ នៅក្នុង ៩ខែដើមឆ្នាំ២០០១ សំលៀកបំពាក់នាំចេញមានសរុប ៨១៤លានដុល្លារ គឺកើនឡើង ១៣% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០០០ ។ ការនាំចេញទៅទីផ្សារអាមេរិកមានទំហំ ៥៨០លានដុល្លារ (កើន ៣% ធៀបនឹង ៩ខែដើមឆ្នាំ២០០០) ។ ថ្វីបើមានបារម្ភពីការបញ្ជាទិញធ្លាក់ចុះ ប៉ុន្តែ ទំហំនៃការនាំចេញទៅសហរដ្ឋអាមេរិក មិនបានថយចុះទេ ។ ទីផ្សារអាមេរិក គឺជាគោលដៅដ៏សំខាន់សំរាប់ឧស្សាហកម្មនាំចេញសំលៀកបំពាក់កម្ពុជា ហើយវាបានធានាដល់ចីរភាពនៃវិស័យនេះ ដោយក្នុងប៉ុន្មានឆ្នាំចុងក្រោយវាបានស្រូបយកប្រហែល ៧៥% នៃសំលៀកបំពាក់នាំចេញសរុបរបស់កម្ពុជា ។

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ កិច្ចព្រមព្រៀងទ្វេភាគី កម្ពុជា-អាមេរិកសំរាប់ការដាក់កូតារយៈបីឆ្នាំលើសំលៀកបំពាក់កម្ពុជានាំចេញទៅអាមេរិកចំនួន ១២មុខ នឹងត្រូវបញ្ចប់ក្នុងពេលឆាប់ៗខាងមុខនេះ ។ ការចរចាធ្វើកិច្ចព្រមព្រៀងលើកូតាថ្មី កំពុងតែដំណើការទៅមុខ ។

ការនាំចេញទៅទីផ្សារសហភាពអឺរ៉ុប (EU) ដែលជាគោលដៅនាំចេញធំទី២ សំរាប់សំលៀកបំពាក់កម្ពុជា បានកើនយ៉ាងខ្លាំងក្នុងពេលថ្មីៗនេះ ។ នៅ ៩ខែដើមឆ្នាំ២០០១ ការនាំចេញទៅ EU មានចំនួន ២២១លានដុល្លារ (កើន ៥៨% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន) ។ តាំងពីខែមេសា ឆ្នាំ១៩៩៩ EU បានអនុញ្ញាតនូវលក្ខខណ្ឌអនុគ្រោះពិសេសសំរាប់ ៣ឆ្នាំ ឱ្យកម្ពុជាអាចនាំចេញទៅទីផ្សារអឺរ៉ុបដោយគ្មានកូតា និងគ្មានពន្ធគយ ។ ប៉ុន្តែតាមពត៌មានពីក្រសួងពាណិជ្ជកម្ម សំលៀកបំពាក់កម្ពុជាប្រហែល ១០% ត្រូវបាននាំទៅទីផ្សារ EU ក្រោមលក្ខខណ្ឌអនុគ្រោះនេះ ឯ ៩០%ទៀតបានជាប់ពន្ធតាមអត្រា MFN ដែលមានកំរិតជាមធ្យម ៩% ។ ឧបសគ្គធំៗមួយចំនួនដែលរារាំងការអនុវត្តន៍លក្ខខណ្ឌអនុគ្រោះ គឺស្តង់ដាគុណភាពអន់ និងអសមត្ថភាពក្នុងការយល់ដឹង និងអនុវត្តតាមបែបបទនានារបស់ប្រទេសនាំចូល ។

យោងតាមអង្គការទេសចរណ៍ពិភពលោក (WTO) ឧស្សាហកម្មទេសចរណ៍ពិភពលោក រំពឹងថាត្រូវរួមតូច ២០% ក្នុងឆ្នាំ២០០១ ដោយសារឥទ្ធិពលអាក្រក់នៃភេរវកម្មថ្ងៃ១១ កញ្ញា ២០០១ នៅសហរដ្ឋអាមេរិក ។ ទោះជាទេសចរណ៍ពិភពលោកធ្លាក់ចុះក៏ដោយ ក៏ឧស្សាហកម្មទេសចរណ៍កម្ពុជា (ប្រភពចំណូលរូបិយប័ណ្ណធំទី២) មិន ទាន់មានសញ្ញាណាមួយនៃការធ្លាក់ចុះទេ ។ ក្នុង ៩ខែដើមឆ្នាំ២០០១ មានទេសចរ បរទេសសរុប ៣៨៤.៥០០នាក់ បានចូលមកតាមជើងយន្តហោះ (កើន ២២%ធៀបនឹង រយៈពេលដូចគ្នានៃឆ្នាំ២០០០) ក្នុងនេះ ២៨%បានចូលមកតាមជើងហោះហើរអន្តរ ជាតិផ្ទាល់ទៅសៀមរាប ។ តាម WTO តំបន់អាស៊ីប៉ាស៊ីហ្វិក នឹងក្លាយជាទីពេញនិយម របស់ទេសចរនាពេលអនាគត ហើយដល់ឆ្នាំ២០២០ ប្រទេសចិននឹងលូតហួសប្រទេសបារាំង និងអេស្ប៉ាញ ដើម្បីក្លាយជាកន្លែងពេញនិយមបំផុតក្នុងពិភពលោកសំរាប់ទេសចរអន្តរជាតិ ។ ជាការព្យាករណ៍ទេសចរណ៍កម្ពុជានឹងមានអនាគតល្អ ដោយសារឥទ្ធិពលហៀរចូលនៃកំណើនទេសចរណ៍នៅក្នុងតំបន់ ។

## អតិផរណា និងអត្រាប្តូរប្រាក់

អត្រាអតិផរណានៅភ្នំពេញ គឺស្ថិតក្នុងរង្វង់ 0%នៅក្នុងត្រីមាសទី៣ ឆ្នាំ២០០១ ។ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ទាំងអស់ (CPI of all goods) បានធ្លាក់ចុះ -0,៤% ក្នុងរយៈមួយឆ្នាំមកដល់ត្រីមាសទីបីឆ្នាំនេះ ។ CPI ស្នូលដែលមានថ្លៃម្ហូបអាហារ និងថ្លៃថាមពល បានធ្លាក់ចុះ -២,៤% និង -៣%រៀងៗគ្នា តាមទិន្នន័យផ្តល់ដោយវិជ្ជាស្ថានជាតិស្ថិតិ ។ តាមអង្កេតប្រចាំត្រីមាសរបស់ វបសអ អតិផរណាបានថយចុះគួរឱ្យកត់សំគាល់នៅតាមខេត្តនានាក្នុងប្រទេសកម្ពុជា គឺធ្លាក់ចុះ -១,១% ក្នុងរយៈមួយឆ្នាំមក ដល់ត្រីមាសទី៣ ឆ្នាំ២០០១ ដែលជាការចុះទាបមិនធ្លាប់មានពីមុនមក ។ ការធ្លាក់ចុះ ថ្លៃត្រីគឺជាកត្តាចំបងដែលសង្កត់អោយអតិផរណាតាមខេត្តថយចុះ ។

ប្រាក់រៀលកម្ពុជាបន្តធ្លាក់ចុះជាលំដាប់ធៀបនឹងដុល្លារអាមេរិក ដោយមានអត្រាប្តូរជាមធ្យម ៣.៩៥២រៀល/ដុល្លារ ក្នុងត្រីមាសទី៣ ឆ្នាំ២០០១ ។ មូលហេតុចំបងមួយនៃការធ្លាក់ថ្លៃប្រាក់រៀល គឺកំណើនសាច់ប្រាក់ (រៀល) ដែលបញ្ចេញឱ្យចរាចរសំរាប់ដោះស្រាយការចំណាយបោះឆ្នោតឃុំ-សង្កាត់ដែលជិតមកដល់ ។ ការបោះឆ្នោតឃុំ-សង្កាត់ នឹងប្រព្រឹត្តទៅនៅខែកុម្ភៈ ឆ្នាំ២០០២ ។ ជាទូទៅ ប្រាក់រៀលតែងចុះថ្លៃនៅពេលការបោះឆ្នោតខិតជិតមកដល់ ប៉ុន្តែបន្ទាប់មកនឹងវិវត្តមកដូចធម្មតាវិញ ។ ប្រាក់រៀលបន្តឡើងថ្លៃធៀបនឹងប្រាក់ដុងវៀតណាម ប៉ុន្តែស្ថិតក្រោមការគៀបសង្កត់ពីប្រាក់បាតថៃ ។ ក្នុងត្រីមាសទី៣ ឆ្នាំ២០០១, ១ប

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

ាតថៃ ប្ដូរបាន ៨៨,២រៀល ហើយ ១០០ដុងវៀតណាម ប្ដូរបាន ២៦,៤ រៀល ។

ថ្វីបើនៅក្នុងប៉ុន្មានខែចុងក្រោយនេះ ប្រេងឆៅក្នុងទីផ្សារពិភពលោកបានធ្លាក់ថ្លៃវិញ ប៉ុន្តែប្រេងសាំងនៅប្រទេសកម្ពុជា នៅតែថ្លៃខ្ពស់នៅឡើយដល់ ២.១០០រៀល ឬ ០,៥៣ដុល្លារ/លីត្រ ឯប្រេងម៉ាស៊ូតលក់ថ្លៃ ១.៥៥០រៀល/លីត្រ (តារាង៤) ។ ប្រេងឥន្ធនៈមានថ្លៃខ្ពស់ អាចមានផលប៉ះពាល់ជាអវិជ្ជមានចំពោះការលូតលាស់ក្នុងផ្នែកខ្លះ នៃសេដ្ឋកិច្ច ។

## ស្ថានភាពក្រីក្រ-ចំណូលកម្មករ

ធនាគារអភិវឌ្ឍន៍អាស៊ីបានរាយការណ៍ថា ភាពក្រីក្រនៅតំបន់អាស៊ីបានធ្លាក់ចុះជិតពាក់កណ្ដាលក្នុងរយៈពេល ៣០ឆ្នាំគិតមកដល់ចុងឆ្នាំ១៩៩៧ ។ ប៉ុន្តែភាគរយប្រជាជននៅក្រោមបន្ទាត់ក្រីក្រ បានចាប់ផ្ដើមកើនឡើង បន្ទាប់ពីមានវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នាឆ្នាំ១៩៩៧ ។ តាមការគណនារបស់ក្រសួងផែនការ ភាគរយប្រជាជនកម្ពុជាស្ថិតនៅក្រោមបន្ទាត់ក្រីក្របានធ្លាក់ចុះបន្តិចគឺពី ៤០% មកនៅត្រឹម ៣៦% ពីឆ្នាំ១៩៩៤ ដល់ ១៩៩៩ ។ ភាគរយជនក្រីក្រនៅកម្ពុជា បានធ្លាក់ចុះមែន ក៏ប៉ុន្តែចំនួនអ្នកក្រីក្របានបន្តកើនឡើង ពីព្រោះអត្រាកំណើនសេដ្ឋកិច្ចមិនទាន់ធំល្មមគ្រប់គ្រាន់ទេ ដើម្បីរ៉ាប់រងកំណើនប្រជាជនដ៏ខ្ពស់នេះ ។ ចាប់ពីឆ្នាំ១៩៩៤-៩៩ នៅកម្ពុជាមានផុសអ្នកក្រថ្មីចំនួនកន្លះលាននាក់ថែមទៀត ។ ដើម្បីវាយតំលៃពីទិដ្ឋភាពផ្សេងៗនៃភាពក្រីក្រនៅកម្ពុជា វបសអ បានធ្វើអង្កេតប្រចាំត្រីមាសនៅក្នុងក្រុងភ្នំពេញ និងខេត្តជ្រើសរើសមួយចំនួនទៅលើពលករងាយរងគ្រោះជាច្រើនក្រុម ដូចជាអ្នកធាក់ស៊ីក្លូ កម្មករសំណង់មានជំនាញ...(តារាង៥) ។

តាមលទ្ធផលអង្កេតក្នុងខែវិច្ឆិកា ឆ្នាំ២០០១ ពលករងាយរងគ្រោះ ៧៣% បានរាយការណ៍ពីការធ្លាក់ចុះចំនូល បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន ត្រូវបានប៉ះទង្គិចធ្ងន់ជាងគេគឺមាន អ្នកធាក់ស៊ីក្លូ អ្នកលក់បន្លែតូចតាច អ្នកលីសែង និងកម្មករសំណង់មានជំនាញ និងគ្មានជំនាញ (តារាង៥) ។ គេយល់ថា ការធ្លាក់ចុះចំណូលកើតឡើងដោយកំណើនចំនួនពលករចំណាកស្រុកនៅក្នុងក្រុងភ្នំពេញ (កំណើនចំនួនកំលាំងពលកម្មធ្វើឱ្យចំណូលធ្លាក់ចុះ) ។ ប្រជាជនជាច្រើនបានមកទីក្រុងដើម្បីរត់គេចពីទុគ៌តភាពបង្កឡើងដោយគ្រោះធម្មជាតិ (ទឹកជំនន់ និងគ្រោះរាំងស្ងួត) នៅតំបន់ជនបទ ។ មូលហេតុផ្សេងទៀតនៃភាពងាយរងគ្រោះរបស់ប្រជាជន អាចជាប់ទាក់ទងនឹងកង្វះទ្រព្យ សំភារៈនិងធនធានមនុស្ស, ធនធានធម្មជាតិដែលកាន់តែខ្សត់ខ្សោយ, និងកំនើនប្រជាជន ។ ទោះបីជាពុំមានការសិក្សាលំអិត ដើម្បីវាយតំលៃអំពីមូលហេតុនៃភាពក្រីក្រ ឬផលប៉ះពាល់នៃចំណាកស្រុកចូល ទឹកជំនន់... ទៅលើសេដ្ឋកិច្ចក៏ដោយ ក៏ការធ្លាក់ចុះចំណូល (ប្រចាំថ្ងៃ) និងកំណើនចំណាកស្រុកពីជនបទទៅទីក្រុង វាជាកង្វល់ដ៏ធំមួយរួចហើយ ។ ចំនូលប្រចាំថ្ងៃរបស់កម្មករលីសែងបានធ្លាក់ចុះអស់បួនត្រីមាសជាប់ៗគ្នា ហើយពួកគាត់រកប្រាក់ផ្ញើទៅគ្រួសារនៅឯជនបទមិនបានទេ ។ ចំណូលប្រចាំថ្ងៃរបស់កម្មករកាត់ដេរបានកើនឡើង ២១% បើធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន ។ ប៉ុន្តែបើធៀបនឹងខែសីហា ២០០១ (ពេលធ្វើអង្កេតលើកមុន) ចំណូលរបស់ពួកគេបានធ្លាក់ចុះបន្តិច (តារាង៥) ។ ក្នុងចំណោមកម្មករកាត់ដេរ ១២០នាក់មកពីរោងចក្រ១០ ដែលបានឆ្លើយសំភាសន៏ ជិតមួយភាគបីបានបញ្ជាក់ថា ដើម្បីបានការងារធ្វើក្នុងរោងចក្រ បេក្ខជនកម្មករពិសេសបុរសភេទ ត្រូវចំណាយពី ៥០ ទៅ ១០០ដុល្លារ ដើម្បីការសូកប៉ាន់ ។ ការបង់ប្រាក់នេះ កម្មករ ៧៤% រាយការណ៏ថាបានខ្ចីពីសាច់ញាតិ ឯ ២៦%ទៀតបានចំណាយប្រាក់សន្សំរបស់ខ្លួន ។

វបសអ បានធ្វើអង្កេតផងដែរលើអ្នកលក់ទំនិញប្រណិត (មាស ត្បូង នាឡិកា ទូរទស្សន៏ និងរូបចម្លាក់វត្ថុអនុស្សាវរីយ៏) អ្នកលក់សំភារៈប្រើប្រាស់ក្នុងផ្ទះ (មុង ភួយ ចាន ឆ្នាំង) សំលៀកបំពាក់ អាហារ និងអ្នកលក់ទំនិញផ្សេងៗទៀត ដូចជា គ្រឿងសំអាង ប្រដាប់ក្មេងលេង សំភារៈការិយាល័យ ដើម្បីវាយតំលៃអំពីដំណើរការនៃទីផ្សារ ។ អ្នកលក់ដុំ និងអ្នកលក់រាយក្នុងក្រុងភ្នំពេញ ១៣១នាក់បានបញ្ជាក់ថា ការលក់ដូរកាន់តែលំបាកហើយក្នុងពេលខាងមុខ ។ ប្រហែល ៧៨% ប្រាប់ថាលក់បានតិចជាងមុន ហើយ ២២%ទៀតឆ្លើយថា ការលក់ដូរបានល្អដូចដើមឆ្នាំមុនដែរ ។ ៧៨% នៃអ្នកលក់ទំនិញប្រណិតបញ្ជាក់ថា ជំនួញរបស់ពួកគាត់ធ្លាក់ចុះជិត ៤០% ធៀបនឹងត្រីមាសមុន ។ ចំពោះ ៧៤%នៃអ្នកលក់សំភារៈប្រើប្រាស់ក្នុងផ្ទះ (ក្រណាត់ និងផលិតផលប្រើប្រាស់) ការលក់ដូរក្នុងឆ្នាំនេះអន់ជាងឆ្នាំមុន ។ ប្រហែល ៥៦% នៃអ្នកលក់ម្ហូបអាហារក្នុងផ្សារធំៗប្រាំនៅភ្នំពេញបានត្អូញត្អែរថា ការលក់ដូរធ្លាក់ចុះជិត ៥០% ក្នុងប៉ុន្មានខែចុងក្រោយ ។ មួយចំណែកទៀត ៧៥% នៃអ្នកលក់ដុំបញ្ជាក់ថា ការលក់ដូររបស់គាត់មិនបានល្អដូចឆ្នាំមុនទេ ។ អង្កេតបានរកឃើញថា នៅតាមខេត្តនានា គ្រោះធម្មជាតិគឺជាមូលហេតុចំបងដែលធ្វើឱ្យការលក់ដូរធ្លាក់ចុះ ។ អ្នកលក់ដុំភាគច្រើនបានប្រាប់ថា ចំនួនអតិថិជនមកពីខេត្តផ្សេងៗបានថយចុះ ពីព្រោះកំលាំងទិញនៅតាមខេត្តចុះខ្សោយ ដោយសារតែគ្រោះទឹកជំនន់ពីរឆ្នាំជាប់ៗគ្នាកន្លងមកនេះ ។ ដោយហេតុថាសព្វថ្ងៃនេះពិបាករកចំណូលជាងមុន ដូច្នេះប្រជាជនចំណាយតិចជាងមុនដែរ ។ ដោយសារពុំមានអង្កេតទិន្នន័យទ្រង់ទ្រាយធំ គេពិបាកនឹងបញ្ជាក់បានពីទំហំនៃការថយចុះតំរូវការប្រើប្រាស់ ប៉ុន្តែផ្អែកលើការសិក្សាគំរូតាងតូចៗរបស់ វបសអ គេអាចសន្និដ្ឋានបានថា ទំហំនៃចំណាយប្រើប្រាស់បានធ្លាក់ចុះ បើប្រៀបធៀបនឹងឆ្នាំ២០០០កន្លងមក ។

សរុបមក ដោយសារកង្វះទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចទ្រង់ទ្រាយធំថ្មីៗ គេពិបាកនឹងកំណត់បានពីមូលហេតុនៃការធ្លាក់ចុះចំណូលណាស់ ។ ប៉ុន្តែផ្អែកតាមការសិក្សានានារបស់ វបសអ គេហាក់ដូចជាពិនិត្យឃើញថា សម្ពាធប្រជាជន ធនធានធម្មជាតិ ដែលកាន់តែខ្សត់ខ្សោយទៅៗ និងកង្វះខាតនូវការងារធ្វើ កំពុងតែចោទជាបញ្ហា ឡើងហើយ ។

## ការវិវត្តន៍រូបិយវត្ថុ

ការវិវត្តន៏ខាងរូបិយវត្ថុនៅតែស្ថិតក្រោមការគ្រប់គ្រងដដែល ទោះបីជាគេបានចរាចរសាច់ប្រាក់ច្រើនថែមទៀតនៅតាមទីផ្សារ ក្នុងត្រីមាសទី៣ ឆ្នាំ២០០១ ក៏ដោយ ។ តាមពត៌មានពីធនាគារជាតិនៃកម្ពុជា (NBC) រូបិយវត្ថុកម្ពុជាកំពុងចរាចរឡើងដល់ ៥៣៥ពាន់លានរៀលក្នុងត្រីមាសទី៣ ឆ្នាំ២០០១ (កើន ៥% ធៀបនឹងត្រីមាសមុន) ។ ចំណែកឯប្រាក់បញ្ញើជារូបិយប័ណ្ណក្នុងធនាគារពាណិជ្ជកម្ពុជា បានបន្តកើនឡើងរហូតដល់ ១.៤៩៦ពាន់លានរៀល នៅចុងត្រីមាសទី៣ (គឺកើនពី ១.៣៩០ពាន់លានរៀលនៅចុងត្រីមាសទី២) ។ ប្រាក់បញ្ញើរបស់រដ្ឋាភិបាលនៅធនាគារជាតិ នៅតែមានកំរិតខ្ពស់ (៧៣ពាន់លានរៀល) ហើយឥណទានផ្ដល់ឱ្យវិស័យឯកជន កើនជិតដល់ ៥% (កើនដល់ ៩៩២ពាន់លានរៀលនៅចុងត្រីមាសទី៣ ឆ្នាំ២០០១) ។ រដ្ឋាភិបាលបានជួយឱ្យគ្រួសារក្រីក្រ បានប្រើប្រាស់មីក្រូឥណទានផងដែរ ។ ដើម្បីជួយទ្រទ្រង់ដល់បណ្ដាស្ថាប័នម៉ាក្រូឥណទានទាំងឡាយ រដ្ឋាភិបាលបានខ្ចីប្រាក់ពី ADB និងធនាគារពិភពលោក ។ មកដល់ឆ្នាំ២០០០ ប្រហែល ១៥% នៃគ្រួសារកម្ពុជា អាចប្រើប្រាស់បាននូវមីក្រូឥណទាន ។ តាមរបាយការណ៏ដែលទទួលបានពីធនាគារអភិវឌ្ឍន៏ជនបទជាតិ ទឹកប្រាក់ចំនួន ១១៤,៤ពាន់លានរៀល ត្រូវបានគេផ្ដល់ទៅឱ្យប្រជាជនក្រីក្រ ៣៧០.៦៥១នាក់ខ្ចី ។

ការដាក់អនុវត្តន៏ *ច្បាប់ថ្មីស្ដីពីធនាគារ និងស្ថាប័នហិរញ្ញវត្ថុ* កំពុងដំណើរការទៅមុខ ហើយតាមពត៌មានពី NBC មកដល់ចុងខែវិច្ឆិកា ឆ្នាំ២០០១ មាន ១១ធនាគារបាន

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

ទទួលអាជ្ញាប័ណ្ណជាថ្មី (ធនាគារនិមួយៗត្រូវដាក់ដំកល់ទុន ១៣លានដុល្លារ) និង ១០ ធនាគារផ្សេងទៀត (ក្នុងនេះមានទាំង ៣ធនាគារឯកទេសផង) មិនទាន់បំពេញបាន តាមលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ថ្មីនៅឡើយទេ ប៉ុន្តែបានទទួលការអនុញ្ញាត ឱ្យធ្វើប្រតិបត្តិការ ក្រោមកិច្ចព្រមព្រៀងប្រតិបត្តិមួយដែលពន្យារយៈពេលត្រូវ បំពេញតាមលក្ខខណ្ឌច្បាប់ថ្មី ។ ការកាត់ផ្តាច់ធនាគារពាណិជ្ជកម្មក្រៅប្រទេសកម្ពុជា (FTB) ចេញពី NBC ដែលគ្រោងធ្វើនៅចុងឆ្នាំនេះ ប្រហែលជាត្រូវការពេលវេលាច្រើន ថែមទៀត ដើម្បីធ្វើឯកជនូបនីយកម្ម (denationalisation) ។ ដោយហេតុថា FTB នៅជាធនាគាររដ្ឋនៅឡើយ ដូច្នេះ NBC ក៏បានផ្តល់ទុនសំរាប់បំពេញតាមការតំរូវខាង ប្រាក់ដំកល់ ។

**ហិរញ្ញវត្ថុសាធារណៈ**

បញ្ហាប្រឈមចំបងចំពោះរដ្ឋាភិបាល គឺបង្កើនចំណូលថវិកា និងកាត់បន្ថយចំណាយ ជាពិសេសក្នុងវិស័យការពារជាតិ និងសន្តិសុខជាតិឱ្យបានយ៉ាងឆាប់ ។ ក្នុង ៩ខែដើម ឆ្នាំ២០០១ ចំណូលក្នុងស្រុកសរុបឡើងដល់ ១.១២៦ពាន់លានរៀល (កើន ៧.៦% បើធៀបនឹងរយៈពេលដូចគ្នានាឆ្នាំ២០០០) ប៉ុន្តែនៅទាបជាងផែនការ ៧% ។ យោង តាម *ច្បាប់ថវិកាឆ្នាំ២០០១* ផែនការប្រមូលចំណូលក្នុងស្រុកគឺ ១.៦៥១ពាន់លាន រៀល (ប្រហែល១២%នៃ ផសស) ។ ផែនការនេះ ប្រហែលអាចសំរេចបានដោយ សារការដាក់អនុវត្តនីយុទ្ធសាស្ត្របង្កើនចំណូលមួយចំនួន ដូចជា តែមបង់ពន្ធបិទលើ កញ្ចប់បារី អាករលើតំលៃបន្ថែម (VAT) លើប្រេងម៉ាស៊ូត និងកំរៃពិសេសលើទិដ្ឋាការ (ចាប់ប្រមូលតាំងពីពាក់កណ្តាលឆ្នាំ២០០១) ។ រាជរដ្ឋាភិបាលកំពុងព្យាយាមកាត់បន្ថយការពឹងផ្អែកលើចំណូលពន្ធគយ ដើម្បីសំរបតាមគោលនយោបាយរបស់ ASEAN/AFTA ដោយខំប្រឹងប្រែងប្រមូល VAT និងអាករពិសេសវិញ ។

*ច្បាប់ថវិកា*ថ្មីសំរាប់ឆ្នាំ២០០២ បានឆ្លងក្រុមប្រឹក្សារដ្ឋមន្ត្រីរួចហើយ និងត្រូវបាន ដាក់ជូនរដ្ឋសភាដើម្បីសុំការអនុម័តហើយ ។ *ច្បាប់ថវិកា* ឆ្នាំ២០០២ សំដៅបង្កើន ចំណូលក្នុងស្រុកដល់ ១.៨១៦ពាន់លានរៀលដែលស្មើនឹង ១៣%នៃ ផសស (ធៀប នឹង ១២% សំរាប់ឆ្នាំ២០០១) ។ ដើម្បីប្រមូលចំណូលនេះ គោលនយោបាយមួយ ចំនួនសំរាប់ឆ្នាំ២០០២ ត្រូវបានកំណត់ឡើងដែលមានជាអាទិ ការពង្រីក VAT ទៅ លើឧស្សាហកម្មខ្លះទៀត (ឧទាហរណ៍ ការតំឡើង ទោចក្រយានយន្ត និងគ្រឿងបន្លាស់ផ្សេងៗ) ការដាក់អនុវត្តនី VAT ក្នុង១០ខេត្ត (សព្វថ្ងៃមាន ៥ខេត្ត) និងការកាត់បន្ថយ ការលើកលែងពន្ធចំពោះក្រុមហ៊ុនធំៗ ។

ចំណែកឯខាងចំណាយវិញ ត្រូវបានផ្តល់អាទិភាពទៅលើវិស័យសំខាន់ៗបួនគឺ អប់រំ សុខាភិបាល កសិកម្ម និងអភិវឌ្ឍន៍ជនបទ ។ នៅ ៩ខែដើមឆ្នាំ២០០១ ចំណាយសរុប ក្នុងវិស័យអប់រំ និងសុខាភិបាល បានកើន ២៧% ហើយចំណាយសរុបក្នុងវិស័យ កសិកម្ម និងអភិវឌ្ឍន៍ជនបទ បានកើន ៦៨% បើធៀបរយៈពេលដូចគ្នានៃឆ្នាំ ២០០០ ។ ក្នុងកំឡុងពេលនេះដែរ ចំណាយខាងយោធាបានធ្លាក់ចុះ ១២,៦% បើ ប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០០០ ។ ជាតួលេខជាក់ស្តែង នៅ ៩ខែដើម ឆ្នាំ២០០១ ចំណាយសរុបមានចំនួន ១.៥៥៥ពាន់លានរៀល (បូកទាំងហិរញ្ញប្បទាន បរទេស) គឺកើន ១០,៥% ធៀបនឹងរយៈពេលដូចគ្នានាឆ្នាំ២០០០ ។

គោលនយោបាយចំណាយថវិកានៅក្នុង *ច្បាប់ថវិកា* ថ្មីឆ្នាំ២០០២ បានតំរង់ទិស ថវិកាទៅកាន់វិស័យជាអាទិភាពនានា និងកាត់បន្ថយចំណាយនៅក្នុងវិស័យមិនមែន អាទិភាព ។ ចំណាយខាងយោធារំពឹង ថានឹងថយចុះមកត្រឹម ២,៧% នៃ ផសស (ចុះពីប្រហែល ៣%នៃ ផសស ក្នុងឆ្នាំ ២០០១) ហើយចំណាយក្នុងវិស័យជាអាទិភាព ទាំង៤ខាងលើ រំពឹងថានឹងកើនខ្ពស់គួរសម បើប្រៀបធៀបនឹងឆ្នាំ២០០១ ។ ផែនការ ចំណាយតាមវិស័យកើនឡើង ២៨% សំរាប់ខាងអប់រំ ២១% សំរាប់ខាងសុខាភិបាល ១៣% សំរាប់កសិកម្ម និង ៤៦% សំរាប់អភិវឌ្ឍន៍ជនបទ ។

**វិនិយោគឯកជន និងការផ្តល់ការងារ**

វិនិយោគឯកជនហាក់ដូចជាបានថយចុះក្នុងឆ្នាំ២០០១ ។ តាមពតិមានដែល ទទួលបានមកពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) វិនិយោគផ្ទាល់ពីបរទេស (FDI) បានបន្តធ្លាក់ចុះ ។ ក្នុង ៩ខែ ដើមឆ្នាំ២០០១ CDC បានអនុម័ត ៣៦ គំរោងវិនិយោគថ្មី និងគំរោងពង្រីកបន្ថែម ដែលមានតំលៃគិតជាទ្រព្យសកម្មជាប់លាប់គិតជាប្រាក់មាន ៥៦,១លានដុល្លារ ។ តួលេខទ្រព្យសកម្មជាប់លាប់ថ្មីនៅក្នុងឆ្នាំ២០០១ មានកំរិត ៧៣% ទាបជាង បើប្រៀបធៀបទៅនឹងតួលេខនៅក្នុងឆ្នាំ២០០០ ។ នៅក្នុងចំណោម គំរោងវិនិយោគនានាដែលគេបានអនុម័ត មាន ១៧គំរោង គឺជារោងចក្រកាត់ដេរ (ធ្លាក់ចុះជិតដល់ ៦០% ធៀបនឹង ៩ខែដើមឆ្នាំ២០០០) ។ ឧស្សាហកម្មសំលៀក បំពាក់នៅប្រទេសកម្ពុជាមានអនាគតមិនច្បាស់លាស់ទេសំរាប់រយៈពេលខ្លីខាងមុខ ពីព្រោះតំរូវការនៅក្នុងទីផ្សារនាំចេញធំៗរបស់ផលិតផលកម្ពុជាបានថយចុះ ដោយ សារតែការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក ។

ច្បាប់វិនិយោគកម្ពុជាត្រូវបានកែប្រែឡើងវិញនៅដើមឆ្នាំ២០០១ ហើយស្ថានការ នយោបាយក៏មានស្ថិរភាពល្អដែរ ប៉ុន្តែ FDI នៅតែមានកំរិតទាប ។ FDI ដើរតួនាទី សំខាន់ណាស់ក្នុងការផ្តល់ការងារ ឱ្យកំលាំងពលកម្មកម្ពុជាដែលកើនឡើងយ៉ាងឆាប់រហ័ស ។ យោងតាមការសិក្សាមួយរបស់ វបសអ ចំនួនការងារក្នុងគំរោង FDI តំណាងឱ្យជិត ៨,៥% នៃចំនួនការងារសរុបនៅកម្ពុជា ។ ពីឆ្នាំ២០០៤-២០០៨ ពលករថ្មីដែល ស្វែងរកការងារមានពី ២២០,០០០-២៥០,០០០នាក់ក្នុងមួយឆ្នាំៗ ហើយបើសិនជា FDI និងវិនិយោគក្នុងស្រុក មិនកើនឡើងទេ ភាពគ្មានការងារធ្វើ នឹងចោទជាបញ្ហា យ៉ាង ធ្ងន់ធ្ងរ ។

**ជំនួយបរទេស និងបំណុលបរទេស**

**ទាយកពហុភាគីរបស់ប្រទេសកម្ពុជា ១៩៩២-២០០០ (លានដុល្លារ)**




**ប្រភព:** CDC

ក្នុងរយៈពេលពីឆ្នាំ១៩៩២-២០០០ កម្ពុជា បានទទួលជំនួយពីទាយកពហុភាគី ប្រហែល ១,៤៤ពាន់លានដុល្លារ ក្នុងនេះ ៣១៥,២លានដុល្លារបានមកពីសហភាពអឺរ៉ុប

# តាមដានសេដ្ឋកិច្ច ~ សន្ទស្សន៍សេដ្ឋកិច្ច

## តារាង១. កម្ពុជា: សន្ទស្សន៍ម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ពីឆ្នាំ១៩៩៣-២០០០

| | 1993 | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 |
|---|---|---|---|---|---|---|---|---|
| ផសស ថ្លៃបច្ចុប្បន្ន (ពាន់លានរៀល) | 6,080 | 6,220 | 7,200 | 8,330 | 9,150 | 10,600 | 11,640 | 11,993 |
| ផសស តំលៃបច្ចុប្បន្ន (លានដុល្លារ) | 2,160 | 2,420 | 2,925 | 3,155 | 3,050 | 2,790 | 3,050 | 3,108 |
| ផសស ក្នុងមនុស្សម្នាក់ក្នុងមួយឆ្នាំ (ដុល្លារ) | 225 | 245 | 284 | 295 | 276 | 244 | 259 | 257 |
| អត្រាកំណើននៃ ផសស ពិត (ថ្លៃថេរឆ្នាំ១៩៩៣) | 7.1 | 4.0 | 6.7 | 8.0 | 0.6 | 1.7 | 6.6 | 5.0 |
| កសិកម្ម | 5.5 | 5.2 | 10.3 | 2.0 | 2.8 | 0.9 | 1.3 | -2.2 |
| ឧស្សាហកម្ម | 12.7 | 4.8 | 9.0 | 19.3 | 0.4 | 14.0 | 8.9 | 14.9 |
| សេវាកម្ម | 6.9 | 2.6 | 2.4 | 10.5 | -1.5 | -2.1 | 11.0 | 7.8 |
| អតិផរណានៅត្រីមាសទី៤ (ជារៀល) | 41.0 | 17.8 | 3.5 | 9.0 | 9.1 | 12.6 | 0.0 | 0.5 |
| អត្រាប្តូរប្រាក់ រៀល/ដុល្លារ (មធ្យមភាគប្រចាំឆ្នាំ) | 2,814 | 2,569 | 2,462 | 2,641 | 3,000 | 3,800 | 3,820 | 3,859 |
| ចំនូលថវិកា (ភាគរយនៃ ផសស) | 4.8 | 9.5 | 8.9 | 9.0 | 9.6 | 8.9 | 11.3 | 11.9 |
| ចំនាយថវិកា (ភាគរយនៃ ផសស) | 10.0 | 16.2 | 16.7 | 17.3 | 13.8 | 14.7 | 16.6 | 17.5 |
| ឱនភាពថវិកាចរន្ត (ភាគរយនៃ ផសស) | -1.4 | -1.4 | -0.8 | -1.2 | 0.7 | -0.2 | 1.6 | 1.6 |
| ឱនភាពថវិកាទូទៅ (ភាគរយនៃ ផសស) | -5.2 | -6.7 | -7.7 | -8.3 | -4.1 | -5.8 | -5.3 | -5.6 |
| ទំនិញក្នុងស្រុកនាំចេញ (ភាគរយនៃ ផសស) | 7.4 | 10.6 | 10.8 | 11.4 | 17.9 | 21.8 | 24.8 | 36.4 |
| ទំនិញនាំចូលសំរាប់ប្រើប្រាស់ (ភាគរយនៃ ផសស) | 16.9 | 22.6 | 24.4 | 29.3 | 31.8 | 41.4 | 41.2 | 48.6 |
| ជញ្ជីងពាណិជ្ជកម្ម (ភាគរយនៃ ផសស) | -9.5 | -11.9 | -13.6 | -17.8 | -13.9 | -19.6 | -16.4 | -12.2 |
| តុល្យភាពគណនីចរន្ត (ភាគរយនៃ ផសស) | -5.2 | -10.6 | -14.0 | -16.8 | -12.1 | -17.8 | -13.6 | -9.0 |
| ការរួមចំណែកបរទេសដល់សេដ្ឋកិច្ច (ភាគរយនៃ ផសស) | 14.5 | 16.9 | 21.0 | 21.2 | 14.5 | 18.3 | 16.4 | 14.5 |
| សញ្ជ័យសរុប (ភាគរយនៃផសស) | 18.9 | 19.2 | 22.1 | 27.6 | 22.3 | 26.3 | 23.6 | 19.2 |
| ធនបំរុងបរទេសសរុប (ចំនួនខែនៃទំនិញនាំចូល) | 1.5 | 1.4 | 1.7 | 2.0 | 2.3 | 3.1 | 3.1 | 3.1 |
| ចំនួនប្រជាជន (ជាលាននាក់) | 9.6 | 9.9 | 10.3 | 10.7 | 11.1 | 11.4 | 11.8 | 12.1 |
| កំលាំងពលកម្ម (ភាគរយនៃចំនួនប្រជាជន) | 48.0 | 47.3 | 46.6 | 45.9 | 45.3 | 44.8 | 45.2 | 45.7 |

*ប្រភព: ទិន្នន័យរដ្ឋាភិបាល និង វិបសអ ។*

## តារាង២. គោលដៅនៃផលិតផលសំលៀកបំពាក់នាំចេញ ពីឆ្នាំ១៩៩៤-២០០១

| | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | | | 2001 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| សហរដ្ឋអាមេរិក | 0.0 | 0.02 | 0.1 | 26.8 | 74.1 | 121.5 | 187.7 | 220.4 | 187.9 | 189.3 | 192.9 | 198.0 |
| ប្រទេសឯទៀត | 1.0 | 6.6 | 19.6 | 30.0 | 20.5 | 17.0 | 37.6 | 78.8 | 77.3 | 62.8 | 68.8 | 102.7 |
| សរុប | 1.0 | 6.6 | 19.7 | 56.8 | 94.5 | 138.5 | 225.3 | 299.2 | 265.2 | 252.1 | 261.7 | 300.7 |
| | បំរែបំរួលភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | – | 560 | 200 | 187 | 66 | 47 | 64 | 98 | 100 | 29 | 16 | 0.5 |

*ប្រភព: នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, ក្រសួងពាណិជ្ជកម្ម (១៩៩៤-១៩៩៩ មធ្យមភាគប្រចាំត្រីមាស) ។*

## តារាង៣. ចំនួនអ្នកដំណើរតាមជើងហោះហើរអន្តរជាតិមកដល់ព្រលានយន្តហោះពោធិចិនតុង និងសៀមរាប ពីឆ្នាំ ១៩៩៤-២០០១

| | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | | | 2001 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | អ្នកដំណើរគិតជាពាន់នាក់ | | | | | | | | | | | |
| ទិដ្ឋាការអ្នកទេសចរ | 27.9 | 38.7 | 55.3 | 46.3 | 38.1 | 44.9 | 55.8 | 56.0 | 66.6 | 64.6 | 53.2 | 53.5 |
| ទិដ្ឋាការអ្នកជំនួញ | 7.1 | 10.6 | 15.8 | 13.9 | 10.7 | 16.0 | 13.0 | 12.7 | 14.7 | 20.0 | 23.2 | 20.9 |
| ទិដ្ឋាការផ្លូវការរដ្ឋ | 3.3 | 3.9 | 3.2 | 3.6 | 4.4 | 8.8 | 3.5 | 4.3 | 5.0 | 3.8 | 4.7 | 4.6 |
| សរុប នៅពោធិចិនតុង | 38.3 | 53.2 | 74.3 | 63.8 | 53.2 | 69.7 | 72.3 | 73.0 | 86.3 | 88.4 | 81.1 | 79.0 |
| សរុប នៅសៀមរាប | - | - | - | - | 2.6 | 7.15 | 14.8 | 20.1 | 32.2 | 41.9 | 23.6 | 30.5 |
| | ភាគរយប្រែប្រួលធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប នៅពោធិចិនតុង | 29.7 | 38.9 | 39.7 | -14.1 | -16.6 | 31.0 | 13.3 | 6.5 | 9.1 | 8.2 | 12.2 | 8.2 |
| សរុប នៅសៀមរាប | - | - | - | - | - | 175 | 202 | 183 | 166 | 111 | 59 | 52 |

*ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍ (១៩៩៤-១៩៩៩ មធ្យមភាគប្រចាំត្រីមាស) ។*

## តារាង៤. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI), អត្រាប្តូរប្រាក់ និងថ្លៃមាស ពីឆ្នាំ១៩៩៤-២០០១ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | | | 2001 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (ភាគរយប្រែប្រួលធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ខេត្ត | - | - | - | 6.1 | 16.3 | 6.2 | 4.0 | 6.5 | 10.4 | 4.8 | 1.3 | -1.1 |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | -0.5 | 7.8 | 7.1 | 8.1 | 14.2 | 4.2 | -2.3 | -1.4 | 0.5 | -0.8 | 0.1 | -0.4 |
| - ម្ហូបអាហារ | -13.4 | 4.9 | 7.6 | 6.7 | 15.6 | 8 | -5.5 | -5.1 | -1.3 | -2.6 | -2.2 | -2.4 |
| - ថាមពល | -1.2 | 19.4 | 20.7 | 21.0 | 10.7 | 5.5 | 3.6 | 8.8 | 6.7 | 0.5 | 1.5 | -3.0 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 2,582 | 2,479 | 2,666 | 3,029 | 3824 | 3832 | 3,874 | 3,912 | 3,906 | 3,925 | 3,931 | 3,953 |
| រៀលក្នុង ១ បាត | 102 | 99 | 105 | 98 | 88 | 101 | 99 | 94 | 90.3 | 88.5 | 86.6 | 88.2 |
| រៀលក្នុង ១០០ ដុង | 23.5 | 22.3 | 24.0 | 25.6 | 28.6 | 27.8 | 27.3 | 27.5 | 27.3 | 26.9 | 26.8 | 26.4 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 45.8 | 45.9 | 46.3 | 40.4 | 36.0 | 34.0 | 33.8 | 34.0 | 32.6 | 32.0 | 32.0 | 33.6 |
| ថ្លៃប្រេងម៉ាស៊ូត (រៀល/លីត្រ) | 750 | 716 | 779 | 883 | 1,065 | 1,105 | 1,256 | 1,353 | 1,483 | 1,483 | 1,533 | 1,550 |
| ថ្លៃសាំង (រៀល/លីត្រ) | 698 | 847 | 1,118 | 1,378 | 1,613 | 1,760 | 2,043 | 2,200 | 2,233 | 2,100 | 2,100 | 2,100 |

*ប្រភព: វិបសអ, IMF, NIS, ក្រសួងផែនការ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។*

# តាមដានសេដ្ឋកិច្ច ~ សន្ទស្សន៍សេដ្ឋកិច្ច

## តារាង៥. ចំណូលប្រចាំថ្ងៃជាមធ្យមរបស់ពលករ ពីឆ្នាំ១៩៩៧ -២០០១

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1997 | 2000 | | | | 2001 | | | | 2001 | 2001 | 2001 |
| | Pre-Jul | Feb | May | Aug | Nov | Feb | May | Aug | Nov | May | Aug | Nov |
| អ្នកធាក់ស៊ីក្លូ | 12,250 | 9,682 | 9,691 | 9,511 | 8,398 | 8,200 | 9,568 | 9,057 | 6,262 | -1.3 | -4.8 | -25.4 |
| អ្នកលីសែង | 9,675 | 8,275 | 8,002 | 8,068 | 6,893 | 7,300 | 7,058 | 7,189 | 5,000 | -11.8 | -10.9 | -27.5 |
| អ្នកលក់ដូរតូចតាច | 7,050 | 7,864 | 7,267 | 6,611 | 5,813 | 6,400 | 7,386 | 6,670 | 5,096 | 1.6 | 0.9 | -12.3 |
| អ្នករើសសំរាម | 4,155 | 4,750 | 4,969 | 4,186 | 3,006 | 3,900 | 2,670 | 2,686 | 3,393 | -46.3 | -35.8 | 12.9 |
| អ្នកបំរើតាមហាង * | – | 1,873 | 2,030 | 2,250 | 2,335 | 2,600 | 2,600 | 2,683 | 2,358 | 28.1 | 19.2 | 1.0 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | – | 3,600 | 4,000 | 4,443 | 4,184 | 4,100 | 3,613 | 4,500 | 3,618 | -9.7 | 1.3 | -13.5 |
| កម្មកររោងចក្រកាត់ដេរ | – | 7,283 | 8,272 | 8,500 | 7,410 | 8,300 | 7,500 | 9,165 | 8,968 | -9.3 | 7.8 | 21.0 |
| អ្នករត់ម៉ូតូឌុប | – | 9,200 | 12,100 | 11,044 | 9,522 | 10,000 | 12,050 | 10,559 | 9,791 | -0.4 | -4.4 | 2.8 |
| កម្មករសំណង់គ្មានជំនាញ | – | 9,193 | 6,900 | 8,220 | 5,970 | 7,500 | 8,261 | 5,625 | 4,841 | 19.7 | -31.6 | -18.9 |
| កម្មករសំណង់មានជំនាញ | – | 15,873 | 15,600 | 14,891 | 14,517 | 11,200 | 10,306 | 12,375 | 9,866 | -33.9 | -16.9 | -32.0 |

*សំគាល់: អង្កេតចំនួលអ្នកបំរើ អ្នកស៊ីឈ្នួលធ្វើស្រែ កម្មករកាត់ដេរ អ្នកម៉ូតូឌុប និងកម្មករសំនង់មាន និងគ្មានជំនាញ ចាប់ធ្វើនៅខែកុម្ភៈ ២០០០ ។ * ចំនូលអ្នកបំរើមិនរាប់បញ្ចូលទាំងអាហារ និងការស្នាក់នៅដែលម្ចាស់ហាងផ្តល់ឱ្យទេ ។ ប្រភព: វបសអ ។*

## តារាង៦. ស្ថានភាពរូបិយវត្ថុ ពីឆ្នាំ១៩៩៤-២០០១ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | | | 2001 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | | | | | | គិតជាពាន់លានរៀល | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 391 | 550 | 881 | 1,172 | 1,550 | 1,961 | 2,510 | 2,448 | 2,589 | 2,733 | 2,807 | 2,951 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 59 | 99 | 31 | -109 | -435 | -591 | -679 | -656 | -759 | -834 | -821 | -827 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | 143 | 148 | 128 | 54 | 141 | 111 | 41 | 6 | 3 | -69 | -82 | -73 |
| ឥណទានចំពោះផ្នែកឯកជន | 237 | 293 | 435 | 637 | 682 | 731 | 860 | 932 | 898 | 905 | 947 | 992 |
| រូបិយវត្ថុទូទៅ M2 | 450 | 650 | 912 | 1,063 | 1,116 | 1,370 | 1,831 | 1,792 | 1,831 | 1,899 | 1,985 | 2,124 |
| រូបិយវត្ថុ M1 | 200 | 279 | 329 | 385 | 466 | 515 | 546 | 540 | 540 | 548 | 544 | 569 |
| រូបិយវត្ថុផ្សេងៗ | 250 | 371 | 583 | 678 | 655 | 855 | 1,286 | 1,252 | 1,291 | 1,351 | 1,441 | 1,555 |
| | | | | | | ភាគរយប្រែប្រួលធៀបនឹងឆ្នាំមុន | | | | | | |
| រូបិយវត្ថុទូទៅ M2 | 35.1 | 44.3 | 40.3 | 16.6 | 4.9 | 22.7 | 39.1 | 27.4 | 26.8 | 9.6 | 8.4 | 18.5 |
| រូបិយវត្ថុ M1 | -1.9 | 39.5 | 17.9 | 17 | 21 | 10.5 | 9.2 | 7.8 | 1.5 | -0.4 | -0.4 | 5.4 |
| រូបិយវត្ថុផ្សេងៗ | 93.2 | 48.1 | 57.2 | 16.4 | -3.4 | 30.5 | 53.4 | 38.5 | 41.7 | 14.2 | 12.1 | 24.2 |

*ប្រភព: ធនាគារជាតិនៃកម្ពុជា ។*

## តារាង៧. ប្រតិបត្តិការថវិកាជាតិ ពីឆ្នាំ១៩៩៤-២០០១ (គិតជាពាន់លានរៀល)

| | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | | | 2001 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ចំណូលសរុប | 148 | 161 | 187 | 220 | 230 | 329 | 378 | 336 | 377 | 366 | 400 | 360 |
| ចំណូលពន្ធ | 91 | 111 | 134 | 149 | 169 | 239 | 281 | 246 | 268 | 263 | 291 | 261 |
| ពន្ធគយ | 70 | 80 | 86 | 87 | 94 | 108 | 106 | 83 | 104 | 98 | 105 | 83 |
| ចំណូលមិនមែនពន្ធ | 56 | 47 | 44 | 68 | 51 | 87 | 97 | 84 | 85 | 100 | 107 | 97 |
| អាជីវកម្មព្រៃឈើ | 22 | 13 | 7 | 9 | 5 | 9 | 11 | 7 | 13 | 10 | 9 | 8 |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 15 | 14 | 16 | 21 | 22 | 27 | 34 | 14 | 25 | 23 | 28 | 30 |
| ចំណូលជាមូលធន | 0 | 2 | 10 | 3 | 9 | 3 | 0 | 6 | 23 | 3 | 2 | 2 |
| ចំណាយសរុប | 252 | 300 | 360 | 315 | 324 | 448 | 483 | 514 | 653 | 453 | 517 | 582 |
| ចំណាយជាមូលធន | 84 | 128 | 157 | 113 | 92 | 156 | 209 | 280 | 223 | 198 | 210 | 250 |
| ចំណាយចរន្ត | 168 | 172 | 203 | 202 | 245 | 291 | 274 | 234 | 430 | 255 | 307 | 333 |
| អប់រំ និងសុខាភិបាល | 23 | 25 | 31 | 32 | 33 | 70 | 35 | 32 | 150 | 27 | 47 | 52 |
| ការពារជាតិ និងសន្តិសុខ | 98 | 106 | 102 | 105 | 110 | 116 | 118 | 74 | 164 | 63 | 88 | 91 |
| ក្រសួងផ្សេងៗ | 48 | 41 | 71 | 65 | 83 | 103 | 122 | 128 | 116 | 165 | 172 | 190 |
| ឱនភាពជាទូទៅ | -105 | -139 | -173 | -95 | -95 | -119 | -105 | -178 | -276 | -87 | -117 | -222 |
| ហិរញ្ញប្បទានក្រៅប្រទេស | 108 | 140 | 170 | 111 | 67 | 104 | 168 | 212 | 164 | 165 | 160 | 236 |
| ហិរញ្ញប្បទានក្នុងស្រុក | -3 | -1 | 3 | -16 | 28 | 15 | -63 | -34 | 112 | -78 | -43 | -13 |

*ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (១៩៩៤-១៩៩៩ មធ្យមភាគប្រចាំត្រីមាស) ។*

## តារាង៨. គំរោងវិនិយោគដែលបានអនុម័ត ពីឆ្នាំ១៩៩៤-២០០១ *

| | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | | | 2001 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q1-Q4 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | | | | | | | ចំនួនគំរោងវិនិយោគ | | | | | |
| សរុប | 46 | 51 | 75 | 34 | 35 | 24 | 27 | 29 | 13 | 11 | 13 | 12 |
| កាត់ដេរ | 27 | 30 | 36 | 12 | 21 | 11 | 17 | 13 | 7 | 4 | 7 | 6 |
| | | | | | | | មូលធនដែលបានចុះបញ្ជី (គិតជាលានដុល្លារ) | | | | | |
| សរុប | 116.0 | 89.0 | 97.8 | 69.5 | 104.1 | 61.7 | 19.7 | 42.7 | 24.5 | 5.1 | 15.2 | 15.2 |
| កាត់ដេរ | 26.8 | 28.0 | 39.2 | 8.6 | 22.9 | 13.9 | 7.0 | 8.2 | 4.0 | 1.0 | 6.0 | 8.8 |
| | | | | | | | ទ្រព្យសកម្មជាប់លាប់ (គិតជាលានដុល្លារ) | | | | | |
| សរុប | 303.0 | 76.2 | 186.7 | 190.4 | 212.3 | 118.5 | 85.8 | 86.6 | 56.0 | 10.1 | 29.1 | 16.5 |
| កាត់ដេរ | 25.1 | 25.4 | 39.6 | 9.7 | 30.2 | 19.9 | 28.3 | 17.3 | 7.5 | 5.7 | 8.2 | 10.0 |

*ប្រភព: ក្រុមប្រឹក្សាវិនិយោគកម្ពុជា (១៩៩៤-១៩៩៩ មធ្យមភាគប្រចាំត្រីមាស) ។ * ក្នុងនេះមានទាំងគំរោងពង្រីកគំរោងវិនិយោគដែលមានស្រាប់ ។*

# សន្ទានុក្រម
# វាក្យស័ព្ទខ្លះដែលប្រើប្រាស់នៅក្នុងអត្ថបទ

**វុក្ខសាស្ត្រ** (forestry)*
ប្រព័ន្ធសកម្មភាពជាប់ទាក់ទងនឹងព្រៃឈើ តំបន់ព្រៃឈើ ផលិតផលឈើ និងអនុផលព្រៃឈើ, ដែលត្រូវបានអនុវត្តតាមវិធីសាស្ត្រម៉ត់ចត់មួយមានទិដ្ឋភាពចំរុះខាងគោលនយោបាយ, ច្បាប់, បច្ចេកទេស, វិទ្យាសាស្ត្រ, និង រដ្ឋបាល ។

**សម្បទានិក** (concessionaire)*
អង្គភាពស្របច្បាប់ជាតិ ឬបរទេស ដែលរដ្ឋបានផ្តល់ឱ្យតាមរយៈដំណើរការដេញថ្លៃជាសាធារណៈនិងមានការអនុញ្ញាតត្រឹមត្រូវ នូវសិទ្ធិប្រើប្រាស់សម្បទានព្រៃឈើ ។

**កិច្ចសន្យាសម្បទាននៅកម្ពុជា** (concession agreement in Cambodia)*
កិច្ចសន្យារវាងរដ្ឋ នឹងសម្បទានិក សំរាប់ការគ្រប់គ្រងមានចីរភាព និងសំរាប់ការប្រមូលយកផលិតផលឈើ និងអនុផលព្រៃឈើ អំពីព្រៃសម្បទានមួយដែលមានការអនុញ្ញាតស្របតាមសេចក្តីចែងនៅក្នុងច្បាប់ព្រៃឈើ និងកិច្ចសន្យាព្រៃសម្បទាន ។

**សួយ** (royalties)*
ប្រាក់ដែលរូបវន្តបុគ្គល នីតិបុគ្គល ឬសហគមន៍ បង់ជូនរដ្ឋជាការទូទាត់ចំពោះផលិតផលឈើ និងអនុផលព្រៃឈើ ដែលប្រមូលយកបានពីព្រៃបំរុងរបស់រដ្ឋ ។

**អនុផលព្រៃឈើ** (non-timber forest products: NTFPs)
ផលិតផលក្រៅពីឈើ ដែលប្រមូលយកបានពីព្រៃឈើ និងមានជាអាទិ ឬស្សី ផ្តៅ ជ័រ បន្លែព្រៃ ផលិតផលបានពីសត្វព្រៃ និងផលិតផលផ្សេងទៀត ។

**ភាពងាយរងគ្រោះ** (vulnerability)
ស្ថានភាពងាយទទួលរងការប៉ះទង្គិចពីកត្តាមានគ្រោះថ្នាក់ ឬការវាយប្រហារផ្សេងៗ ដោយសារលក្ខណៈទន់ខ្សោយ ខាងផ្លូវកាយ, សំភារៈ ឬខាងសង្គមកិច្ច ។

**អត្រាកំណើន** (growth rate)
បំរើបំរួលគិតជាភាគរយនៃចំណូលជាតិនៅក្នុងឆ្នាំ ដោយធៀបនឹងឆ្នាំមុន ។

**គ្រឿងបង្អាក់ទឹកចិត្ត** (disincentive)
កត្តាបង្អាក់ចិត្តមិនឱ្យធ្វើសកម្មភាព ឬការប្រឹងប្រែងអ្វីមួយ ។

**ការទទួលស្គាល់** (accreditation)
ការកសាងកិត្តិស្តង់ដា និងបទដ្ឋានផ្សេងៗសំរាប់ឧត្តមសិក្សា ។

* តាមនិយមន័យក្នុង ***សេចក្តីព្រាងច្បាប់ព្រៃឈើ*** (២០ កក្កដា ២០០១) ជាភាសាអង់គ្លេស ។

---

## ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា-អត្រាជំនាវសំរាប់ឆ្នាំ២០០២

**ជំនាវក្នុងស្រុក (១ ច្បាប់ x ៤ លេខ = ៤ ច្បាប់ក្នុងមួយឆ្នាំ)**

p ទស្សនាវដ្តីជាភាសាអង់គ្លេស ($១៤) p ទស្សនាវដ្តីជាភាសាខ្មែរ (៥.០០០រៀល) បង់ជាប្រាក់សុទ្ធ p ឬជា US-dollar cheques p

(ប្រសិនបើបង់ជា US-dollar cheques សូមថែម $២ទៀត សំរាប់សេវាធនាគារ) សរុប: ____________________

**ជំនាវក្នុងស្រុក - បញ្ចុះតំលៃ (៥ ច្បាប់ x ៤ លេខ = ២០ ច្បាប់ក្នុងមួយឆ្នាំ)**

p ទស្សនាវដ្តីជាភាសាអង់គ្លេស ($៦០) p ទស្សនាវដ្តីជាភាសាខ្មែរ (២០.០០០រៀល) បង់ជាប្រាក់សុទ្ធ p ឬជា US-dollar cheques p

(ប្រសិនបើបង់ជា US-dollar cheques សូមថែម $២ទៀត សំរាប់សេវាធនាគារ) សរុប: ____________________

**ជំនាវក្រៅប្រទេស (១ ច្បាប់ x ៤ លេខ = ៤ ច្បាប់ក្នុងមួយឆ្នាំ)**

p ថៃ ឡាវ វៀតណាម p ទស្សនាវដ្តីជាភាសាអង់គ្លេស ($២៥)* p ទស្សនាវដ្តីជាភាសាខ្មែរ ($១៥)*

p អាស៊ី អឺរ៉ុប p ទស្សនាវដ្តីជាភាសាអង់គ្លេស ($៣០)* p ទស្សនាវដ្តីជាភាសាខ្មែរ ($២០)*

p អាមេរិក អាហ្វ្រិក p ទស្សនាវដ្តីជាភាសាអង់គ្លេស ($៣៥)* p ទស្សនាវដ្តីជាភាសាខ្មែរ ($២៥)*

* ថ្លៃជំនាវនេះរួមទាំងសេវាប្រៃសនីយ៍រួចហើយ ។ បង់ជាប្រាក់សុទ្ធ p (នៅភ្នំពេញ) ឬជា US-dollar cheques p (ប្រសិនបើបង់ជា US-dollar cheques សូមថែម $២០ ទៀតសំរាប់សេវាធនាគារ) ។ សូមបញ្ជាក់ថា វិទ្យាស្ថានទទួលការបង់ប្រាក់ពីបរទេសជា US-dollar cheques ឬ bankers draft តែប៉ុណ្ណោះ ។ **សរុប:** ____________________

ងារ: p បណ្ឌិត p លោក p លោកស្រី p កញ្ញា p ផ្សេងៗ ____________________

នាមត្រកូល ____________ នាមខ្លួន ____________ តួនាទី ____________

ក្រុមហ៊ុន/អង្គការ ____________________

អាសយដ្ឋាន (ប្រអប់សំបុត្រ CCC បើមាន) ____________________

ខេត្ត/ក្រុង ____________ ប្រទេស ____________ ទូរស័ព្ទ ____________

ទូរសារ ____________ អ៊ីម៉ែល (e-mail): ____________

បើលោក/លោកស្រី ត្រូវការជាវ សូមបំពេញបែបបទនេះ ហើយបញ្ជូនមក វិបសអ-CDRI វិញ ដោយភ្ជាប់មកជាមួយនូវចំនួនទឹកប្រាក់ដែលត្រូវបង់ផង ។

សូមជូនដំណឹងទៅផ្នែកបោះពុម្ពផ្សាយនៅ CDRI ប្រសិនបើអាសយដ្ឋានរបស់លោក-អ្នក មានការផ្លាស់ប្តូរ ។

# ព័ត៌មានថ្មីៗពី វបសអ

## វបសអ

សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់បានជួបប្រជុំប្រចាំឆ្នាំនៅថ្ងៃទី៦-៧ ខែធ្នូ ឆ្នាំ២០០១ ដើម្បីពិនិត្យលទ្ធផលការងារ និងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០០១ អនុម័តផែនការប្រតិបត្តិការនិងថវិកាឆ្នាំ២០០២ និងអនុម័តក្របខ័ណ្ឌគោលនយោបាយសំរាប់តំរង់ទិសកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្ស ។ ក្របខ័ណ្ឌគោលនយោបាយនេះត្រូវបាន រៀបចំឡើងក្នុងរយៈពេលមានបេសកកម្មប្រឹក្សាយោបល់របស់លោក Paul Matthews ក្នុងខែវិច្ឆិកា ឆ្នាំ២០០១ បានផ្អែកលើបទពិសោធន៍កន្លងមករបស់ វបសអ ក្នុងការងារ អភិវឌ្ឍន៍ធនធានមនុស្ស ឯកសារផែនការផ្សេងៗរបស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំង យោបល់ និងអនុសាសន៍ផ្សេងៗរបស់អ្នកជាប់ពាក់ព័ន្ធ និងដៃគូនានារបស់ វបសអ ។ ពីថ្ងៃទី០៤ ដល់ ០៦ ខែធ្នូ ឆ្នាំ២០០១ វបសអ បានរៀបចំសិក្ខាសាលាមួយ ជូនដល់សមាជិកព្រឹទ្ធសភា និងរដ្ឋសភាស្តីពីសេដ្ឋកិច្ចកម្ពុជា ថវិកាជាតិ និងការអភិវឌ្ឍន៍ ។ វិទ្យាស្ថានបានស្វាគមន៍លោក Bruce McKenny, លោក ព្រំ-តុលា, លោកស្រី Moudda Billmeier ដែលចូលមកបំរើការជាបុគ្គលិក វបសអ ។

## ផ្នែកស្រាវជ្រាវ

ដំណាក់កាលទីពីរនៃការប្រមូលទិន្នន័យសំរាប់ការសិក្សាពីដីធ្លី និងសន្តិសុខស្បៀង បានចប់ស្រេចបាច់ក្នុងចន្លោះពេលពីខែកញ្ញា-វិច្ឆិកា ឆ្នាំ២០០១ ។ ព្រមគ្នានេះដែរ ទិន្នន័យទាំងអស់ដែលជាប់ទាក់ទិននឹងការសិក្សាពីទីផ្សារដីធ្លី ត្រូវបានកត់ត្រាចូលក្នុងប្រព័ន្ធមួយ ។ របាយការណ៍អភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជា សំរាប់ឆ្នាំ ២០០១ ត្រូវបានបង្ហើយ និងដាក់ជូនក្រសួងផែនការ និង UNDP ។ ក្នុងត្រីមាសទី៤ ឆ្នាំ ២០០១ វបសអ បានចាប់ផ្តើមកម្មវិធីស្រាវជ្រាវថ្មីពីរស្តីពី ការតាមដាននិងវិភាគពីភាពក្រីក្រ និងកម្មវិធីធនធានធម្មជាតិ និងបរិដ្ឋាន ។ ដំណាក់កាលទី៣ នៃគំរោងរបស់បណ្តាញវិភាគអភិវឌ្ឍន៍ស្តីពីការបង្កើនចំនួនមុខរបរ និងការងារក្រៅកសិដ្ឋាន បានចាប់ដំណើរការតាមរយៈសិក្ខាសាលាស្តីពីវិធីសាស្ត្រដែលបានធ្វើកាលពីខែធ្នូ ឆ្នាំ២០០១ ។

## មជ្ឈមណ្ឌលដើម្បីសន្តិភាព និងអភិវឌ្ឍន៍ (មសអ)

ការប្រជុំតុមូលប្រចាំខែ ឧបសែល ដើម្បីទប់ស្កាត់ទំនាស់នៅក្នុងការបោះឆ្នោតឃុំ-សង្កាត់បានបន្តធ្វើជាទៀងទាត់ ។ មសអ បានរៀបចំសិក្ខាសាលាមួយសំរាប់ប្រព័ន្ធផ្សព្វផ្សាយ និងបានជួយសំរួលដល់ការសន្ទនារវាងភាគីផ្សេងៗនៅក្នុងជំលោះខាងពលកម្ម ។ ក្រុមបណ្តុះបណ្តាលរបស់ មសអ បានដំណើរការវគ្គសិក្សាពីរទៀតស្តីពីវិធី *គ្រប់គ្រងការប្រែប្រួល* សំរាប់មន្ត្រីនៅមូលដ្ឋាន ក្នុងតំបន់ផ្ទុះផ្សានៅអន្លង់វែង និងត្រពាំងប្រាសាទ ។ មសអ ក៏បានចាប់ផ្តើមដែរនូវកំរងសិក្ខាសាលាថ្មីមួយសំរាប់ស្ត្រី ស្តីពីការគ្រប់គ្រងទំនាស់ និងការកសាងសន្តិភាព ដែលត្រូវបន្តក្នុងខែមករា និងមីនា ឆ្នាំ ២០០២ ។ ក្នុងខែវិច្ឆិកា ឆ្នាំ២០០១ មសអ បានដឹកនាំក្រុមបេសកកម្មចំរុះរដ្ឋាភិបាល-NGO ទៅប្រទេសអាហ្វ្រិកខាងត្បូងដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងសិក្សាពីបទពិសោធន៍កសាងសង្គមឡើងវិញក្រោយពេលបញ្ចប់ទំនាស់ ។ ក្នុងបេសកកម្ម សមាជិកក្រុមបានពិភាក្សាពីកំណែទំរង់ និងយុទ្ធសាស្ត្រនានា ដែលជួយជំរុញដល់ការផ្សះផ្សានិងការកសាងជាតិ ។ មួយចំណែកទៀត សៀវភៅរូបភាពទាំងបួនក្បាលស្តីពី *ការសុំរុះសំរួលប្រកបដោយសតិ* ដែលជាការណែនាំតាមបែបពុទ្ធសាសនាពីវិធីគ្រប់គ្រងទំនាស់ និងកសាងសន្តិភាព ត្រូវបានបោះពុម្ពឡើងវិញ សំរាប់ផ្សព្វផ្សាយនៅក្នុងឆ្នាំថ្មី ។

## បណ្ណាល័យ

បណ្ណាល័យ វបសអ បានផ្លាស់បន្ទប់ទៅនៅកន្លែងធំទូលាយជាងមុនដើម្បីតំរូវតាមការរីកចំរើននៃសេវា និងកំណើនចំនួនអ្នកប្រើប្រាស់បណ្ណាល័យ ។ កុំព្យូទ័រច្រើនគ្រឿងទៀតត្រូវបានដាក់ឱ្យប្រើប្រាស់ ដើម្បីសំរួលដល់ការរកសៀវភៅ ។

## ផ្នែកបោះពុម្ពផ្សាយ

---

**ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា ក៏មានផ្សាយជាភាសាអង់គ្លេសដែរ ៕**

***Cambodia Development Review*** **is also available in English.**


ឯកសារបោះពុម្ពផ្សាយរបស់ *វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

**ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា**

ឆ្នាំទី៦ លេខ១ ខែមករា-មីនា ឆ្នាំ២០០២



**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា

អាសយដ្ឋានប្រៃសណីយ: ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

ទូរស័ព្ទ: (៨៥៥-២៣) ៣៦៨-០៥៣, ៨៨០-៧៣៤, ៨៨៣-៦០៩ ទូរសារ: (៨៥៥-២៣) ៣៦៦-០៩៤

e-mail: cdri@camnet.com.kh / pubs@cdri.forum.org.kh

website: http://www.cdri.org.kh


***ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា*** បោះពុម្ពដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង/មួយឆ្នាំ ជាភាសាខ្មែរ និងអង់គ្លេសក្នុងពេលដំណាលគ្នា ។

***ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា*** ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ ***អត្ថបទតាមដានសេដ្ឋកិច្ច*** ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

***ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា*** ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិតត្រូវចុះហត្ថលេខា ប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹង ត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។


គ្រឹះស្ថានផ្សាយ: វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

គ្រប់គ្រងកែសំរួលស្តីទី: អែម សូវ៉ានី / កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា

អ្នកបកប្រែ: យូ សិទ្ធិរិទ្ធ

រោងពុម្ព: រោងពុម្ពជប៉ុន ភ្នំពេញ



**រក្សាសិទ្ធិ ២០០២** វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។



**ISSN 1560-7615**


ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។